**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# របបនៃការប្រកាសទោស

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **យុន លក្ខណា**

ណែនាំដោយ

លោក **មីន សំអុល**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្ដីថ្លែងអំណរគុណ

ជាបឋម នាងខ្ញុំឈ្មោះ **យុន លក្ខណា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា ២០២២-២០២៣។

**សូមគោរពលំឱនកាយវាចារចិត្តថ្លែងនូវកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ ៖**

លោកឪពុក **តែម សំអាន** អ្នកម្ដាយ **ទេព សុម៉ាលី**

ដែលអ្នកមានគុណទាំងទ្វេបានផ្ដល់កំណើត និងអត់ធ្មត់ប្រឹងប្រែងតស៊ូធ្វើការសព្វគ្រប់បែបយ៉ាង ដើម្បីចិញ្ចឹមបីបាច់ថែរក្សារូបកូនតាំងពីនៅតូចរហូតដល់ធំពេញវ័យ ព្រមទាំងការឧបត្ថម្ភផ្គត់ផ្គង់ ទំនុកបម្រុងឲ្យរូបកូនបានចូលសិក្សាតាំងពីថ្នាក់បឋមសិក្សារហូតដល់រូបកូនបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។ មិនតែប៉ុណ្ណោះលោកទាំងពីរបានលះបង់នូវកម្លាំងកាយ កម្លាំងចិត្ត បង្ហាត់បង្រៀន អប់រំណែនាំ ទូន្មានប្រៀនប្រដៅ និងជួយជំរុញលើកទឹកចិត្តដល់រូបកូនឱ្យខំប្រឹងប្រែងរៀនសូត្រ ដើម្បីឱ្យរូបកូនមានអនាគតភ្លឺស្វាង និងអភិវឌ្ឍខ្លួនក្លាយជាកូនល្អ សិស្សល្អ ពលរដ្ឋល្អ នៅក្នុងសង្គមជាតិ។

ឯកឧត្ដម **លុយ ចន្ធា** សាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស រួមទាំងលោកលោកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោកបានខិតខំដឹកនាំគ្រប់គ្រង បង្ហាត់បង្រៀន និងផ្ដល់នូវចំណេះដឹងក្នុងការជួយតម្រង់ទិសដៅដល់រូបយើងខ្ញុំតាំងពីឆ្នាំសិក្សាថ្នាក់មូលដ្ឋាន រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះប្រកបដោយក្រមសីលធម៌។

លោកគ្រូ **មីន សំអុល** ដែលលោកបានខិតខំចំណាយពេលវេលាដ៏មានតម្លៃផ្ដល់នូវគំនិតយោបល់ វិធីសាស្ត្រសិក្សាស្រាវជ្រាវ បង្ហាត់បង្ហាញផ្ដល់នូវមតិកែលម្អ និងជួយជ្រោមជ្រែងក្នុងការសរសេរកិច្ចការស្រាវជ្រាវមួយនេះតាំងពីដើមរហូតដល់ចប់ស្នាដៃ។ ស្នាដៃដែលកើតចេញពីការស្រាវជ្រាវមួយនេះពិតជាមិនអាចមានអត្ថិភាពឡើយ ប្រសិនបើគ្មានការជ្រោមជ្រែងពីលោកគ្រូ ។

ជាចុងបញ្ចប់ យើងខ្ញុំសូមបួងសួងដល់វត្ថុសក្ដិសិទ្ធទាំងឡាយក្នុង ព្រះរាជាណាចក្រកម្ពុជាជួយប្រសិទ្ធពរជ័យជូនអ្នកមានគុណទាំងទ្វេ ឯកឧត្ដម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យនិស្សិត និងមិត្តជាទីស្រលាញ់រាប់អានទាំងអស់ ជួបតែនឹងសេចក្ដីសុខចម្រើន សុខភាពល្អ នៅក្នុងជីវិតតរៀងទៅ ព្រមទាំងជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀតឃ្លាឡើយ។

# អារម្ភកថា

ក្រោយពីបានឆ្លងកាត់ការសិក្សា និងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល៤ឆ្នាំកន្លងមកនេះ ដោយកិច្ចខិតខំប្រឹងប្រែងក្នុងការរៀនសូត្រដើម្បីទទួលបានចំណេះដឹងពី លោក លោកស្រី សាស្ត្រាចារ្យនៅក្នុងសាកលវិទ្យាល័យ យើងខ្ញុំទាំងពីររូបត្រូវបានលើកទឹកចិត្ត និងទទួលបានការអនុញ្ញាតពីសាកលវិទ្យាល័យដើម្បីសរសេរសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទស្តីពី **របបនៃការប្រកាសទោស** ។

មូលហេតុនៃការជ្រើសរើសយកប្រធានបទមួយនេះ គឺដោយសារក្រុមយើងខ្ញុំចង់សិក្សាស្វែងយល់បន្ថែម និងកាន់តែស៊ីជម្រៅទៅលើផ្នែកព្រហ្មទណ្ឌ ដែលជាផ្នែកដ៏សំខាន់នៅក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ជាពិសេសទាក់ទងនឹងដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ ការកំណត់អត្តិភាពនៃបទល្មើស ការអនុវត្តទោស និងការប្រកាសទោសរបស់តុលាការនៅក្នុងប្រព័ន្ធច្បាប់។

ក្រុមយើងខ្ញុំមានសេចក្តីសោមនស្សរីករាយពន់ពេកដែលមានឱកាសក្នុងការសិក្សាស្រាវជ្រាវ និងរៀបចំសរសេរសារណានេះក្រោមការណែនាំដោយលោក **មីន សំអុល** ដែលជា សាស្ត្រាចារ្យផ្នែកច្បាប់មួយរូបដែលមានបទពិសោធន៍ទាក់ទងនឹងវិស័យសាធារណៈ។ សារណាមួយនេះមានទិសដៅស្រាវជ្រាវប្រមូលផ្តុំ និងចងក្រងក្នុងគោលបំណងបន្សល់ទុកជាឯកសារ សម្រាប់បំពេញនូវតម្រូវការរបស់សិស្សនិស្សិតជំនាន់ក្រោយយកទៅសិក្សាស្រាវជ្រាវបន្ថែមទៀត ដើម្បីបង្កើននូវចំណេះដឹងក៏ដូចជាការយល់ដឹងពីច្បាប់ឲ្យកាន់តែទូលំទូលាយទាក់ទងទៅនឹងដំណើរការនៃមូលហេតុដែលនាំឱ្យមានការប្រកាសទោស។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរសង្ឃឹមថាសារណាបញ្ចប់ការសិក្សានេះនឹងអាចធ្វើជាឯកសារជំនួយក្នុងការសិក្សាស្រាវជ្រាវក្នុងរឿងព្រហ្មទណ្ឌដល់អ្នកសិក្សាជំនាន់ក្រោយ។ ទន្ទឹមនឹងនេះផងដែរ យើងខ្ញុំទាំងពីរសូមធ្វើការអធ្យាស្រ័យទុកជាមុនចំពោះចំណុចខ្វះខាត កំហុសខុសឆ្គងទាំងខ្លឹមសារ ឃ្លាប្រយោគ ព្រមទាំង អក្ខរាវិរុទ្ធ ដោយអចេតនា ឬ ដោយប្រការណាមួយ។ យើងខ្ញុំទាំងពីររង់ចាំទទួលការរិះគន់ ការកែតម្រូវ ដើម្បីស្ថាបនាគ្រប់បែបយ៉ាងពីសំណាក់ លោក លោកស្រី សាស្ត្រាចារ្យ សិស្សនិស្សិត មិត្តអ្នកអាន និងអ្នកស្តាប់ទាំងអស់គ្នា ដើម្បីឱ្យសារណានេះកាន់តែមានភាពល្អប្រសើរឡើង។

# មាតិកា


**សេចក្តីផ្តើម** ........ ១

**ជំពូកទី១៖ របបទូទៅនៃការប្រកាសទោសព្រហ្មទណ្ឌ** ........ ៤

ផ្នែកទី១. គោលការណ៍មូលដ្ឋានរួមនៅក្នុងរបបនៃការប្រកាសទោស ........ ៤

កថាខណ្ឌទី១៖ គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ........ ៥

កថាខណ្ឌទី២៖ គោលការណ៍ឯកត្តកម្មនៃទោស ........ ៦

ផ្នែកទី២៖ ការប្រកាសទោសព្រហ្មទណ្ឌទៅលើប្រភេទនៃទោសនីមួយៗចំពោះរូបវន្តបុគ្គល ........ ៧

កថាខណ្ឌទី១៖ ការប្រកាសមូលទោស ........ ៧

១.១ ការប្រកាសមូលទោសទៅលើរូបវន្តបុគ្គលជានីតិជន ........ ៨

១.២ ការប្រកាសមូលទោសទៅលើរូបវន្តបុគ្គលជាអនីតិជន ........ ៨

ក. អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ........ ៩

ខ.អនីតិជនដែលមានអាយុចាប់ពី ១៤  ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ........ ១០

កថាខណ្ឌទី២៖ ការប្រកាសទោសបន្ថែម ........ ១០

២.១. ការប្រកាសទោសបន្ថែមទៅលើរូបវន្តបុគ្គលជានីតិជន ........ ១១

២.២.  ការប្រកាសទោសបន្ថែមទៅលើរូបវន្តបុគ្គលជាអនីតិជន ........ ១២

ក. អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ........ ១២

ខ. អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ........ ១២

កថាខណ្ឌទី៣៖ ការប្រកាសទោសជំនួស ........ ១៣

៣.១ ការប្រកាសទោសការងារសហគមន៍ ........ ១៣

ក.ការប្រកាសទោសការងារសហគមន៍ទៅលើរូបវន្តបុគ្គលជានីតិជន ........ ១៣

ខ. ការប្រកាសទោសការងារសហគមន៍ទៅលើរូបវន្តបុគ្គលជាអនីតិជន ........ ១៣

ខ.១ អនីតិជនដែលមានអាយុក្រោម១៦ ឆ្នាំ ........ ១៤

ខ.២ អនីតិជនដែលមានអាយុយ៉ាងតិច ១៦ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ ........ ១៤

៣.២. ការប្រកាសទោសស្ដីបន្ទោស..................................................................................................១៤

ក. លក្ខខណ្ឌដើម្បីប្រកាសទោសស្ដីបន្ទោស ..........................................................................................១៤

ក.១. ភាពចលាចលដល់សណ្ដាប់ធ្នាប់សាធារណៈដែលបណ្ដាលមកពីបទល្មើសបានបញ្ចប់.........១៤

ក.២ ការខូចត្រូវបានជួសជុលរួចហើយ ..............................................................................................១៥

ក.៣ ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ..........................១៥

ខ. ការប្រកាសនូវទោសស្ដីបន្ទោសចំពោះរូបវន្តបុគ្គលទាំងពីរប្រភេទ..........................................១៥

ផ្នែកទី ៣៖ ការប្រកាសទោសព្រហ្មទណ្ឌទៅលើប្រភេទនៃទោសនីមួយៗចំពោះនីតិបុគ្គល ....................១៥

កថាខណ្ឌទី ១៖ នីតិបុគ្គលនៃនីតិសាធារណៈ ឬ នីតិបុគ្គលដែលជារដ្ឋ..........................................១៥

កថាខណ្ឌទី ២៖ នីតិបុគ្គលនៃនីតិឯកជន ឬ នីតិបុគ្គលដែលមិនមែនជារដ្ឋ....................................១៦

**ជំពូកទី២ ៖ របបនានានៃការប្រកាសព្យួរទោស**......................................................................... ១៧

ផ្នែកទី១. ការប្រកាសព្យួរទោសធម្មតា ..........................................................................................១៨

កថាខណ្ឌទី១៖ ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម......................................................១៩

១.១ លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្ដន្ទាទោសពីមុន.........................................................................១៩

១.២ លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលនាំឲ្យមានការព្យួរទោសធម្មតា ............................១៩

១.៣ ចំណុចផ្សេងៗទៀតពាក់ព័ន្ធនឹងការព្យួរទោសធម្មតា .......................................................២០

ក. ការព្យួរទោសមួយផ្នែក........................................................................................................២០

ខ. ការដកហូតការព្យួរទោស ...................................................................................................... ២១

គ. ការមិនដកហូតការព្យួរទោស ..................................................................................................២១

ឃ. ការទុកជាអសារបង់នូវការផ្ដន្ទាទោស.................................................................................... ២២

កថាខណ្ឌទី ២៖ ការចោទប្រកាន់ចំពោះបទលហុ ..................................................................... ២២

២.១ លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្ដន្ទាទោសពីមុន........................................................................ ២២

២.២. លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលអាចនាំឲ្យមានការព្យួរទោសធម្មតា.......................២៣

២.៣. ចំណុចផ្សេងទៀតពាក់ព័ន្ធនឹងការព្យួរទោសធម្មតា .........................................................២៣

ក. ការដកហូតការព្យួរទោស ............................................................................................................... ២៣

ខ. ការមិនដកហូតការព្យួរទោស ........................................................................................................ ២៣

គ. ការទុកជាអសារបង់នូវការផ្តន្ទាទោស .............................................................................................. ២៤

កថាខណ្ឌទី៣៖ ការប្រកាសព្យួរទោសសាកល្បង.......................................................................................... ២៤

៣.១ លក្ខខណ្ឌនៃការព្យួរទោសសាកល្បង និងរយៈពេលនៃការសាកល្បង ............................................. ២៥

ក. លក្ខខណ្ឌនៃការព្យួរទោសសាកល្បង ............................................................................................. ២៥

ខ. រយៈពេលនៃការសាកល្បង............................................................................................................ ២៥

៣.២ វិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែក................................................................................ ២៦

ក. វិធានការត្រួតពិនិត្យដែលដាក់ទៅលើទណ្ឌិត.................................................................................... ២៦

ខ. កាតព្វកិច្ចដោយឡែកដែលដាក់ទៅលើទណ្ឌិត.................................................................................... ២៦

៣.៣ ការដកហូតការព្យួរទោសសាកល្បង ............................................................................................. ២៨

**ជំពូកទី៣៖ យន្តការសំខាន់ៗនៃរបបនៃការប្រកាសទោស**.......................................................................... ៣០

ផ្នែកទី១. របបនៃការផ្អាកការប្រកាសទោស ......................................................................................... ៣០

កថាខណ្ឌទី១. លក្ខខណ្ឌនៃការផ្អាកការប្រកាសទោស ......................................................................... ៣០

១.១ បទល្មើសដែលត្រូវចោទប្រកាន់ ................................................................................................ ៣០

ក. ភាពច្របូកច្របល់នៃសណ្តាប់ធ្នាប់សាធារណៈដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ឈប់ ... ៣១

ខ. ជនជាប់ចោទបានបង្ហាញនូវការធានា ក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ ........................ ៣១

គ. ជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត ...................................................................... ៣១

១.២ ជនជាប់ចោទត្រូវតែមានវត្តមាននៅពេលសវនាការ......................................................................... ៣១

កថាខណ្ឌទី២៖ សវនាការពិនិត្យរឿងដែលបង្អង់ និងភាពខុសគ្នារវាងការផ្អាកការប្រកាស និងការផ្អាកការសវនាការនាពេលសព្វថ្ងៃ..................................................................................................... ៣២

១.១. សវនាការពិនិត្យរឿងដែលបង្អង់ ............................................................................................... ៣២

១.២. ភាពខុសគ្នារវាងការផ្អាកការប្រកាស និងការផ្អាកសវនាការនាពេលសព្វថ្ងៃ ........................ ៣២

ផ្នែកទី ២៖ របបពាក់កណ្ដាលសេរីភាព............................................................................................................................ ៣៣
កថាខណ្ឌទី១៖ លក្ខខណ្ឌ និងបែបបទនៃរបបពាក់កណ្ដាលសេរីភាព ........................................................... ៣៣
១.១ លក្ខខណ្ឌនៃរបបពាក់កណ្ដាលសេរីភាព..................................................................................... ៣៤
១.២ បែបបទនៃរបបពាក់កណ្ដាលសេរីភាព ....................................................................................... ៣៤
កថាខណ្ឌទី២៖ ចំណុចផ្សេងៗទៀតនៃរបបពាក់កណ្ដាលសេរីភាព ................................................................ ៣៤
២.១ ការគិតបញ្ចូលរយៈពេលនៃរបបពាក់កណ្ដាលសេរីភាពទៅក្នុងទោស ................................. ៣៤
២.២ ការរៀបចំ និងការលុបចោលនៃរបបពាក់កណ្ដាលសេរីភាព............................................... ៣៥
២.៣ ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត ........................................................................................ ៣៥
ផ្នែកទី៣៖ ការបែងចែកទោសជាប្រភាគ.......................................................................................................... ៣៥
កថាខណ្ឌទី១៖ លក្ខខណ្ឌ និងបែបបទនៃការបែងចែកទោសជាប្រភាគ ....................................................... ៣៦
១.១ លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ................................................................................ ៣៦
១.២ បែបបទនៃការបែងចែកទោសជាប្រភាគ .................................................................................. ៣៦
កថាខណ្ឌទី២៖ ភាពដូចគ្នា និងភាពខុសគ្នារវាងការបែងចែកទោសជាប្រភាគ និងរបបពាក់កណ្ដាលសេរីភាព ............................................................................................................................................ ៣៦
២.១ ភាពដូចគ្នារវាងការបែងចែកទោសជាប្រភាគ និងរបបពាក់កណ្ដាលសេរីភាព....................... ៣៧
ក. លក្ខខណ្ឌដែលទទួលបាន ............................................................................................................ ៣៧
ខ. ការកែប្រែរបបនៃការបែងចែកទោសជាប្រភាគ ............................................................................ ៣៧
គ. ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត.............................................................................................. ៣៨
២.២ ភាពខុសគ្នា រវាងការបែងចែកទោសជាប្រភាគ និងរបបពាក់កណ្ដាលសេរីភាព .................... ៣៨
**សេចក្ដីសន្និដ្ឋាន** ........................................................................................................................ ៤០
**អនុសាសន៍**................................................................................................................................... ៤២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងបណ្តាប្រទេសដែលមានការប្រកាសនូវលទ្ធិប្រជាធិបតេយ្យ គឺអំណាចនៃការដឹកនាំរដ្ឋត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា ទាំងការប្រមូលផ្តុំទៅលើអំណាច ឬចូលថ្នាក់ដឹកនាំតែមួយនោះទេ។ ជាក់ស្តែងដូចជា នៅក្នុងប្រទេសកម្ពុជាដែលប្រកាន់នូវលទ្ធិប្រជាធិបតេយ្យ ក៏ពុំមានការខុសគ្នាពីបណ្តាប្រទេសសេរីមួយចំនួនទៀតដែរ ពោលគឺបានបែងចែកនូវអំណាចនៃការដឹកនាំរដ្ឋដាច់ដោយឡែកពីគ្នា គឺអង្គការនីតិបញ្ញត្តិ អង្គការនីតិប្រតិបត្តិ និងអង្គការតុលាការ។ ទាំងអស់នេះបានបង្ហាញឱ្យឃើញថានៅក្នុងចំណោមនៃអង្គការទាំង ៣ នេះមានតែអង្គការតុលាការមួយគត់ ដែលមាននូវសិទ្ធិអំណាចនៅក្នុងការសម្រេចសេចក្តីពាក់ព័ន្ធជាមួយនឹងវិវាទដែលកើតមានឡើង ហើយមានតែស្ថាប័ននេះតែប៉ុណ្ណោះដែលមានសិទ្ធិអំណាចនៅក្នុងការជម្រះក្តីដោយយុត្តិធម៌។ ហេតុដូចនេះ នៅពេលដែលមានបទល្មើសមួយកើតឡើង ត្រូវតែមាននូវបុគ្គលម្នាក់ទទួលខុសត្រូវចំពោះបទល្មើសនោះ កាលបើមានច្បាប់កំណត់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌ គឺទោសនោះត្រូវប្រកាសដោយតុលាការជាមុនសិន ប្រសិនបើគ្មានការប្រកាសទោសទេទោសនោះមិនអាចអនុវត្តបានឡើយ។

ជាគោលការណ៍ ការដោះស្រាយបញ្ហាដែលមានការពាក់ព័ន្ធទៅលើរឿងក្តីព្រហ្មទណ្ឌ គឺជាបន្ទុករបស់តុលាការព្រហ្មទណ្ឌ។ ចំពោះការប្រកាសទោសព្រហ្មទណ្ឌពិតជាមានលក្ខណៈពិសេសណាស់ ព្រោះវាមានទំនាក់ទំនងដែលឈានទៅដល់ការសម្រេចនៃជោគវាសនារបស់មនុស្ស ក្នុងការទទួលនូវទណ្ឌកម្មណាមួយដែលពាក់ព័ន្ធជាមួយការជាប់ពន្ធនាគារ នឹងការពិន័យជាប្រាក់ជាដើម។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយសារតែការប្រកាសទោសព្រហ្មទណ្ឌមានសារៈសំខាន់ណាស់សម្រាប់បុគ្គលទាំងឡាយដែល បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ និងមុនឈានទៅដល់ការសម្រេចសេចក្តី តុលាការត្រូវពិនិត្យពិចារណានូវទោសព្រហ្មទណ្ឌចំពោះបុគ្គលដែលបានប្រព្រឹត្តបទល្មើសនោះឱ្យបានល្អិតល្អន់ ច្បាស់លាស់ ដើម្បីជៀសវាងការអនុវត្តទោសខុសពីនីតិវិធី និងមានភាពអយុត្តិធម៌។ ដូច្នេះទើបមាននូវសំណួរចោទសួរឡើងថា៖

តើរបបគតិយុត្តនៃការប្រកាសទោសព្រហ្មទណ្ឌប្រព្រឹត្តទៅយ៉ាងដូចម្តេច? ក្រៅពីរបបនៃការប្រកាសទោសនេះ តើតុលាការមានយន្តការពិសេសអ្វីខ្លះដែលអាចផ្តល់លទ្ធភាពដល់ទណ្ឌិតក្នុងការកែប្រែខ្លួន?

## ៣. គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវសារណានេះដែរ គឺធ្វើឡើងក្នុងគោលបំណងដើម្បីសិក្សាស្វែង យល់អំពីភាពមិនច្បាស់លាស់មួយចំនួន ក៏ដូចជាចង់ស្រាយបំភ្លឺអំពីចំណោទបញ្ហាគតិយុត្តិដូចដែល បានលើកឡើងពីខាងលើស្រាប់។ លើសពីនេះទៅទៀត គឺដើម្បីពង្រឹង និងពង្រីកនូវសមត្ថភាព ផ្ទាល់ខ្លួនបន្ថែមទៀត ដែលទាក់ទង

និងវិស័យព្រហ្មទណ្ឌនេះ។ ហើយចំពោះសមិទ្ធផលដែលបានមកពីការសិក្សាស្រាវជ្រាវនេះ ក៏ជាផ្នែកមួយនៃការចូលរួមចំណែកក្នុងការអភិវឌ្ឍនូវវិស័យព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាផងដែរ ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទ ដែលបានលើកឡើងក្នុងចំណោទបញ្ហាខាងលើ យើងខ្ញុំខិតខំសិក្សាស្រាវជ្រាវទៅលើឯកសារគ្រឹះ និងជាមូលដ្ឋានដ៏សំខាន់គឺក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ និងឯកសារដែលពាក់ព័ន្ធទាំងឡាយដែលមានយោងក្នុងឯកសារពិគ្រោះយោបល់ដូចមានភ្ជាប់ជូនមកជាមួយ ដើម្បីសរសេរសារណានេះឡើង ដោយមានចំនួន ៣ ជំពូក។ ការស្រាវជ្រាវទៅលើប្រធានបទស្តីពីរបបនៃការប្រកាសផ្តន្ទាទោស គឺជាការសិក្សាដែលផ្តោតសំខាន់ទាក់ទងទៅនឹង គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គោលការណ៍ឯកត្តកម្មនៃទោស លក្ខខណ្ឌនៃការប្រកាសផ្តន្ទាទោសទៅលើជនល្មើស ការព្យួរទោស ការផ្អាកការប្រកាសទោស របបពាក់កណ្តាលសេរីភាព និងការចែងចែកទោសជាប្រភាគ ដោយអនុលោមតាមជំពូកទី៣ របបនៃការប្រកាសទោស ដែលមានចែងចាប់ពីមាត្រា ៩៦ ដល់មាត្រា ១៣៥ និងមាត្រាពាក់ព័ន្ធមួយចំនួនទៀត នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ និង ក្រមនីតិវិធីព្រហ្មទណ្ឌ ព្រមទាំងសេចក្តីណែនាំរបស់ក្រសួងយុត្តិធម៌មួយចំនួនដែលពាក់ព័ន្ធផងដែរ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

យើងដឹងហើយថាការស្រាវជ្រាវទៅលើប្រធានបទមួយ គឺជាការបកស្រាយក៏ដូចជាពន្យល់នូវអ្វីដែលពាក់ព័ន្ធនឹងប្រធានបទ។ ដូច្នេះសារណានេះអាចធ្វើឱ្យ បងប្អូនក៏ដូចជាមិត្តនិស្សិតជំនាន់ក្រោយទុកជាឯកសារជំនួយដល់ស្មារតីនៃការសិក្សាស្រាវជ្រាវរបស់ខ្លួន នឹងបានយល់ដឹងកាន់តែច្បាស់ថា៖ អ្វីទៅជារបបប្រកាសទោសព្រហ្មទណ្ឌ? ហើយតើការប្រកាសទោសព្រហ្មទណ្ឌត្រូវមានលក្ខខណ្ឌអ្វីខ្លះ? តើការប្រកាសព្យួរទោសត្រូវមានលក្ខខណ្ឌ និងបែបបទអ្វីខ្លះ? តើការប្រកាសព្យួរទោសធម្មតា និងការប្រកាសព្យួរទោសសាកល្បងមានលក្ខណៈខុសគ្នាដូចម្តេច? តើរបបដោយឡែកនៃការប្រកាសទោសព្រហ្មទណ្ឌមានអ្វីខ្លះ?

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសរសេរសារណានេះ យើងខ្ញុំធ្វើការសិក្សាបែបពិពណ៌នា និង វិភាគ ។ ការសិក្សាស្រាវជ្រាវបានធ្វើតាមរយៈការប្រមូលនូវព័ត៌មានទាំងឡាយ ក៏ដូចជាឯកសារពាក់ព័ន្ធទៅនឹងប្រធានបទនៃសារណានេះ ដើម្បីឱ្យសារណា មានភាពត្រឹមត្រូវ និងមានប្រសិទ្ធិភាព។ ព័ត៌មានដែលជ្រើសរើសយកមក តាមការស្រាវជ្រាវ និងមតិយោបល់ពី អ្នកជំនាញការខាងច្បាប់ព្រហ្មទណ្ឌ ព្រមទាំងមានបទពិសោធន៍នៅក្នុងវិស័យច្បាប់នេះផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ លើប្រធានបទស្តីពី របបនៃការប្រកាសទោស នេះយើងខ្ញុំបានបែងចែក និងផ្តោតសំខាន់ទៅលើ ៣ ជំពូកធំៗដូចជា៖

**ជំពូកទី១៖ របបទូទៅនៃការប្រកាសទោសព្រហ្មទណ្ឌ**

**ជំពូកទី២៖ របបទូទៅនៃការប្រកាសព្យួរទោស**

**ជំពូកទី៣៖ យន្តការសំខាន់ៗនៃរបបនៃការប្រកាសទោស។**

# ជំពូកទី១៖
# របបទូទៅនៃការប្រកាសទោស
# ព្រហ្មទណ្ឌ

# ជំពូកទី១

# របបទូទៅនៃការប្រកាសទោសព្រហ្មទណ្ឌ

## និយមន័យ

មុននឹងឈានទៅដល់ការបកស្រាយ យើងត្រូវយល់អំពីនិយមន័យ **"អ្វីទៅជារបបនៃការប្រកាសទោសព្រហ្មទណ្ឌ"** ជាមុនសិន។ យោងតាមសទ្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែកក្រមព្រហ្មទណ្ឌនៃគណៈកម្មការបណ្ឌិត្យសភា ទទួលបន្ទុកអនុម័តពាក្យច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី បោះពុម្ពលើកទី១ ឆ្នាំ២០១១ លេខរៀងទី១១ បានកំណត់យ៉ាងច្បាស់អំពីខ្លឹមសារ ឬអត្ថន័យនៃពាក្យថា **"ការប្រកាសទោស"** គឺជាការប្រកាសដោយតុលាការនូវទោសណាមួយដើម្បីអាចយកទោសនោះមកអនុវត្តបាន។ ចំណែកឯពាក្យថា **"របប"** គឺសំដៅទៅលើការរៀបចំអ្វីមួយឲ្យមាននូវសណ្តាប់ធ្នាប់ ឬរបៀបរៀបរយ[1]។

ស្របតាមវិធីបំបែកន័យខាងលើនេះ យើងអាចឲ្យនិយមន័យរួមបានថា **"របបនៃការប្រកាសទោសព្រហ្មទណ្ឌ"** គឺជាការរៀបចំនៃការសម្រេចនៅក្នុងការផ្តន្ទាទោសព្រហ្មទណ្ឌ (ទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់) ចំពោះបុគ្គលដែលបានប្រព្រឹត្តនូវអំពើណាមួយដែលច្បាប់ហាមឃាត់ ដោយឲ្យបុគ្គលនោះអនុវត្តនូវទោសទាំងឡាយដែលតុលាការបានប្រកាសចំពោះគាត់។ បន្តទៅនេះយើងនឹង ធ្វើការបែងចែកចេញជាចំណុចសំខាន់ៗមួយចំនួនទៀតដូចខាងក្រោម ៖

## ផ្នែកទី១. គោលការណ៍មូលដ្ឋានរួមនៅក្នុងរបបនៃការប្រកាសទោស

មុននឹងឈានទៅដល់ការបកស្រាយអំពីគោលការណ៍នីមួយៗ យើងត្រូវយល់អំពីនិយមន័យនៃពាក្យរបបនៃការប្រកាសទោសព្រហ្មទណ្ឌជាមុនសិន។ ពាក្យថា **ការប្រកាសទោស** គឺជាការប្រកាសទោសណាមួយដោយតុលាការ ដើម្បីអាចយកទោសនោះមកអនុវត្តបាន។[2] ចំណែកឯពាក្យថា **របប** គឺសំដៅទៅលើការរៀបចំអ្វីមួយឲ្យមាននូវសណ្តាប់ធ្នាប់ ឬរបៀបរៀបរយ។ ដូចនេះយើងអាចឱ្យនិយមបានថា **របបនៃការប្រកាសទោសព្រហ្មទណ្ឌ** គឺជាការរៀបចំនៃការសម្រេចក្នុងការផ្តន្ទាទោសព្រហ្មទណ្ឌ (ទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់) ចំពោះបុគ្គលដែលបានប្រព្រឹត្តនូវអំពើណាមួយដែលច្បាប់ហាមឃាត់ ដោយឲ្យបុគ្គលនោះអនុវត្តនូវទោសទាំងឡាយដែលតុលាការបានប្រកាសចំពោះគាត់។

ដោយអនុលោមតាមមាត្រា ៣ នៃក្រមព្រហ្មទណ្ឌ បានបញ្ញត្តិថាមានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌ

[1] យោងតាមវចនានុក្រមខ្មែររបស់ព្រះសង្ឃរាជ្យ **ជួន ណាត** បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត ក្នុងព.ស២៥១១ និងគ.ស១៩៦៧ ទំព័រ១០២២

[2] សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ លេខរៀងទី១១

បាន ពោលគឺមានតែទោសដែលមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌដែលបានចូលជាធរមាននៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះទើបអាចប្រកាសទោសបាន។[3] ដូចនេះអាចសបញ្ជាក់ឲ្យឃើញថា ប្រសិនបើសកម្មភាពណាមួយមិនត្រូវបានចាត់ទុកជាបទល្មើសដូចដែលក្រមព្រហ្មទណ្ឌបានបញ្ញត្តិនោះទេ គឺតុលាការមិនអាចប្រកាសទោសចំពោះសកម្មភាពនោះបានឡើយ។

**ឧទាហរណ៍៖** លោក **ក** និងនារី **ខ** ជាមិត្តនឹងគ្នា ហើយលោក ក បានចាប់ចិត្តលួចស្រលាញ់លើនារី **ខ**។ ចំពោះសកម្មភាពនេះនៅក្នុងច្បាប់ព្រហ្មទណ្ឌមិនបានបញ្ញត្តិថាជាការប្រព្រឹត្តបទល្មើសទេ ដូចនេះសកម្មភាពរបស់លោក **ក** គឺគ្មានទោសឡើយ។ ប៉ុន្តែដោយមានចិត្តស្រលាញ់ជាពន់ពេកលោក **ក** ក៏បានចាប់រំលោភនារី **ខ** នោះបានសម្រេច។ ចំពោះសកម្មភាពនេះ គឺមានចែងនៅក្នុងបទប្បញ្ញត្តិច្បាប់នៃក្រមព្រហ្មទណ្ឌ មាត្រា ២៣៩ បទរំលោភសេពសន្ថវៈ ដូចនេះតុលាការអាចប្រកាសទោស និងអនុវត្តទោសលើសកម្មភាពលោក **ក** បាន។

ហេតុដូចនេះក្រមព្រហ្មទណ្ឌ បានចែងនូវគោលការណ៍សំខាន់ៗចំនួន ២ (ពីរ) គឺ **គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ** ដែលមានចែងនៅក្នុងមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ និង**គោលការណ៍ឯកត្តកម្មនៃទោស** ដែលមានចែងក្នុងមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ។ ក្រមព្រហ្មទណ្ឌចែងនូវគោលការណ៍នេះ គឺដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់ចៅក្រមយកទៅប្រើប្រាស់ក្នុងការកំណត់អំពីទោសឱ្យបានត្រឹមត្រូវទៅតាមស្ថានភាពរបស់បុគ្គលដែលបានប្រព្រឹត្តបទល្មើស និងដើម្បីធ្វើឱ្យការប្រកាសទោសប្រកបដោយភាពយុត្តិធម៌។[4] ជាបន្តទៀតនេះ យើងសូមពន្យល់បកស្រាយឱ្យកាន់តែយល់ច្បាស់អំពីគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ(**១.១**) និងគោលការណ៍ឯកត្តកម្មនៃទោស(**១.២**)។

## កថាខណ្ឌទី១៖ គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិព្រហ្មទណ្ឌ គឺជាបទដ្ឋានគតិយុត្តចែងកំណត់អំពីការដាក់ទណ្ឌកម្មរាល់បុគ្គលណាដែលបានប្រព្រឹត្តអំពើនាំឲ្យប៉ះពាល់ដល់ប្រយោជន៍បុគ្គល ឬសាធារណៈ និងសណ្តាប់ធ្នាប់សង្គម។ រាល់បុគ្គលទាំងឡាយណាដែលប្រព្រឹត្តអំពើល្មើសផ្ទុយពីច្បាប់បានកំណត់ បុគ្គលនោះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ។

ផ្អែកតាមក្រមព្រហ្មទណ្ឌ **ការទទួលខុសត្រូវព្រហ្មទណ្ឌ** គឺជាការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។[5] នៅក្នុងន័យនេះបានសេចក្តីថា បើជនណាជាអ្នកប្រព្រឹត្តបទល្មើសដែលផ្ទុយនឹងច្បាប់

[3] មាត្រា ៣ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[4] យោងតាមអនុសាសន៍របស់ ឯកឧត្តម កើត រិទ្ធ អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ (បច្ចុប្បន្នជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌) នៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា។

[5] មាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

ជននោះនឹងត្រូវទទួលទោសទណ្ឌកម្មតាមច្បាប់បានកំណត់ទៅតាមអំពើប្រព្រឹត្តរបស់ខ្លួនដោយមិនអាចផ្ទេរឲ្យអ្នកដទៃ ឬសាច់ញាតិរបស់ខ្លួនទទួលខុសត្រូវព្រហ្មទណ្ឌជំនួសបានឡើយ។

**ឧទាហរណ៍៖** បុរសឈ្មោះ **គ** មានគំនុំជាមួយនឹងបុរសឈ្មោះ **ខ** ដោយមានចិត្តខឹងជាខ្លាំង លោក **គ** បានយកកូនកាំបិតចាក់ទៅលើលោក **ខ** បណ្តាលឱ្យស្លាប់ភ្លាមៗ។ ដូចនេះលោក **គ** ត្រូវទទួលខុសត្រូវចំពោះអំពើល្មើសដែលខ្លួនបានប្រព្រឹត្តមួយនេះ។

ផ្ទុយទៅវិញប្រសិនបើច្បាប់មិនបានកំណត់បែបនេះទេ ជនដែលបានប្រព្រឹត្តបទល្មើសមិនមានការខ្លាចរអានឹងច្បាប់ឡើយ គឺគាត់អាចនឹងមិនកែខ្លួន ហើយបន្តប្រព្រឹត្តបទល្មើសម្តងហើយម្តងទៀត។ ហេតុដូច្នេះទើបក្រមព្រហ្មទណ្ឌបានកំណត់ជាដាច់ខាត គឺមិនអនុញ្ញាតអោយមានអ្នកទទួលទោសជំនួសចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសនោះទេ សូម្បីតែការបង់ប្រាក់ពិន័យក៏មិនអាចអោយអ្នកដទៃ ឬសាច់ញាតិបង់ជំនួសបានឡើយ។ ម្យ៉ាងវិញទៀតគោលការណ៍នេះចែងមក គឺមានគោលបំណងធ្វើអោយជនដែលបានប្រព្រឹត្តខុសនោះបានទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន និងមានការខ្លាចរអានឹងច្បាប់ហើយធ្វើការកែប្រែខ្លួនអោយល្អឡើងវិញនៅក្នុងសង្គមជាតិ។ ដោយឡែក ចំពោះសំណងខូចខាតវិញ ជនរងគ្រោះ ឬសាច់ញាតិជនរងគ្រោះអាចធ្វើការទាមទារបានដោយផ្អែកលើអំពើអនីត្យានុកូលដែលបានបញ្ញត្តិនៅក្នុងក្រមនីតិរដ្ឋប្បវេណី។

## កថាខណ្ឌទី២៖ គោលការណ៍ឯកត្តកម្មនៃទោស

ជាការពិតណាស់ មុននឹងធ្វើការសម្រេចអំពីការផ្តន្ទាទោសលើបទល្មើសនីមួយៗ តុលាការចាំបាច់សិក្សាពីមូលហេតុ និងកត្តាដែលជំរុញនាំឱ្យមានបទល្មើស និងកិរិយាមាយាទក្រោយពេលប្រព្រឹត្តបទល្មើស ដោយគោរពនឹងភាពមិនរើសអើង និងស្មើភាពគ្នា ភាពសមាមាត្រនៃទោស និងគោលការណ៍ដោយឡែកដោយផ្អែកលើស្ថានភាពប្រែប្រួលរបស់ជនល្មើសនីមួយៗ។ ចំពោះ **គោលការណ៍ឯកត្តកម្មនៃទោស** គឺជាគោលការណ៍ដែលត្រូវបានបង្កើតឡើងទុកជាមូលដ្ឋានគ្រឹះសម្រាប់ចៅក្រមជំនុំជម្រះពិចារណាទៅតាមស្ថានភាពរបស់បុគ្គលម្នាក់ៗដែលបានប្រព្រឹត្តបទល្មើស ដើម្បីឈានទៅដល់ការប្រកាសទោសព្រហ្មទណ្ឌ។[6] តួយ៉ាង តុលាការអាចធ្វើការប្រកាសទោសបាន គឺត្រូវពិចារណាដោយផ្អែកទៅលើស្ថានភាពមុននិងក្រោយការប្រព្រឹត្តបទល្មើសរបស់ជនល្មើស កាលៈទេសៈនៃបទល្មើស បុគ្គលិកលក្ខណៈនៃជនជាប់ចោទ សភាពផ្លូវចិត្តនៃជនល្មើស ទំហំព្យសនកម្មដែលជនល្មើសបង្កដល់ជនរងគ្រោះ ឬសង្គមជាតិ ព្រមទាំងកិរិយាមាយាទរបស់ជនល្មើសជាអាទិ៍។ ផ្ទុយទៅវិញបើការប្រកាសទោសពុំបានឆ្លងកាត់ការវិនិច្ឆ័យដោយគោរពតាមគោលការណ៍ឯកត្តកម្មនៃទោសទេ ការជំនុំជម្រះទោសនឹងនាំឱ្យមានភាពលំអៀង និងអយុត្តិធម៌ ឬអាចឈានដល់ការប្តឹងសុំមោឃភាពនីតិវិធីផងដែរ។ លើសពី

[6] មាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

នេះទៅទៀត គោលការណ៍នេះក៏ជាមូលដ្ឋានសំខាន់ពាក់ព័ន្ធនឹងរបបទូទៅនៃការប្រកាសទោសរបស់តុលាការ ពោលគឺ ត្រូវប្រកាសទោសដោយគោរពគោលការណ៍ឯកត្តកម្មនៃទោសដែលអាចឱ្យចៅក្រមធ្វើការពិចារណាក្នុងការសម្រេចលើ ការប្រកាសមូលទោស ការប្រកាសទោសជំនួស ការប្រកាសទោសបន្ថែមលើមូលទោស ការប្រកាសទោសការងារសហគមន៍ ការព្យួរទោសធម្មតា ការព្យួរទោសសាកល្បង របបពាក់កណ្ដាលសេរីភាព និងការបែងចែកទោសជាប្រភាគជាអាទិ៍។

## ផ្នែកទី២៖ ការប្រកាសទោសព្រហ្មទណ្ឌទៅលើប្រភេទនៃទោសនីមួយៗចំពោះរូបវន្តបុគ្គល

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ទោសជា ៣ (បី) ប្រភេទសម្រាប់រូបវន្តបុគ្គលគឺ **មូលទោស ទោសបន្ថែម** និង**ទោសជំនួស**។ ពាក្យថា **រូបវន្តបុគ្គល** គឺសំដៅដល់បុគ្គលដែលមានរូប មានសាច់មានឈាម ជារួមគឺសំដៅដល់មនុស្សគ្រប់រូបម្នាក់ៗហ្នឹងឯង។[7] យ៉ាងណាមិញ នៅក្នុងការសម្រេចនូវទោសទាំងឡាយគឺត្រូវការពិចារណាច្រើនទៅលើចំណុចនីមួយៗ ព្រោះថាទោសដែលបានប្រកាសពុំសុទ្ធតែមានលក្ខណៈដូចគ្នាឡើយ ចំណែកឯលក្ខខណ្ឌនៃទោសក៏ដូច្នោះដែរ។ ជាក់ស្ដែងដូចជា មូលទោស គឺមានតែទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ បើយើងក្រឡេកមើលទៅលើទោសបន្ថែមឃើញថា គឺជាការបន្ថែមទោសមួយ ឬច្រើនទៅលើមូលទោស។ ចំណែកឯទោសជំនួសវិញ ឃើញថាជាការយកនូវទោសការងារសហគមន៍ ឬមួយក៏ទោសស្ដីបន្ទោសជំនួសឱ្យមូលទោស។

### កថាខណ្ឌទី១៖ ការប្រកាសមូលទោស

**មូលទោស** គឺជាទោសមូលដ្ឋាន ដែលយកទៅប្រើប្រាស់សម្រាប់ការប្រកាសទោសចំពោះជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើស។ មូលទោស ត្រូវបានបែងចែកជា ២ ប្រភេទគឺ ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ហើយការពិន័យត្រូវគិតជាប្រាក់រៀល។[8] មួយវិញទៀត មូលទោស គឺសំដៅដល់ទោសសំខាន់ចម្បងជាងគេដែលតុលាការអាចប្រកាសទោសតែឯង ដើម្បីផ្ដន្ទាទោសចំពោះបទល្មើសណាមួយ។

**ទោសដាក់ពន្ធនាគារ** គឺជាទោសដែលត្រូវបំបាត់ស្ទើរតែអស់នូវសេរីភាពជាមូលដ្ឋាន ដោយមានកំណត់កាល។ ស្របគ្នានឹងនេះផងដែរ នៅក្នុងការកំណត់ពីទោសដាក់ពន្ធនាគារ ច្បាប់កម្ពុជាតែងតែកំណត់អំពីកម្រិតអប្បបរមានៃទោស និង កម្រិតអតិបរមានៃទោស។[9] បន្ថែមពីនេះទៅទៀត ទោសដាក់ពន្ធនាគារអាចជា ទោសដាក់ពន្ធនាគារអស់មួយជីវិត ឬជាទោសដាក់ពន្ធនាគារមានរយៈពេល។[10] ចំពោះទោសដាក់ពន្ធនាគារមានរយៈពេល គឺអាចជាទោសដាក់ពន្ធនាគារមានរយៈពេលចាប់ពី ១ (មួយ) ថ្ងៃ រហូតដល់ ៣០ (សាមសិប) ឆ្នាំ។

---

[7] ដកស្រង់ចេញអំពីសៀវភៅស្ដីពី " រូបវន្តបុគ្គល " ឆ្នាំ២០១២ រៀបរៀងដោយលោកសាស្ត្រាចារ្យ កៅ សីហា

[8] មាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[9] មាត្រា ៤៤ (កថាខណ្ឌទី១) នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[10] ដកស្រង់ចេញអំពីសៀវភៅ "នីតិព្រហ្មទណ្ឌ" របស់លោកសាស្ត្រាចារ្យ នុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត

ដោយទោសដាក់ពន្ធនាគារ ១ (មួយ) ថ្ងៃ ត្រូវគិត ២៤ (ម្ភៃបួន) ម៉ោង ទោសដាក់ពន្ធនាគារ ១ (មួយ) ខែ ត្រូវគិត ៣០ (សាមសិប) ថ្ងៃ ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមចំនួនថ្ងៃជាក់ស្តែងដែលមាននៅក្នុងខែនោះ ចំណែកឯទោសដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំ ត្រូវគិត ១២ (ដប់ពីរ) ខែ។[11] កាលបើទណ្ឌិតបានទទួលរងទោសនៅក្នុងពន្ធនាគារចប់សព្វគ្រប់តាមថិរវេលាដូចបានកំណត់នៅក្នុងសេចក្តីសម្រេចផ្តន្ទាទោសហើយ ទណ្ឌិតនឹងត្រូវដោះលែងឱ្យមានសេរីភាពវិញ ប៉ុន្តែប្រសិនបើទោសរបស់ទណ្ឌិតនោះត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬបទដ្ឋានគតិយុត្តបានកំណត់ត្រូវតែដោះលែងឱ្យមានសេរីភាពវិញនៅមុនថ្ងៃឈប់សម្រាកនោះ។

ចំពោះ **ទោសពិន័យជាប្រាក់** សំដៅលើទោសដែលតម្រូវឱ្យទណ្ឌិតបង់ចំនួនប្រាក់កំណត់ដោយ តុលាការ។ គួរបញ្ជាក់ផងដែរថា ប្រាក់ជាផលនៃពិន័យត្រូវគិតជាប្រាក់រៀលទៅទុកតម្កល់នៅក្នុងរតនាគារជាតិ ។ ផ្អែកតាមក្រមព្រហ្មទណ្ឌ ការប្រកាសមូលទោសចំពោះរូបវន្តបុគ្គលគឺបែងចែកជា ២ (ពីរ) ប្រភេទទៀត ដែលយើងនឹងធ្វើការបកស្រាយដូចតទៅ៖ ការប្រកាសមូលទោសទៅលើរូបវន្តបុគ្គលជានីតិជន **(១.១)** និងការប្រកាសមូលទោសទៅលើរូបវន្តបុគ្គលជាអនីតិជន **(១.២)** ។

### ១.១ ការប្រកាសមូលទោសទៅលើរូបវន្តបុគ្គលជានីតិជន

អនុលោមតាមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌបានបញ្ញត្តិថា នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបាន កំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ។ មានន័យថា នីតិជនមានភាពពេញលេញក្នុងការទទួលខុស ត្រូវព្រហ្មទណ្ឌដែលខ្លួនបានប្រព្រឹត្តបទល្មើស។ នៅក្នុងករណីដែលនីតិជនប្រព្រឹត្តបទល្មើសត្រូវផ្តន្ទាទោស ដាក់ពន្ធនាផង និង ពិន័យជាប្រាក់ផង តុលាការអាចប្រកាស ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬ ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ។

ឧទាហរណ៍៖ លោក **ក** មានអាយុ២៣ ឆ្នាំ បានប្រព្រឹត្តបទល្មើសហិង្សាដោយចេតនាទៅលើលោក **ខ** បណ្តាលឱ្យលោក **ខ** រងរបួសយ៉ាងធ្ងន់ធ្ងរ។ ក្នុងករណីនេះ លោក **ក** ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌយ៉ាងពេញលេញចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។

### ១.២ ការប្រកាសមូលទោសទៅលើរូបវន្តបុគ្គលជាអនីតិជន

ដោយឡែក អនីតិជន គឺជាជនដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ឬជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។ ម្យ៉ាងទៀត អនីតិជន គឺជាជនដែលច្បាប់មិនទាន់ឱ្យទទួលខុសត្រូវលើអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ឬជាជនដែលច្បាប់កំណត់ឱ្យទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្ត តែការទទួលខុសត្រូវនោះគឺមានកម្រិត។

[11] មាត្រា ៤៩ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

ឧទាហរណ៍៖ កុមារា **ក** មានអាយុ ១៦ឆ្នាំ បានយកកាំបិតចាក់សម្លាប់កុមារា **ខ** បណ្តាលឱ្យស្លាប់បាត់បង់ជីវិតនៅកន្លែងកើតហេតុភ្លាមៗ។ នៅក្នុងករណីនេះ តុលាការអាចប្រកាសទោសទៅលើកុមារា **ក** ដោយធ្វើការពិចារណាទៅតាមកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។

អាស្រ័យហេតុនេះ ក្រមព្រហ្មទណ្ឌបានបែងចែកទោសដែលអាចប្រកាសចំពោះអនីតិជនដែលមាន អាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ចេញជា ២ ប្រភេទផ្សេងទៀត គឺអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ **(ក)** និងអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ **(ខ)**។

### ក. អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ

អនីតិជនប្រភេទនេះ គឺមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ មានន័យថាតុលាការមិនអាចសម្រេចផ្តន្ទាទោសទៅលើអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំឡើយ សូម្បីតែការចោទប្រកាន់ទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌក៏មិនអាចចោទប្រកាន់ទៅលើអនីតិជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំផងដែរ។ តាមគោលគំនិតរបស់ច្បាប់បានចាត់ទុកអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ជាជនដែលគ្មានសមត្ថភាពក្នុងការយល់ដឹងតែមួយគត់ក្នុងការវិនិច្ឆ័យ និងបានច្រានចោលនូវហេតុផ្សេងៗទៀត តាមកាលៈទេសៈនៃបទល្មើស បុគ្គលិកលក្ខណៈរបស់អនីតិជន ដែលជាហេតុនាំឱ្យអនីតិជនក្រោមអាយុ ១៤ (ដប់បួន) ឆ្នាំ មិនទទួលខុសត្រូវព្រហ្មទណ្ឌ ទោសក៏មិនអនុវត្ត ការឃាត់ខ្លួនក៏មិនអាចធ្វើបាន ការឃុំខ្លួនក៏មិនអាចធ្វើបាន។ ហេតុនេះចៅក្រមមិនប្រកាសអំពីទោសព្រហ្មទណ្ឌទេ បានន័យថាមិនសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់ឡើយ ពោលគឺចៅក្រមអាចប្រើប្រាស់នូវយន្តការផ្សេងៗដូចជាទាក់ទងនឹងវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ដោយយោងតាមមាត្រា ៣៩ មាត្រា ៤០ និងមាត្រា ៤១ ដែលចែងអំពីរបបគតិយុត្តពិសេសទាក់ទងជាមួយនឹងអនីតិជន។

បន្ថែមពីនេះទៀត អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនត្រូវកំណត់យកអាយុនៅពេលដែលអនីតិជននោះប្រព្រឹត្តបទល្មើស។[12] ចំពោះភ័ស្តុតាងបញ្ជាក់នៃអាយុរបស់អនីតិជនត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងទៀតដែលអាចបញ្ជាក់បានអំពីកំណើត។ ក្នុងករណីពុំមានឯកសារ ឬមានការសង្ស័យឬមិនមានភាពច្បាស់លាស់ទាក់ទងនឹងយថាភូតឯកសារនោះ ភ័ស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន។ អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វះស្វែងរកភ័ស្តុតាង ដើម្បីកំណត់អាយុរបស់អនីតិជនឲ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន។

[12] មាត្រា ៧ នៃច្បាប់ស្តីពី យុត្តិធម៌អនីតិជន, នស/រកម/០៧១៦/០០៩, ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦

### ខ.អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ

ជាទូទៅរាល់អនីតិជនដែលមានអាយុពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលបានប្រព្រឹត្តបទល្មើសទាំងអស់ គឺតុលាការអាចសម្រេចដាក់ទោសត្រឹមតែជា វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភតែប៉ុណ្ណោះ ដែលមានដូចជា៖

- ការប្រគល់អនីតិជនឲ្យទៅឪពុកម្ដាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬ បុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសាកសមនឹងទំនុកចិត្ត។
- ការប្រគល់អនីតិជនឲ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។
- ការប្រគល់អនីតិជនឲ្យទៅអង្គការឯកជន ដែលមាននីតិសម្បទានៅក្នុងការទទួលអនីតិជន។
- ការប្រគល់អនីតិជនឲ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកជន។
- ការដាក់អនីតិជនឲ្យស្ថិតនៅក្រោមការការពាររបស់តុលាការ ត្រង់ន័យនេះមានន័យថា តុលាការត្រូវចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជននោះ។ បន្ទាប់មក បុគ្គលនោះត្រូវធ្វើរបាយការណ៍ស្ដីពីកិរិយាមារយាទរបស់អនីតិជនឲ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បន្ថែមពីនេះទៀត បុគ្គលនោះត្រូវផ្ដល់ព័ត៌មានដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឲ្យមានការកែប្រែនូវវិធានការណ៍នេះ។

ផ្ទុយទៅវិញ ប្រសិនបើតុលាការយល់ឃើញថា កាលៈទេសៈរបស់បទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវឲ្យអនីតិជនទទួលខុសត្រូវព្រហ្មទណ្ឌនោះ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនមិនអាចស្ថិតនៅលើគោលការណ៍ស្មើភាពដូចនីតិជនទេ។

## កថាខណ្ឌទី២៖ ការប្រកាសទោសបន្ថែម

ទោសបន្ថែម មានន័យថាជាការបន្ថែមនូវទោសមួយ ឬ ច្រើនទៅលើមូលទោស ឬគេអាចនិយាយម្យ៉ាងទៀតថា ជាទោសដែលតុលាការយកមកប្រើក្នុងការប្រកាសទៅលើមូលទោស ដោយសំដៅដល់ទោសដែលត្រូវដាក់បញ្ចូល ឬដាក់ជំនួសក្នុងមូលទោស។ ទោសបន្ថែម ត្រូវបានបង្កើតឡើងក្នុងគោលបំណងកម្រិតនូវទណ្ឌកម្មឱ្យសមស្របទៅតាមបទល្មើសដែលបានប្រព្រឹត្តជាក់ស្ដែង ដើម្បីធានាដល់ការអនុវត្ត ហៅថាគោលការណ៍ឯកត្តកម្មនៃទោស។

ដោយផ្អែកតាមលក្ខខណ្ឌនៃការប្រកាសទោស ក្នុងមាត្រា ៥៤ និង មាត្រា ១៦៩ នៃក្រមព្រហ្មទណ្ឌ ទោសបន្ថែមអាចចែកចេញជាពីរប្រភេទគឺ ៖

- ទោសបន្ថែមដែលអាចប្រកាសតាមជម្រើសរបស់ចៅក្រម
- ទោសបន្ថែមដែលត្រូវប្រកាសជាកាតព្វកិច្ច ។

យ៉ាងណាមិញ ទោសបន្ថែមអាចប្រកាសទោសបាន លុះត្រាតែទោសនោះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុដែលត្រូវចោទប្រកាន់។ ក្នុងករណីច្បាប់កំណត់ថា ទោសបន្ថែមត្រូវតែប្រកាសជាកាតព្វកិច្ចនោះតុលាការត្រូវតែប្រកាសទោសបន្ថែមជាដាច់ខាត[13]។

**២.១. ការប្រកាសទោសបន្ថែមទៅលើរូបវន្តបុគ្គលជានីតិជន**

ជាគោលការណ៍ ក្នុងការប្រកាសទោសបន្ថែម គឺអាចប្រកាសបានលុះត្រាតែត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលត្រូវចោទប្រកាន់។ ដូចនេះ នៅក្នុងបទប្បញ្ញត្តិនៃមាត្រា ៥៣ បានចែងអំពីប្រភេទនៃការប្រកាសទោសបន្ថែម គឺមានចំនួន ១៩ ចំណុច ដែលមានដូចខាងក្រោម៖

១. ការដកសិទ្ធិខ្លះជាពលរដ្ឋ។

២. ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ។

៣. ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ។

៤. ការព្យួរលិខិតបើកបរ។

៥. ការហាមឃាត់ចំពោះការស្នាក់នៅទីកន្លែងមួយចំនួន នៃព្រះរាជាណាចក្រកម្ពុជា។

៦. ការហាមឃាត់ចំពោះការចាកចេញពីដែនដី នៃព្រះរាជាណាចក្រកម្ពុជា។

៧. ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស។

៨. ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬ ដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស។

៩. ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

១០. ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

១១. ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុ ដែលលំអទីកន្លែង ដែលបទល្មើសត្រូវបានប្រព្រឹត្ត។

១២. ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត។

១៣. ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

១៤. ការបណ្តេញពីលទ្ធកម្មសាធារណៈ។

១៥. ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬ ប្រព្រឹត្តបទល្មើស។

[13] មាត្រា ៥៤ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

១៦.ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន។

១៧.ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស។

១៨. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

១៩.ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។

នៅគ្រប់ករណីទាំងអស់នេះ ចៅក្រមអាចធ្វើការជ្រើសរើសយកទោសបន្ថែមមួយ ឬ ច្រើនក្នុងចំណោម ១៩ ចំណុចនោះយកមកប្រកាស ដើម្បីបន្ថែមទៅលើមូលទោសបាន។ ជាទូទៅដើម្បីអាចប្រកាសទោសបន្ថែមបាន លុះត្រាតែទោសបន្ថែមនេះមានចែងយ៉ាងជាក់លាក់។

### ២.២. ការប្រកាសទោសបន្ថែមទៅលើរូបវន្តបុគ្គលជាអនីតិជន

ក្រៅពីទោសបន្ថែមដែលត្រូវប្រកាសទៅលើរូបវន្តបុគ្គលជានីតិជនមាន ១៩ ចំណុចនោះ ក្រមព្រហ្មទណ្ឌក៏បានធ្វើការបញ្ញត្តិនៅក្នុងមាត្រា ១៦១ នៃក្រមព្រហ្មទណ្ឌស្តីអំពី ទោសបន្ថែម។

#### ក. អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ

អនីតិជនប្រភេទនេះ ដោយសារតែច្បាប់មិនបានអនុញ្ញាតឱ្យប្រកាសនូវមូលទោសទៅលើគាត់រួចទៅហើយ ដូច្នេះទោសបន្ថែមក៏ដូចគ្នាដែរ គឺមិនអាចប្រកាសទៅលើគាត់បានទេ។ ពីព្រោះទោសបន្ថែម គឺជាទោសដែលត្រូវបានចៅក្រមសម្រេចបន្ថែមទៅលើមូលទោស ផ្ទុយទៅវិញបើគ្មានការប្រកាសមូលទោសទេស្មើនឹងគ្មានការប្រកាសទោសបន្ថែមដូចគ្នាដែរ។

#### ខ. អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ

កាលណាតុលាការគ្មានជម្រើសណាមួយក្រៅពីសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅបានទេ នោះតុលាការអាចសម្រេចប្រើប្រាស់នូវទោសបន្ថែមសម្រាប់អនីតិជនប្រភេទនេះបានដែរ។ លើសពីនេះទៅទៀតបច្ចេកទេសនៅក្នុងការប្រកាសទោសបន្ថែមនេះក៏ប្រើដូចនឹងវិធីសាស្ត្រក្នុងការប្រកាសទោសបន្ថែមសម្រាប់រូបវន្តបុគ្គលជានីតិជនផងដែរ។ ក៏ប៉ុន្តែមានភាពខុសគ្នានៅត្រង់ថាទោសបន្ថែមដែលអាចប្រកាសសម្រាប់អនីតិជនប្រភេទនេះមានត្រឹមតែ ៥ (ប្រាំ) ចំណុចតែប៉ុណ្ណោះ ដែលបានប្បញ្ញត្តិនៅក្នុងមាត្រា ១៦១ នៃក្រមព្រហ្មទណ្ឌ។

ចំពោះទោសបន្ថែមដែលអាចអនុវត្តចំពោះអនីតិជនបាន៖

១. ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស។

២. ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

៣. ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

៤. ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។

៥. ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទ។

**កថាខណ្ឌទី៣៖ ការប្រកាសទោសជំនួស**

ទោសជំនួស ជាទោសការងារសហគមន៍ ឬការស្តីបន្ទោស (ទោសស្តីបន្ទោស) ដែលត្រូវបានកំណត់ថាជាទោសជំនួសដាក់ពន្ធនាគារ។ តុលាការដែលប្រកាសការងារសហគមន៍ ឬការស្តីបន្ទោស មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬ ពិន័យជាប្រាក់បានទេ។

**៣.១ ការប្រកាសទោសការងារសហគមន៍**

ការប្រកាសទោសការងារសហគមន៍បាន លុះត្រាតែជនជាប់ចោទមានវត្តមាននាពេលសវនាការ ហើយយល់ព្រមធ្វើការងារនោះ ដោយតុលាការត្រូវប្រាប់សាមីខ្លួនថាមានសិទ្ធិប្រកែក (ចម្លើយត្រូវចុះក្នុងសេចក្តីសម្រេច) ហើយតុលាការត្រូវកំណត់ពីថិរវេលា តែមិនអាចលើសពី ១ឆ្នាំ ទេ (៣០ម៉ោង ទៅ ២០០ម៉ោង) និងមានព្រះរាជអាជ្ញាជាអ្នកដែលត្រូវកំណត់បែបបទនៃការអនុវត្តទោស និងចង្អុលបង្ហាញនីតិបុគ្គលដែលត្រូវទទួលផលប្រយោជន៍។

**ក.ការប្រកាសទោសការងារសហគមន៍ទៅលើរូបវន្តបុគ្គលជានីតិជន**

ចំពោះទោសការងារសហគមន៍ គឺជាទោសមួយដែលគេតម្រូវឱ្យធ្វើការងារជាប្រយោជន៍រួមមួយ ដោយគ្មានកម្រៃនោះទេ ក៏ប៉ុន្តែជាប្រយោជន៍សម្រាប់នីតិបុគ្គលមួយ។ ហើយទោសនេះអាចអនុវត្តទៅបាន គឺអាស្រ័យទៅតាមលក្ខខណ្ឌដូចមានចែងនៅក្នុងបទប្បញ្ញត្តិចាប់ពីមាត្រា ៧២ ដល់មាត្រា ៧៤ ក៏ដូចជាមាត្រា ៩៨ និងចាប់ពីមាត្រា ១០១ ទៅដល់មាត្រា ១០៣ ផងដែរ។ ក្នុងករណីនេះបើសិនជាយើងពិនិត្យទៅលើលក្ខខណ្ឌរបស់ទោសនេះ យើងឃើញមានមាត្រា ៧២ បានផ្តល់ជាលក្ខខណ្ឌរួមថា កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬស្មើ នឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសទោសការងារសហគមន៍បាន។

**ខ. ការប្រកាសទោសការងារសហគមន៍ទៅលើរូបវន្តបុគ្គលជាអនីតិជន**

ផ្សេងអំពីមាត្រា ៧២ ស្តីពីនិយមន័យនៃការងារសហគមន៍ ដែលត្រូវយកទៅអនុវត្តចំពោះរូបវន្តបុគ្គលជានីតិជននោះ។ មាត្រា ១៦២ ក៏មានចែងអំពីទោសការងារសហគមន៍ផងដែរ ក៏ប៉ុន្តែមាត្រាក្រោយមួយនេះគឺប្រើសម្រាប់យកទៅប្រកាសនូវទោសការងារសហគមន៍ទៅលើរូបវន្តបុគ្គលជាអនីតិជនប៉ុណ្ណោះ។ ដូច្នេះដើម្បីដឹងច្បាស់ថាទោសការងារសហគមន៍ចំពោះនីតិជន និងអនីតិជនខុសប្លែកគ្នាបែបណានោះ យើងនឹងធ្វើការបកស្រាយដូចតទៅ៖

**ខ.១ អនីតិជនដែលមានអាយុក្រោម១៦ ឆ្នាំ**

មិនត្រឹមតែមូលទោស និងទោសបន្ថែមដែលតុលាការមិនត្រូវប្រកាសចំពោះអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំប៉ុណ្ណោះទេ។ សូម្បីតែទោសការងារសហគមន៍នេះក៏ក្រមព្រហ្មទណ្ឌមិនបានបើកសិទ្ធិអំណាចឲ្យ ចៅក្រមជំនុំជម្រះធ្វើការប្រកាសទោសប្រភេទនេះទៅលើអនីតិជនដែលមានអាយុមិនទាន់គ្រប់១៦ (ដប់ប្រាំមួយ) ឆ្នាំផងដែរ។ ត្រង់ចំណុចនេះខុសគ្នាត្រង់អាយុបន្តិចពីព្រោះនៅប្បញ្ញត្តិមុនៗ ដែលច្បាប់កំណត់ក្នុងការប្រកាសមូលទោស និងទោសបន្ថែមទៅលើរូបវន្តបុគ្គលជាអនីតិជន គឺមានត្រឹមតែអាយុក្រោម ១៤ (ដប់បួន) ឆ្នាំតែប៉ុណ្ណោះ។ ប៉ុន្តែករណីពិសេសនេះ បើកាលណាអនីតិជនដែលមានអាយុក្រោម ១៦ (ដប់ប្រាំមួយ)ឆ្នាំនោះចៅក្រមគ្មានសិទ្ធិនៅក្នុងការប្រកាសនូវទោសការងារសហគមន៍បានទេ ។

**ខ.២ អនីតិជនដែលមានអាយុយ៉ាងតិច ១៦ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ**

បើយោងទៅតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌត្រង់មាត្រា ១៦២ អនីតិជនដែលអាចប្រើប្រាស់នូវទោសការងារសហគមន៏នេះបាន លុះត្រាតែអនីតិជននោះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ)ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ។ ចំពោះថិរវេលាដែលអាចឱ្យអនីតិជននោះធ្វើការងារមិនអាចឱ្យលើសពី ១០០ (មួយរយ) ម៉ោងទេ បានសេចក្តីថាថិរវេលានៃទោសការងារសហគមន៍ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ច្បាប់កំណត់ត្រឹមពាក់កណ្តាលនៃថិរវេលារបស់នីតិជន។ មួយទៀត គឺត្រូវជ្រើសរើសការងារមួយដែលសមស្របសម្រាប់អនីតិជននោះ ពិសេសគឺស្ថានភាពរបស់អនីតិជនដែលទាក់ទងនឹងការបណ្តុះបណ្តាល និងស្ថានភាពដែលអនុញ្ញាតឲ្យកែសម្រួលអនីតិជនកែប្រែ អប់រំ អនីតិជននោះឱ្យចូលទៅរួមរស់នៅក្នុងសង្គមវិញ។

**៣.២. ការប្រកាសទោសស្ដីបន្ទោស**

ចំពោះទោសស្តីបន្ទោសវិញម្តង គឺការស្តីបន្ទោសមានចែងតែមួយគត់នៅក្នុងបទប្បញ្ញត្តិនៃ **មាត្រា៧៦** ដែលបានចែងយ៉ាងជាក់លាក់តែម្តងអំពីលក្ខខណ្ឌរបស់វា និងចែងពីការប្រកាសនូវទោសស្តីបន្ទោសចំពោះរូបវន្តបុគ្គលទាំងពីរប្រភេទ។

**ក. លក្ខខណ្ឌដើម្បីប្រកាសទោសស្តីបន្ទោស**

កាលណាបើជនជាប់ចោទបានរងទោសដាក់ពន្ធនាគារដែរ អតិបរមាតិចជាងឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសការស្តីបន្ទោសបានប្រសិនបើមានគ្រប់ដូចលក្ខខណ្ឌទាំង ៣ (បី) ខាងក្រោម ៖

**ក.១. ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើសបានបញ្ចប់**

បានន័យថាទោសស្តីបន្ទោសនេះ គឺធ្វើការប្រើប្រាស់សម្រាប់ស្ថានភាពបទល្មើសដែលមានលក្ខណៈមិនធ្ងន់ធ្ងរ ជាពិសេសពេលមានបទល្មើសរួចហើយ មតិសាធារណៈជនមិនសូវចាប់អារម្មណ៍ទេ ព្រោះបទល្មើស

នោះមិនសូវបានប៉ះពាល់ខ្លាំងក្លានោះទេ ដែលបណ្តាលឲ្យកើតមានចលាចលនៃបទល្មើសទៅដល់សណ្តាប់ធ្នាប់សាធារណៈតទៅទៀតទេដោយសារវាជាបទល្មើសមានចរិតលក្ខណៈតូចតាច។

**ក.២ ការខូចខាតត្រូវបានជួសជុលរួចហើយ**

ព្យសនកម្ម ឬស្មើសុំជួសជុលការខូចខាត ដូចជាចេញសងសំណងជំងឺចិត្តវិញជាដើម ឬការខូចខាតទាំងឡាយដែលចេញពីអំពើល្មើសរបស់ខ្លួន។

**ក.៣ ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ**

បានសេចក្តីថាគាត់បានបង្ហាញពីឆន្ទៈថាគាត់មានវិប្បដិសារីមានការសោកស្តាយចំពោះកំហុសដែលបានប្រព្រឹត្តបទល្មើសនោះ ហើយចំពោះការប្រព្រឹត្តទើបតែបានប្រព្រឹត្តនូវបទល្មើសលើកទី១ ដែលជាបទល្មើសលហុជាដើមហើយគាត់ធានាថាលើកក្រោយគាត់មិនប្រព្រឹត្តបែបនេះទៀតទេ ហើយគាត់ព្រមសុខចិត្តរៀនសូត្រដើម្បីអប់រំកែប្រែឬធ្វើសមាហរណកម្មចូលទៅរួមរស់នៅក្នុងសង្គម។

**ខ. ការប្រកាសនូវទោសស្តីពីបន្ធោសចំពោះរូបវន្តបុគ្គលទាំងពីរប្រភេទ**

ជារួមមកយើងឃើញថា ចំពោះរូបវន្តបុគ្គលទាំងពីរប្រភេទ គឺតុលាការអាចប្រកាសទោសចំពោះពួកគាត់បានដូចគ្នាប្រសិនបើលក្ខខណ្ឌគតិយុត្តពាក់ព័ន្ធនឹងការស្តីបន្ទោសត្រូវបានបំពេញតាមមាត្រា ៧៦ និងលើកលែងតែអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំចេញតែប៉ុណ្ណោះ ទើបមិនប្រកាសទោសទៅបាន។

## ផ្នែកទី ៣៖ ការប្រកាសទោសព្រហ្មទណ្ឌទៅលើប្រភេទនៃទោសនីមួយៗចំពោះនីតិបុគ្គល

គួរបញ្ជាក់ផងដែរ នីតិបុគ្គលត្រូវបានបែងចែកជា ២ (ពីរ) ប្រភេទគឺ នីតិបុគ្គលនៃនីតិសាធារណៈ ឬនីតិបុគ្គលដែលជារដ្ឋ**(១)** និងនីតិបុគ្គលនៃនីតិឯកជន ឬនីតិបុគ្គលដែលមិនមែនជារដ្ឋ**(២)**។

**កថាខណ្ឌទី ១៖ នីតិបុគ្គលនៃនីតិសាធារណៈ ឬ នីតិបុគ្គលដែលជារដ្ឋ**

នីតិបុគ្គលនៃនីតិសាធារណៈ គឺជាក្រុមមនុស្សដែលច្បាប់បានអនុញ្ញាតឲ្យធ្វើសកម្មភាពដូចជាបុគ្គលដើម្បីជាផលប្រយោជន៍សាធារណៈ ឬ អាចហៅម្យ៉ាងទៀតបានថាគឺជាស្ថាប័នដែលត្រូវបានបង្កើតឡើង និងគ្រប់គ្រងដោយច្បាប់សាធារណៈ ដែលមានសិទ្ធិអំណាចក្នុងការអនុវត្តកិច្ចការរដ្ឋបាល ។ នីតិបុគ្គលនៃនីតិសាធារណៈ មានដូចជា រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់) និងគ្រឹះស្ថានសាធារណៈ (គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈ រដ្ឋបាល និងឧស្សាហកម្ម-ពាណិជ្ជកម្ម)។ បើយោងតាមមាត្រា ៤២ នៃក្រមព្រហ្មទណ្ឌស្តីពី "**ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**" បានបញ្ញត្តិយ៉ាងជាក់ច្បាស់ណាស់ថា នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀតនីតិបុគ្គល លើក

លែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬ អ្នកតំណាងរបស់ខ្លួនដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។

យោងតាមឃ្លានេះបានបញ្ជាក់យ៉ាងច្បាស់ណាស់ថា រដ្ឋដែលជានីតិបុគ្គលនៃនីតិសាធារណៈគឺមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។

**កថាខណ្ឌទី ២៖ នីតិបុគ្គលនៃនីតិឯកជន ឬ នីតិបុគ្គលដែលមិនមែនជារដ្ឋ**

នីតិបុគ្គលនៃនីតិឯកជន គឺជាក្រុមមនុស្ស ឬ មូលនិធិដែលមានបុគ្គលភាពគតិយុត្តហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច ហើយស្ថិតក្រោមវិធានទាំងឡាយដែលគ្រប់គ្រងទំនាក់ទំនងគតិយុត្តរវាងបុគ្គលឯកជន និងបុគ្គលឯកជន ហើយមិនស្ថិតនៅក្រោមនីតិសាធារណៈទេ។ ដូច្នេះក្រៅពីរដ្ឋ នីតិបុគ្គលឯកជនមានដូចជា អង្គការ ក្រុមហ៊ុន សមាគមន៍ សហជីពពាងចក្រ ដែលជាប្រធាននៃបទល្មើសនៅក្នុងសង្គមស៊ីវិល្បត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ។ នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលបានប្រព្រឹត្តដោយអង្គការ ឬ អ្នកតំណាងរបស់ខ្លួនដើម្បីជាផលប្រយោជន៍របស់នីតិបុគ្គលនោះ។

គួរបញ្ជាក់ផងដែរការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលមិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌ ទោសដែលត្រូវយកមកប្រកាសទៅលើនីតិបុគ្គលគឺ មានតែ ២ (ពីរ) ប្រភេទប៉ុណ្ណោះ។ ដោយទោសទីមួយនោះគឺ **ទោសពិន័យជាប្រាក់ក្នុងឋានៈជាមូលទោស** ផ្អែកតាមមាត្រា ១៦៧ នៃក្រមព្រហ្មទណ្ឌ និងទីពីរគឺ **ទោសបន្ថែម** ដែលត្រូវបានប្បញ្ញត្តិនៅក្នុងមាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌ បានបញ្ញត្តិទោសបន្ថែមចំពោះនីតិបុគ្គលដូចតទៅ៖

១. ការរំលាយចោល ។

២. ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ។

៣. ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬ ច្រើន។

៤. ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។

៥. ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈឲ្យធ្វើការសន្សំសំចៃ។

៦.ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបានក្រៅពីឧបករណ៍អាចជួញដូរបានដែលកំណត់ដោយធនាគារ។

៧. ការហាមឃាត់ចំពោះការប្រើប្រាស់ប័ណ្ណទូទាត់។

៨. ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ធ្វើការរៀបចំ ឬ ប្រព្រឹត្តបទល្មើស។

៩.ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលបានប្រើប្រាស់សម្រាប់សាធារណជន។

១០.ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើសឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស។

១១. ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

១២. ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

១៣. ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត។

១៤. ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

ផ្ទុយទៅវិញ គឺមិនមានទោសជំនួសចំពោះនីតិបុគ្គលនៃនីតិសាធារណៈទេ ពីព្រោះមិនអាចឱ្យនីតិបុគ្គលដែលជាអរូបិយទៅធ្វើការងារសហគមន៍ឬក៏ស្ដីបន្ទោសទៅលើមនុស្សគ្មានរូបនេះឡើយ។

# ជំពូកទី២៖
# របបទូទៅនៃការប្រកាសព្យួរទោស

# ជំពូកទី២

# របបទូទៅនៃការប្រកាសព្យួរទោស

ជាគោលការណ៍ក្នុងការប្រកាសដាក់ទោសព្យួរ ឬមិនព្យួរលើបុគ្គលណាម្នាក់ ចៅក្រមត្រូវពិនិត្យមើលទៅលើស្ថានភាពមួយចំនួន ក្នុងនោះរួមមាន ស្ថានទម្ងន់ទោស កាលៈទេសៈនៃបទល្មើស បុគ្គលិកលក្ខណៈ ធនធាន និងបន្ទុករបស់ទណ្ឌិត។ នៅក្នុងនីតិវិធីនៃប្រព័ន្ធតុលាការ ការប្រកាសផ្តន្ទាទោស គឺត្រូវប្រកាសទៅតាមប្រភេទនៃបទល្មើសនីមួយៗ ក៏ប៉ុន្តែទោសទណ្ឌខ្លះក៏ត្រូវចៅក្រមសម្រេចឱ្យមានការព្យួរទោសមួយផ្នែកផងដែរ។ ផ្អែកតាមច្បាប់នៃក្រមព្រហ្មទណ្ឌ បានបញ្ញត្តិថានៅពេលដែលតុលាការប្រកាសផ្តន្ទាទោសចំពោះជនល្មើសណាមួយ តុលាការអាចបង្គាប់ឱ្យព្យួរការអនុវត្តនូវមូលទោសបាន[14]។ **ការព្យួរទោស** គឺជាការលើកលែងការអនុវត្តទោសមួយផ្នែក ឬទាំងស្រុង ដែលត្រូវបានអនុញ្ញាតដោយចៅក្រមដែលបានប្រកាសទោសនោះ[15]។ ត្រង់នេះមានន័យថា ការព្យួរទោស គឺជាការអនុញ្ញាតឱ្យជនជាប់ពិរុទ្ធដែលត្រូវតុលាការផ្តន្ទាទោសអាចមិនអនុវត្តទោសនេះបាន ប្រសិនបើមិនប្រព្រឹត្តបទល្មើសថ្មីផ្សេងទៀតក្នុងរយៈពេលដែលបានកំណត់ណាមួយ ពោលគឺជនណាដែលត្រូវតុលាការប្រកាសព្យួរទោស ជននោះមិនចាំបាច់រស់នៅក្នុងពន្ធនាគារទេ នៅក្នុងរយៈពេលនៃការអនុវត្តទោសនេះ។ ក្នុងការសម្រេចព្យួរទោសទណ្ឌិតណាម្នាក់បាន ចៅក្រមត្រូវពិនិត្យមើលលក្ខខណ្ឌជាក់ស្តែងមួយចំនួន ថាតើបុគ្គលនោះធ្លាប់បានប្រព្រឹត្តបទល្មើសពីមុនមកដែរឬទេ ឬចៅក្រមអាចពិចារណាថា តើបទល្មើសវាធ្ងន់ធ្ងរប៉ុន្មាន កាលៈទេសៈនៃការប្រព្រឹត្តហ្នឹងវាយ៉ាងម៉េចដែរ? ឧទាហរណ៍៖ បុរសម្នាក់អត់លុយយកកូនកំពុងឈឺទៅព្យាបាល ដោយមានជីវភាពខ្វះខាតខ្លាំង គាត់ក៏បានទៅលួចនេះលួចនោះរបស់គេ ដើម្បីបានលុយហ្នឹងមក។ ចំពោះបទល្មើសនេះ ចៅក្រមនឹងគិតពិចារណាទៅលើស្ថានភាពជាក់ស្តែងនៃការប្រព្រឹត្តបទល្មើសរបស់គាត់។ នៅក្នុងករណីនេះ ចៅក្រមពិនិត្យឃើញថាស្ថានភាពជាក់ស្តែងរបស់គាត់គឺមានបន្ទុកច្រើន ដូច្នេះក៏សម្រេចប្រកាសព្យួរទោសបុរសនោះ ដោយទុកឱ្យគាត់មានពេលរកស៊ីចិញ្ចឹមគ្រួសារ ដើម្បីអោយកូនបានរៀន ជាជាងយកគាត់ទៅដាក់គុកដែលវាមានផលប៉ះពាល់ដល់អ្នកដែលពឹងផ្អែកលើគាត់។

ម្យ៉ាងទៀតពាក់ព័ន្ធនឹង របបនៃការព្យួរទោស ក្នុងបទប្បញ្ញត្តិនៃមាត្រា ១០៥ នៃក្រមព្រហ្មទណ្ឌ បានចែងថា "ដើម្បីអនុវត្តបទប្បញ្ញត្តិស្តីពីការព្យួរទោស គឺគិតតែអំពីការផ្តន្ទាទោសជាស្ថាពរខាងបណ្តឹងអាជ្ញាប៉ុណ្ណោះ"។ ដូច្នេះ គឺមិនត្រូវគិតអំពីបណ្តឹងរដ្ឋប្បវេណីឡើយ ព្រោះបណ្តឹងអាជ្ញាគឺជាបណ្តឹងព្រហ្មទណ្ឌ។ បើយោងទៅតាមមាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរ ឆ្នាំ២០០៧ ស្តីពី "បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី" បានចែង យ៉ាងច្បាស់ថាបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី គឺជាបណ្តឹងពីរផ្សេងដាច់ពីគ្នា។ ចំពោះ **"បណ្តឹងអាជ្ញា"** មានគោល

[14] មាត្រា ១០៤, ក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[15] សទ្ទានុក្រមពាក្យច្បាប់ខ្មែរ-អង់គ្លេស-បារាំង ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ១៥

បំណងពិនិត្យអត្ថិភាព(ការកើតមាន)នៃបទល្មើស បង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់។ ចំណែកឯ **"បណ្តឹងរដ្ឋប្បវេណី"** មានគោលបំណងធ្វើឲ្យមានការជួសជុលការខូចខាតដែលបណ្តាល មកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងធ្វើឲ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តសមល្មមនឹងព្យសនកម្មដែលខ្លួនបានរងគ្រោះ។ បើពិនិត្យឲ្យបានស៊ីជម្រៅអំពីការព្យួរទោសនេះ យើងឃើញថាចាប់ពីមាត្រា ១០៤ ដល់ មាត្រា ១២៣ នៃក្រមព្រហ្មទណ្ឌ ការព្យួរទោសត្រូវបានបកស្រាយតាមវិធីសាស្ត្រអនុមានញែក ឬវិធីបំបែកន័យដោយចែកចេញជា ២ (ពីរ) ប្រភេទទៀតគឺ ការប្រកាសព្យួរទោសធម្មតា**(១)** និងការប្រកាសព្យួរទោសសាកល្បង**(២)**។

## ផ្នែកទី១. ការប្រកាសព្យួរទោសធម្មតា

ទោះបីជាក្រមព្រហ្មទណ្ឌ បានចែងអំពីការដាក់ទោសទណ្ឌទៅលើជនដែលប្រព្រឹត្តខុសយ៉ាងណាក៏ដោយក៏ច្បាប់ព្រហ្មទណ្ឌនូវតែចែងអំពីការព្យួរទោសធម្មតាសម្រាប់ជនល្មើសផងដែរ។ **ការព្យួរទោសធម្មតា** គឺជាការព្យួរទោស ដែលមិនមានដាក់ឱ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវកាតព្វកិច្ចដោយឡែកមួយឬច្រើននោះទេ[16]។ ប្រសិនបើជនល្មើសត្រូវតុលាការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ដោយត្រូវព្យួរទោស ជនល្មើសនេះមិនត្រូវជាប់ក្នុងពន្ធនាគារទេ ក៏ប៉ុន្តែប្រសិនបើក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ[17] ចាប់ពីថ្ងៃប្រកាសទោស ជនល្មើសនេះបានប្រព្រឹត្តបទល្មើសណាមួយថ្មីទៀត ការព្យួរទោសនឹងត្រូវលើកចេញវិញ ហើយជនល្មើសនឹងត្រូវអនុវត្តទោសទាំងពីរ គឺទាំងទោសទី១ ដែលបានព្យួរ និងទោសទី២ សម្រាប់បទល្មើសដែលប្រព្រឹត្តថ្មីក្រោយ។ ដូចគ្នាចំពោះទោសពិន័យជាប្រាក់ដែរ ប្រសិនបើតុលាការប្រកាសព្យួរទោស ជនល្មើសមិនត្រូវបង់ប្រាក់ពិន័យទេប្រសិនបើមិនមានប្រព្រឹត្តបទល្មើសថ្មីទៀតក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ។

គួរបញ្ជាក់ថា ការប្រកាសព្យួរទោស ឬមិនព្យួរ គឺជាសិទ្ធិអំណាចរបស់តុលាការ ក៏ប៉ុន្តែ ទោសពន្ធនាគារដែលតុលាការអាចប្រកាសព្យួរបាន ទាល់តែទោសពន្ធនាគារនោះមានរយៈពេលយ៉ាងច្រើនបំផុត ៥ (ប្រាំ) ឆ្នាំ។ ប្រសិនបើជនល្មើសត្រូវតុលាការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ លើសពី ៥ (ប្រាំ) ឆ្នាំ តុលាការមិនអាចប្រកាសព្យួរទោសនេះបានទេ។ ម្យ៉ាងទៀត បើទោះបីជាទោសពន្ធនាគារនេះមានរយៈពេលត្រឹម ៥ (ប្រាំ) ឆ្នាំ ឬតិចជាង ៥ (ប្រាំ)ឆ្នាំក៏ដោយ តុលាការអាចប្រកាសព្យួរទោសបាន លុះត្រាតែជនល្មើសមិនធ្លាប់ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារម្តងសោះនៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំមុនកើតមានអំពើល្មើស។ ចំពោះវិធានការមួយនេះពុំបង្កើត

[16] ដកស្រង់ចេញពីសៀវភៅ "ទោសព្រហ្មទណ្ឌ" រៀបរៀងដោយលោកសាស្ត្រាចារ្យ កៅ សីហា

[17] សទ្ទានុក្រមពាក្យច្បាប់ខ្មែរ-អង់គ្លេស-បារាំង ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ១៦

បានជាសិទ្ធិសម្រាប់ទណ្ឌិតឡើយ ប៉ុន្តែជាវិធានការមួយដែលអនុគ្រោះដល់ទណ្ឌិត ដែលតុលាការមានសិទ្ធិសេរីភាពក្នុងការសម្រេចថានឹងផ្តល់ឱ្យ ឬមិនផ្តល់ឱ្យ។[18]

ឧទាហរណ៍៖ នៅឆ្នាំ២០០៨ ជនល្មើស "ក" ធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារម្តងរួចមកហើយ ស្រាប់តែ ៤ (បួន) ឆ្នាំក្រោយមក នៅឆ្នាំ២០១២ "ក" បានប្រព្រឹត្តបទល្មើសថ្មីទៀត ហើយត្រូវតុលាការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ៣ (បី) ឆ្នាំ។ ដូចនេះទោស ៣ (បី) ឆ្នាំក្រោយនេះមិនអាចត្រូវព្យួរបានទេ។ អនុលោមតាមមាត្រា ១០៦ ដល់ មាត្រា ១១៦ ការព្យួរទោសធម្មតា អាចធ្វើទៅបានដោយតុលាការត្រូវធ្វើការត្រួតមើលទៅលើការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម**(១.១)** ឬការចោទប្រកាន់ចំពោះបទលហុ**(១.២)**។

### កថាខណ្ឌទី១៖ ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

ការព្យួរទោសធម្មតានេះចៅក្រមអាចធ្វើទៅបាន គឺទាល់តែបំពេញនូវលក្ខខណ្ឌមួយចំនួនដូចជាលក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន**(១.១.១)** នឹងលក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលអាចនាំឲ្យមានការព្យួរ**(១.១.២)**។ ក្រៅពីនេះ ក៏នូវមានចំណុចសំខាន់ៗផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការព្យួរទោសធម្មតានេះផងដែរ**(១.១.៣)**។

#### ១.១ លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន

លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន ទាំងអស់នេះគឺទាក់ទងនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ការព្យួរទោសធម្មតាអាចត្រូវផ្តល់ឲ្យបាន ប្រសិនបើជនជាប់ចោទមិនទាន់មានការផ្តន្ទាទោសជាស្ថាពរឲ្យជាប់ពន្ធនាគារក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំមុនអំពើល្មើស[19] មានន័យថា រហូតមកទល់នឹងថ្ងៃដែលគាត់ប្រព្រឹត្តបទល្មើសនោះ គឺគាត់អត់មានត្រូវបានតុលាការ ផ្តន្ទាទោសណាមួយពីមុនជាស្ថាពរទេក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ។ ប៉ុន្តែបើសិនជាគិតតាំងពីលើកមុនមកមានសាលក្រមស្ថាពរ រហូតមិនទាន់ផុត ៥ (ប្រាំ) ឆ្នាំផង ស្រាប់តែមានការប្រព្រឹត្តបទល្មើសលើកក្រោយទៀត គឺតុលាការមិនអាចយកករណីបទល្មើសក្រោយនេះទៅធ្វើការប្រកាសការព្យួរទោសបានទេ។

#### ១.២ លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលនាំឲ្យមានការព្យួរទោសធម្មតា

លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលនាំឲ្យមានការព្យួរទោសធម្មតា[20]ទាំងនេះគឺទោសដាក់ពន្ធនាគារ កាលបើទោសដែលប្រកាសនោះមានរយៈពេលតិចជាង ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ មានន័យថា តុលាការប្រកាសថាគាត់មានទោសត្រូវដាក់ពន្ធនាគារតិចជាង ឬស្មើ ៥ (ប្រាំ) ឆ្នាំ គឺគាត់អាចជ្រើសរើសយកការព្យួរ

[18] យោងតាម " មេរៀននីតិព្រហ្មទណ្ឌ " នៃសហប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ ដោយផ្អែកលើអត្ថបទនៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ខែធ្នូ ឆ្នាំ២០០៧

[19] មាត្រា ១០៦ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[20] មាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

ទោសនេះបាន។ ចំពោះករណីទោសពិន័យជាប្រាក់វិញផងដែរ ជួនកាលតុលាការ ប្រកាសទោសពិន័យជាប្រាក់ ប្រសិនបើជាគាត់មិនចង់ឲ្យមានការអនុវត្តន៍ទេ ក៏គាត់អាចប្រកាសការព្យួរទោសបានដែរ។

### ១.៣ ចំណុចផ្សេងៗទៀតពាក់ព័ន្ធនឹងការព្យួរទោសធម្មតា

#### ក. ការព្យួរទោសមួយផ្នែក

ការព្យួរទោសមួយផ្នែក[21] ចំពោះការព្យួរទោសនេះ តុលាការអាចប្រកាសព្យួរទាំងស្រុងក៏បាន ឬព្យួរមួយផ្នែកក៏បាន ពីព្រោះតុលាការអាចសម្រេចថា ការព្យួរទោសធម្មតានេះអាចនឹងអនុវត្តទៅលើផ្នែកមួយនៃទោសពន្ធនាគារ ដែលតុលាការគឺជាអ្នកកំណត់ថិរវេលា ឬលើមួយផ្នែកនៃប្រាក់ពិន័យដែលតុលាការជាអ្នកកំណត់ចំនួនទឹកប្រាក់ មានន័យថា បើសិនជាគាត់ចង់ប្រកាសឲ្យព្យួរទោសមួយផ្នែក នោះគឺត្រូវតែកំណត់ឲ្យបានច្បាស់លាស់នូវផ្នែកនៃទោសដែលត្រូវព្យួរ ដូចជាប្រកាសព្យួរទៅលើទោសដាក់ពន្ធនាគារ បើគាត់ចង់ព្យួរមួយផ្នែកនោះ គឺគាត់ត្រូវកំណត់ថារយៈពេលប៉ុន្មានដែលគាត់ឲ្យអនុវត្ត ហើយនិងរយៈពេលប៉ុន្មានថ្ងៃ ខែ ឆ្នាំ ដែលគាត់ត្រូវព្យួរមិនឱ្យជាប់ពន្ធនាគារនោះ? ឧទាហរណ៍៖ តុលាការប្រកាសទោសចំពោះទណ្ឌិតណាមួយ ឧបមាថា ឥឡូវ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ២ ឆ្នាំទៅចុះ អញ្ចឹងតុលាការសម្រេចថាមិនចង់ឲ្យ មានការព្យួរទាំងស្រុងទេ តុលាការសម្រេចថា ១ ឆ្នាំ គឺត្រូវព្យួរ ១ ឆ្នាំ ទៀតគឺត្រូវអនុវត្ត។ តុលាការត្រូវតែប្រកាសកំណត់យ៉ាងច្បាស់លាស់នៅក្នុងសាលក្រមថាផ្តន្ទាទោស ដាក់ពន្ធនាគារ ២ ឆ្នាំ ប៉ុន្តែ ១ ឆ្នាំត្រូវព្យួរ នេះគឺត្រូវកំណត់ឲ្យជាក់លាក់។

យើងសូមបញ្ជាក់ផងដែរថា តុលាការប្រកាសការព្យួរទោសមួយផ្នែកនេះ គឺច្រើនតែមានការឃុំខ្លួនបណ្តោះអាសន្នជាមុនសិន។ ករណីដូចមានជនម្នាក់ ត្រូវបានចៅក្រមស៊ើបសួរចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន[22]។ ក្រោយពីបានឃុំខ្លួនបណ្តោះអាសន្នរួចហើយ តុលាការសម្រេចដាក់ទោសពន្ធនាគារលើសពីចំនួនដែលឃុំខ្លួនបណ្តោះអាសន្ន ព្រោះការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីបទមជ្ឈិម ច្បាប់កំណត់មិនឱ្យលើសពីកម្រិតពាក់កណ្តាលនៃអប្បបរមាឡើយ ដូចជា ៦ (ប្រាំមួយ) ខែ គឺមិនឲ្យឃុំខ្លួនលើសពី ៣ (បី) ខែទេ។ ស្រាប់តែដល់ពេលតុលាការផ្តន្ទាទោសមើលទៅបើដាក់គុក ៦ (ប្រាំមួយ) ខែ ហាក់ដូចជា មិនសាកសមដោយសារតែកាលៈទេសៈនៃការប្រព្រឹត្តបទល្មើសនោះចៅក្រម ក៏សម្រេចដាក់ទោសពន្ធនាគារ ៤ (បួន) ខែ ចុះបើនៅសល់ ១ (មួយ) ខែទៀត តើត្រូវធ្វើ ដូចម្តេចទៅ? ត្រង់ចំណុចនេះភាគច្រើន គឺតុលាការគាត់ព្យួរទោសមួយផ្នែក បានន័យថា ៣ ខែ ដែលជាប់ឃុំខ្លួនបណ្តោះអាសន្ននោះ ត្រូវទូទាត់សងនឹងទោសគុកចំនួន ៣ ខែរួចហើយនៅសល់ ១ (មួយ) ខែទៀតត្រូវព្យួរទោសនោះ។[23] ចំពោះទោសពិន័យជាប្រាក់វិញក៏ដូចគ្នាដែរ កាលបើ

[21] មាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[22] មាត្រា ២០៣ ដល់មាត្រា ២១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[23] ដកស្រង់ចេញពីសៀវភៅ " ទោសព្រហ្មទណ្ឌ " រៀបរៀងដោយលោកសាស្ត្រាចារ្យ កៅ សីហា

តុលាការប្រកាសទោសពិន័យជាប្រាក់ ហើយមិនចង់ព្យួរទាំងស្រុងទេ គឺតុលាការអាចព្យួរមួយផ្នែកបានដូចគ្នា ហើយត្រូវកំណត់ចំនួនទឹកប្រាក់ប៉ុន្មានរៀលទៅតាមអ្វីដែលទោសនោះត្រូវព្យួរ។

**ខ. ការដកហូតការព្យួរទោស**

ការដកហូតការព្យួរទោស ប្រសិនបើក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរ ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយមានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀតពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ការព្យួរទោសធម្មតានេះត្រូវដកហូតដោយពេញច្បាប់ ឬបើយើងនិយាយសាមញ្ញ គឺត្រូវដកហូតដោយស្វ័យប្រវត្តិ។ ទោសទី១ ត្រូវអនុវត្តដោយមិនអាចស្រូបចូលជាមួយទោសទី២ បានឡើយ[24]។ យោងតាមអត្ថន័យខាងលើនេះ គឺបានសេចក្តីថាចំពោះ ការព្យួរទោសធម្មតា បើសិនជាក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ មិនទាន់ហួសរយៈពេល ៥ (ប្រាំ) ឆ្នាំផង ជននោះក៏ទៅប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយទៀត។ ដូច្នេះករណីនេះ បើសិនជាមានសាលក្រម ឬសាលដីកាក្រោយផ្តន្ទាទោសជាស្ថាពរ ធ្វើឲ្យដកហូតការព្យួរទោសដែលផ្តន្ទាទោស ដោយកំណត់នៅក្នុងសាលក្រម ឬសាលដីកាមុន គឺដកហូតដោយពេញច្បាប់ ឬស្វ័យប្រវត្តិ មានន័យថាសាលក្រមទី១ ដែលកំណត់ទោសប៉ុន្មាន គឺត្រូវដកហូតយកមកអនុវត្តទោសពេញលេញ និងសាលក្រមទី២ ដែលកំណត់ត្រូវយកមកអនុវត្តដោយបូកបញ្ចូលគ្នាតែម្តង ពោលគឺមិនស្រូបបញ្ចូលគ្នាទេ។

**គ. ការមិនដកហូតការព្យួរទោស**

ការមិនដកហូតការព្យួរទោសនេះ តុលាការអាចសម្រេចថា ការផ្តន្ទាទោសថ្មីមិននាំឱ្យមានការដកហូតនូវការព្យួរទោសធម្មតាដែលបានសម្រេចពីមុននោះទេ។ ចំពោះសេចក្តីសម្រេចរបស់តុលាការត្រូវតែមានសំអាងហេតុបញ្ជាក់ជាពិសេស។ យោងតាមអត្ថន័យនេះ បានបញ្ជាក់ឱ្យឃើញថាក្រមក៏បានទុកសិទ្ធិឱ្យចៅក្រមមានសិទ្ធិក្នុងការសម្រេចអំពីការមិនដកហូតការព្យួរទោសបាន បើសិនការផ្តន្ទាទោសក្រោយនេះស្ថិតនៅក្នុងកម្រិតរយៈពេល ៥ ឆ្នាំ ដែលជននេះបានទៅប្រព្រឹត្តចំពោះសាលក្រមទី ១ ដែលបានកំណត់ព្យួររួចហើយក៏ដោយ[25]។ ឧទាហរណ៍៖ ជនម្នាក់ក្រីក្រខ្លាំងពេក ក៏ទៅប្រព្រឹត្តបទលួច។ នៅពេលដែល នគរបាលយុត្តិធម៌ចាប់ខ្លួនបានក៏បញ្ជូនទៅតុលាការដើម្បីជំនុំជម្រះលើគាត់។ ពេលជំនុំជម្រះរួច ចៅក្រមដែលមានមនុស្សធម៌ក៏សម្រេចព្យួរទោសជននេះ។ គាត់ក៏ខិតខំអប់រំ កែប្រែខ្លួន ស្រាប់តែនៅថ្ងៃដែលជិតផុតពេលកំណត់របស់ច្បាប់ថាចំនួន ៥ ឆ្នាំ នោះទៅហើយ ប៉ុន្តែគាត់អត់មានអ្វីពិសារទាល់តែសោះ ដោយគាត់ឃ្លានខ្លាំងពេក គាត់ក៏ទៅលួចគេម្តង ទៀត។ ចំពោះករណីថ្មីនេះ តុលាការអាចមិនដកហូតការព្យួរទោសបាន។

[24] មាត្រា១០៩ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[25] មាត្រា ១១០ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

ដូចនេះ ប្រសិនបើចៅក្រមយល់ឃើញថាមិនគួរដកហូតការព្យួរទោស ចៅក្រមត្រូវតែចែងក្នុងសាលក្រមនោះឱ្យបានច្បាស់លាស់ថាមិនដកហូតការព្យួរទោសទេ ហើយត្រូវបញ្ជាក់អំពីសំអាងមូលហេតុដែលខ្លួនមិនដកហូតការព្យួរទោស។

### ឃ. ការទុកជាអសារបង់នូវការផ្តន្ទាទោស

ការទុកជាអសារបង់នូវការផ្តន្ទាទោស ចំពោះការព្យួរទោសនេះ យើងសូមបញ្ជាក់ជូនផងដែរថា នៅពេលដែលផុតចិរវេលា ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីមានសាលក្រមកំណត់អំពីការព្យួរទោសនេះហើយ គឺទោសនោះត្រូវចាត់ទុកជាអសារបង់ មានន័យថា គេលែងយកមកអនុវត្តតទៅទៀតហើយ ទោះបីជាទោសដាក់ពន្ធនាគារក្តី ឬទោសពិន័យជាប្រាក់ក្តី។ យោងតាមមាត្រា ១១១ បានចែងថា ប្រសិនបើរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយក៏គ្មានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀតពី បទឧក្រិដ្ឋ ឬបទមជ្ឈិមនោះទេ ការផ្តន្ទាទោសដោយមានព្យួរនេះត្រូវចាត់ទុកជាអសារបង់ រីឯទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ។ កាលណាបើការព្យួរទោសត្រូវបានប្រកាសទៅលើតែផ្នែកមួយនៃទោសនោះការផ្តន្ទាទោសត្រូវចាត់ទុកជាអសារបង់ទាំងស្រុងហើយទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ។[26]

ការបញ្ជាក់ខាងលើនេះ គឺសម្រាប់ទោសដែលទាក់ទងជាមួយនឹងការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬមជ្ឈិមតែប៉ុណ្ណោះ។ ចំណែកឯបទលហុ យើងនឹងធ្វើការបកស្រាយដូចតទៅៈ

### កថាខណ្ឌទី ២ៈ ការចោទប្រកាន់ចំពោះបទលហុ

ចំពោះការព្យួរទោសក្នុងបទលហុវិញ គឺមានលក្ខណៈខុសប្លែកគ្នាខ្លះអំពីចិរវេលាដែលទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន វាគឺជាលក្ខខណ្ឌចាំបាច់ដែលផ្តល់ឲ្យតុលាការអាចសម្រេចពីការព្យួរទោសធម្មតានេះ។ លក្ខខណ្ឌនៅក្នុងការចោទប្រកាន់អំពីបទលហុនេះដែលអាចឈានដល់ការព្យួរទោស រួមមាន លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន**(២.១)** លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលអាចនាំឲ្យមានការព្យួរទោស**(២.២)** និងចំណុចផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការព្យួរទោសធម្មតានេះផងដែរ**(២.៣)**។

### ២.១ លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន

លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាអាចត្រូវបានប្រកាស ប្រសិនបើជនជាប់ចោទមិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារជាស្ថាពរនៅឡើយនៅក្នុងរយៈពេល ១ (មួយ) ឆ្នាំមុនបទល្មើសនេះ[27] មានន័យថា គាត់មិនត្រូវបានចៅក្រមផ្តន្ទាទោសណាមួយពី

[26] មាត្រា ១១១ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[27] មាត្រា១១២ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

បទល្មើសណាមួយក្នុងរយៈពេល ១ (មួយ) ឆ្នាំទេ។ ប្រសិនបើមានការផ្តន្ទាទោសពីមុននៅក្នុងរយៈពេល ១ (មួយ) ឆ្នាំ មិនអាចយកការព្យួរទោសចំពោះបទលហុនេះមកប្រើបានទេ។

### ២.២. លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលអាចនាំឲ្យមានការព្យួរទោសធម្មតា

លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលអាចនាំឲ្យមានការព្យួរទោសធម្មតា ទោសអាចព្យួរបានចំពោះបទលហុនេះមានទាំងទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ យោងតាមក្រមព្រហ្មទណ្ឌថ្មី (ឆ្នាំ២០០៩) បានចែងថាក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាត្រូវបានអនុវត្តទៅលើទោសដូចតទៅនេះ៖[28]

- ទោសដាក់ពន្ធនាគារ
- ទោសពិន័យជាប្រាក់។

### ២.៣. ចំណុចផ្សេងទៀតពាក់ព័ន្ធនឹងការព្យួរទោសធម្មតា

#### ក. ការដកហូតការព្យួរទោស

ការដកហូតការព្យួរទោស ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ ក្រោយការផ្តន្ទាទោសជាស្ថាពរពីបទលហុដោយមានការព្យួរទោសធម្មតាផង រួចកើតមានការផ្តន្ទាទោសថ្មីជាស្ថាពរពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការព្យួរទោសធម្មតានេះត្រូវដកហូតចេញដោយពេញច្បាប់។ ទោសទី១ ត្រូវអនុវត្តដោយគ្មានស្រូបជាមួយនឹងទោសទី២ ឡើយ។[29] ដូច្នេះការព្យួរទោសក្នុងបទលហុ បើគាត់បានប្រព្រឹត្តបទល្មើសថ្មីទៀតទាំងបទឧក្រិដ្ឋក្តី បទមជ្ឈិមក្តី ឬបទលហុក្តី នៅក្នុងរយៈពេល ១ (មួយ) ឆ្នាំ គិតពីពេលសាលក្រមមុនចូលជាស្ថាពរមក ដែលមានការព្យួរទោស ពីបទលហុនេះ គឺថាការដកហូតការព្យួរទោសនៃសាលក្រមមុន ត្រូវដកហូតដោយពេញច្បាប់ ឬដោយស្វ័យប្រវត្តិ។ ដូចនេះ សាលក្រមទី១ ត្រូវយកមកអនុវត្តបូកជាមួយនឹងសាលក្រមទី២ គឺទោសទាំងប៉ុន្មានដែលសាលក្រមទី១ បានកំណត់ និងសាលក្រមទី២ បានកំណត់ នឹងត្រូវអនុវត្តដោយបញ្ចូលគ្នាផ្ទុយទៅវិញគឺអត់មានស្រូបបញ្ចូលគ្នានៃទោសទាំងពីរនោះទេ។

#### ខ. ការមិនដកហូតការព្យួរទោស

ការមិនដកហូតការព្យួរទោស ដូចគ្នានឹងការចោទប្រកាន់ពីបទមជ្ឈិម និងបទឧក្រិដ្ឋដែរ ទាក់ទងជាមួយនឹងការមិនដកហូតអំពីការព្យួរទោសនេះ ប្រសិនបើជាចៅក្រមយល់ឃើញថា ទោះបីជាទណ្ឌិតបានប្រព្រឹត្តបទល្មើសនៅក្នុងចិរវេលា ១ (មួយ) ឆ្នាំ បន្ទាប់ពីមានសាលក្រមព្យួរទោសលើកទី ១ (មួយ) រួចក៏ដោយមិនត្រូវដកហូតការព្យួរទោសធម្មតាទេ នោះគឺគាត់ត្រូវតែបញ្ជាក់ឲ្យបានជាក់លាក់នៅក្នុងសាលក្រម និងមានចែងបញ្ជាក់អំពីសំអាងហេតុជាពិសេសផងដែរ ព្រោះក្រមព្រហ្មទណ្ឌយើងបានបញ្ញត្តិដោយបង្ហាញជាបដិបញ្ញត្តិនៃមាត្រា

---

[28] មាត្រា ១១៣ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[29] មាត្រា ១១៤ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

១១៤(ការដកហូតការព្យួរទោស) នៃក្រមព្រហ្មទណ្ឌនេះ តុលាការអាចសម្រេចថា ការផ្ដន្ទាទោសថ្មីមិនអាចនាំឲ្យមានការដកហូតនូវការព្យួរទោសធម្មតានេះដែលសម្រេចពីមុននោះទេ។ សេចក្ដីសម្រេចនេះត្រូវតែមានសំអាងហេតុជាពិសេស។[30]

**គ. ការទុកជាអសារបង់នូវការផ្ដន្ទាទោស**

ការទុកជាអសារបង់នូវការផ្ដន្ទាទោស ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីការផ្ដន្ទាទោសចូលជាស្ថាពរ ពីបទលហុដែលមានការព្យួរទោសធម្មតា ហើយក៏គ្មានការផ្ដន្ទាទោសថ្មីណាមួយបានកើតឡើងពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុទេ ការផ្ដន្ទាទោសដែលព្យួរនោះត្រូវទុកជាអសារបង់ រីឯទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ។[31] ដូច្នេះប្រសិនបើជាហួសរយៈពេល ១ (មួយ) ឆ្នាំ ផុតពីសាលក្រមដែលបានកំណត់អំពីការព្យួរទោសស្ដីអំពីបទលហុនោះបានកន្លងផុតទៅ គឺទោសនេះត្រូវទុកជាអសារបង់ មានន័យថា លែងយកទោសមកអនុវត្តទៀតហើយ។ ជាបន្តទៅនេះ យើងនឹងធ្វើការលើកឡើងនូវចំណុចបន្ទាប់ទៀតដែលពាក់ព័ន្ធជាមួយ ការព្យួរទោសសាកល្បងវិញម្ដង។ ដើម្បីចង់ដឹងថាការព្យួរទោសសាកល្បងមានលក្ខណៈបែបណា និងខុសគ្នា ឬដូចគ្នាជាមួយការព្យួរទោសធម្មតាយ៉ាងណានោះ យើងខ្ញុំនឹងធ្វើការបកស្រាយជាបន្តបន្ទាប់ដូចខាងក្រោមៈ

**កថាខណ្ឌទី៣៖ ការប្រកាសព្យួរទោសសាកល្បង**

ការព្យួរទោសសាកល្បង គឺជាការដាក់ឲ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវលក្ខខណ្ឌដោយឡែកមួយ ឬច្រើន ក្នុងរយៈពេលព្យួរទោសសាកល្បងមុនអនុវត្តទោសព្យួរ។[32] គេអាចឲ្យនិយមន័យម្យ៉ាងទៀតថា ការព្យួរទោសសាកល្បង គឺជាការព្យួរទោសដែលអាចផ្ដល់ឲ្យទណ្ឌិត ដែលត្រូវទទួលរងទោសដាក់ពន្ធនាគារមានរយៈពេលពី ៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ ដោយដាក់ឲ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពកាតព្វកិច្ចដោយឡែកមួយ ឬច្រើនក្នុងរយៈពេលសាកល្បងមិនអាចតិចជាង ១ (មួយ) ឆ្នាំ និងមិនលើសពី ៣ (បី) ឆ្នាំទេ[33]។ ទណ្ឌិតដែលទទួលនូវការព្យួរទោសសាកល្បងបានលុះត្រាតែមានបំពេញលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១១៧ **(២.១)** ដែលការទទួលបាននូវការព្យួរនេះត្រូវមានបុគ្គលផ្សេងក្រៅពីទណ្ឌិតមានតួនាទីផ្សេងទៀតដែលដាក់ឲ្យទណ្ឌិតអនុវត្តនូវការព្យួរទោសសាកល្បង **(២.១.១)** អ្វីដែលពិសេសនោះឃើញថានៅក្នុងរបបនេះ មាននូវកាតព្វកិច្ច និងវិធានការដោយឡែកដែលតម្រូវឲ្យបុគ្គលដែលទទួលបាននូវការ

---

[30] មាត្រា ១១៥ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[31] មាត្រា ១១៦ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[32] សទ្ទានុក្រមពាក្យច្បាប់ខ្មែរ-អង់គ្លេស-បារាំង ផ្នែកក្រមព្រហ្មទណ្ឌ ទីស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ លេខរៀងទី ១៧

[33] មាត្រា ១១៧ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

ព្យួរទោសសាកល្បងនោះត្រូវតែគោរពតាម(**២.២**) លើសពីនេះទៅទៀតក៏គេអាចមានការកែប្រែ ឬដកហូតការព្យួរទោសសាកល្បងនេះបានផងដែរ(**២.៣**) ។

## ៣.១ លក្ខខណ្ឌនៃការព្យួរទោសសាកល្បង និងរយៈពេលនៃការសាកល្បង

នៅក្នុងយន្តការទាំងឡាយដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ គឺសុទ្ធតែមាននូវលក្ខខណ្ឌរបស់គេ។ ជាក់ស្តែងទៅតាមមាត្រា១១៧ កថាខណ្ឌទី១ (មួយ) នៃក្រមព្រហ្មទណ្ឌ គឺបានកំណត់អំពី លក្ខខណ្ឌនៃការព្យួរទោសសាកល្បង (**ក**) និងមាត្រា១១៨ គឺបានកំណត់អំពី រយៈពេលនៃការសាកល្បង (**ខ**) យើងនឹងធ្វើការបកស្រាយដូចតទៅ៖

### ក. លក្ខខណ្ឌនៃការព្យួរទោសសាកល្បង

នៅក្នុងនេះដើម្បីអាចព្យួរទោសសាកល្បងបាន ទាល់តែទណ្ឌិតនេះត្រូវបានតុលាការគាត់ប្រកាសទោសនៅចន្លោះពី ៦ (ប្រាំមួយ)ខែ ដល់តិចជាង ឬស្មើ ៥ (ប្រាំ) ឆ្នាំ មានន័យថា គឺនៅចន្លោះពី ៦ (ប្រាំមួយ) ខែ ទៅ ៥(ប្រាំ) ឆ្នាំ។ ដូច្នេះតុលាការអាចជ្រើសរើសយកនូវការព្យួរទោសសាកល្បងបាន ពីព្រោះមាត្រា១១៧ កថាខណ្ឌទី១ កំណត់ថា តុលាការអាចសម្រេចព្យួរសាកល្បងនូវទោសដែលបានសម្រេចដាក់ពន្ធនាគារដែលមានរយៈពេលពី ៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ។

### ខ. រយៈពេលនៃការសាកល្បង

ចំពោះថិរវេលាដែលតុលាការកំណត់ឲ្យសាកល្បងនោះ អាចកំណត់មិនឲ្យតិចជាង១(មួយ)ឆ្នាំ ហើយក៏មិនឲ្យលើសពី ៣ (បី) ឆ្នាំដែរ។ ដូច្នេះត្រូវនៅចន្លោះពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ តុលាការអាចកំណត់ថិរវេលាឲ្យគាត់សាកល្បងគឺ៖

- បំពេញនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនដែលតុលាការកំណត់។
- ស្ថិតនៅក្រោមវិធានការត្រួតពិនិត្យទាំងឡាយដែលច្បាប់បានកំណត់។

ដូច្នេះនៅក្នុងការព្យួរទោសសាកល្បងនេះ តុលាការត្រូវតែកំណត់ថិរវេលាថា ប៉ុន្មានឆ្នាំដែលគាត់ត្រូវមានរយៈពេលសាកល្បង។ រយៈពេលនេះអាច ១ (មួយ) ឆ្នាំ ឬ ២ (ពីរ) ឆ្នាំ ឬ ៣ (បី) ឆ្នាំ ដោយមិនអាចលើស ឬខ្វះនោះទេ។[34]

[34] មាត្រា ១១៨ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

### ៣.២ វិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែក

បុគ្គលដែលទទួលបាននូវការព្យួរទោសសាកល្បង គឺមាននូវវិធានការមួយចំនួនដែលត្រូវតែគោរព និងប្រតិបត្តិតាម (ក) ក្រៅពីវិធានការនេះក៏មាននូវកាតព្វកិច្ចដោយឡែកដែលត្រូវដាក់ទៅលើទណ្ឌិតបានផងដែរ (ខ) ដើម្បីបញ្ជាក់ពីវិធាន និងកាតព្វកិច្ចដោយឡែកនេះ យើងនឹងធ្វើការបញ្ជាក់ដូចតទៅ៖

#### ក. វិធានការត្រួតពិនិត្យដែលដាក់នៅលើទណ្ឌិត

ចំពោះវិធានការត្រួតពិនិត្យដែលតម្រូវទៅលើទណ្ឌិត មានដូចតទៅ ៖

១.ទណ្ឌិតត្រូវតែគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យ។

២.ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គល ដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យ។

៣.ទណ្ឌិតត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬដល់បុគ្គលដែលព្រះរាជអាជ្ញា បានប្រគល់អំណាចឲ្យនូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់ លើការបញ្ចូលឲ្យទៅរស់នៅក្នុងសង្គមវិញ។

៤.ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន។

៥.ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន។

៦.ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស[35]។ វិធានទាំងនេះគឺជាវិធានការត្រួតពិនិត្យដែលតុលាការដាក់ទៅលើទណ្ឌិតមួយណា ដែលត្រូវបានប្រកាសអំពីការព្យួរទោសសាកល្បងតែប៉ុណ្ណោះ។

#### ខ. កាតព្វកិច្ចដោយឡែកដែលដាក់នៅលើទណ្ឌិត

ចំពោះការព្យួរទោសសាកល្បងនេះផងដែរ មិនមានតែវិធានការត្រួតពិនិត្យតែប៉ុណ្ណោះទេ ក៏នៅមាននូវកាតព្វកិច្ចដោយឡែកដែលអាចដាក់ទៅលើទណ្ឌិតផងដែរ ដែលកាតព្វកិច្ចដោយឡែកទាំងនោះរួមមានដូចខាងក្រោម ៖

១. បំពេញសកម្មភាពខាងវិជ្ជាជីវៈ។

២. ទទួលការបង្ហាត់បង្រៀន ឬទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ។

៣. រស់នៅក្នុងទីកន្លែងណាមួយជាកំណត់។

៤. ទទួលឲ្យពេទ្យធ្វើការពិនិត្យ ឬការព្យាបាល។

៥. បញ្ជាក់ថាខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ។

៦.ធ្វើការជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើសតាមលទ្ធភាពនៃធនធានរបស់ខ្លួន។

---

[35] មាត្រា ១១៩ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

៧.បញ្ជាក់ថាខ្លួនបានបង់ប្រាក់ជូនរដ្ឋបន្ទាប់ពីការផ្តន្ទាទោសតាមលទ្ធភាពនៃធនធានរបស់ខ្លួន។

៨. មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈ ឬសង្គមដែលអនុញ្ញាត ឬសម្រួលដល់ការប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់។

៩. មិនត្រូវមានមុខនៅទីកន្លែងខ្លះ។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីទីកន្លែងដែលហាមឃាត់។

១០. មិនត្រូវសេពគប់បនល្បែង។

១១. មិនត្រូវសេពគប់គៀមភេសជ្ជៈស្រវឹង។

១២. មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេស ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីបុគ្គលដែលមិនត្រូវសេពគប់ជាមួយ។

១៣. មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។[36]

នៅក្នុងសេចក្តីសម្រេច តុលាការត្រូវចែងអំពីកាតព្វកិច្ចដោយឡែក ដែលតម្រូវទៅលើទណ្ឌិត។ រីឯកាតព្វកិច្ចដោយឡែករួមទាំងអស់ចំនួន ១៣ (ដប់បី) ចំណុចខាងលើនេះ គឺតុលាការអាចប្រកាសយកមួយ ឬច្រើនទៅតាមអ្វីដែលគាត់យល់ឃើញថាគួរដាក់ឲ្យទណ្ឌិតនេះបំពេញ។ ប៉ុន្តែបើសិនជា គាត់បំពេញមិនបាននោះទេ គឺចៅក្រមអាចនឹងដកហូតអំពីការព្យួរទោសសាកល្បងនោះចោលវិញបាន។ ដូច្នេះហើយមាត្រា ១២០ នេះជាកាតព្វកិច្ចដោយឡែកដែលតុលាការជ្រើសរើសយកមកប្រើដោយក្នុងនោះគាត់ត្រូវមើលថា តើអ្វីដែលពាក់ព័ន្ធជាមួយនឹងជននោះដែលគាត់បានប្រព្រឹត្តបទល្មើស។ នេះគឺមិនមែនចេះតែដាក់ទាំងអស់ តាមតែចង់នឹកឃើញដាក់ទៅលើគេនោះទេ តែគាត់អាចជ្រើសរើសដាក់មួយ ឬច្រើនលើសពីមួយបាន។ សូមបញ្ជាក់ជូនថាកាតព្វកិច្ចនេះ គឺដាក់តែទៅលើនីតិជនដែលគាត់ប្រព្រឹត្តបទល្មើសប៉ុណ្ណោះ ពីព្រោះថា បទបញ្ញត្តិនៃមាត្រា ១២០ នេះ ចែងចំពោះតែនីតិជន។

ចំណែកឯ ចំពោះអនីតិជនវិញ នៅក្នុងករណីនៃការព្យួរទោសសាកល្បង មានតែកាតព្វកិច្ចដោយឡែក ៤ (ប្រាំបួន) ចំណុច តែប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជននោះរួមមាន ៖

១. ទទួលការបង្ហាត់បង្រៀន ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ។

២. ស្ថិតនៅទីកន្លែងមួយជាកំណត់។

៣. ដាក់ខ្លួនឲ្យពេទ្យពិនិត្យ ឬព្យាបាល។

៤. ជួសជុលព្យសនកម្មដែលបណ្តាលមកអំពីបទល្មើស ទៅតាមធនធានរបស់ខ្លួន។

---

[36] មាត្រា ១២០ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

៥. បង្ហាញភស្តុតាង[37] បញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយ តាមលទ្ធភាពនៃធនធានរបស់ខ្លួន បន្ទាប់ពីការផ្តន្ទាទោស។

៦. មិនត្រូវបង្ហាញមុខនៅទីកន្លែងខ្លះ។

៧. មិនត្រូវសេពគប់ ទីកន្លែងលក់ភេសជ្ជៈស្រវឹង។

៨. មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ដោយឡែកជាមួយសហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស។

៩. មិនត្រូវកាន់កាប់ ឬ យកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ[38]។

កាតព្វកិច្ចទាំង ៩ (ប្រាំបួន) ចំណុចខាងលើ គឺជាកាតព្វកិច្ចដោយឡែកដែលប្រើបាន ចំពោះតែអនីតិជនតែប៉ុណ្ណោះ។

### ៣.៣ ការដកហូតការព្យួរទោសសាកល្បង

ការដកហូតការព្យួរទោសសាកល្បង នៅក្នុងការព្យួរទោសសាកល្បង ក្រមព្រហ្មទណ្ឌបានប្បញ្ញត្តិអំពីលក្ខខណ្ឌ ដែលអាចឈានដល់ការព្យួរនូវទោសសាកល្បង មិនតែប៉ុណ្ណោះក្រមក៏បានប្បញ្ញត្តិការដកហូតនូវការព្យួរទោសសាកល្បងអាចត្រូវដកហូតដោយតុលាការផងដែរ នៅក្នុងករណីដូចខាងក្រោមនេះ ៖

១. បើក្នុងរយៈពេលសាកល្បង ទណ្ឌិតមិនគោរពតាមវិធានការត្រួតពិនិត្យ ឬកាតព្វកិច្ចដោយឡែកទេ។

២. ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាថ្មីទៀត។

តុលាការអាចបង្គាប់ឲ្យដកហូតការព្យួរទោសសាកល្បងនេះទាំងមូល ឬមួយផ្នែក។ នៅក្នុងករណីនេះទោសត្រូវយកមកអនុវត្តទាំងមូល ឬមួយផ្នែក។ តុលាការត្រូវបានទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌដែលមានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ[39]។ ដូច្នេះការព្យួរទោសសាកល្បង មានន័យថា តុលាការអាចដកហូតការព្យួរទោសសាកល្បងបាន ប្រសិនបើមានបណ្តឹងប្តឹងដោយព្រះរាជអាជ្ញាទាក់ទងជាមួយការមិនគោរពកាតព្វកិច្ចរបស់គាត់ ពីព្រោះថាពេលដែលគាត់ធ្វើកិច្ចការនៅក្រោមវិធានការត្រួតពិនិត្យក្តី ឬការបំពេញនូវកាតព្វកិច្ចដោយឡែកក្តី ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញាទាំងអស់ ហើយបើសិនជា បុគ្គលនោះមិនគោរពនូវកាតព្វកិច្ចណាមួយ ឬក៏មិនបំពេញនូវវិធានការត្រួតពិនិត្យណាមួយនោះទេ គឺព្រះរាជអាជ្ញាគាត់អាច ប្តឹងសុំទៅចៅក្រមដើម្បីឲ្យដកហូតនូវការព្យួរទោសសាកល្បងចោលទៅវិញ ព្រោះថាក្នុងរយៈពេលសាកល្បងនេះ គាត់ត្រូវតែ

[37] **ភស្តុតាង** គឺជាព័ត៌មានគ្រប់ប្រភេទរួមមាន ឯកសារ ព្រឹត្តិការណ៍ វត្ថុជាក់ស្តែង ដែលដាក់បង្ហាញនៅពេលស៊ើបអង្កេត ស៊ើបសួរ ឬសវនាការដើម្បីបង្ហាញពីអត្ថិភាព (ការកើតមាន) នៃអង្គហេតុជាក់លាក់។ សទ្ទានុក្រមពាក្យច្បាប់ខ្មែរ-អង់គ្លេស-បារាំង ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ លេខរៀងទី ១៩៤

[38] មាត្រា ១៦៥ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[39] មាត្រា ១២២ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

បំពេញនូវកាតព្វកិច្ចដោយទៀងទាត់ ឬវិធានការត្រួតពិនិត្យទាំងអស់នេះ។ ប្រសិនបើព្រះរាជអាជ្ញាតាមដាននៅក្នុងរយៈពេលដែលតុលាការកំណត់ឲ្យសាកល្បងនោះ តែគាត់មិនបានបំពេញនូវកាតព្វកិច្ចណាមួយទេ ឬមួយក្នុងរយៈពេលសាកល្បងនេះ បើគាត់បានប្រព្រឹត្តបទឧក្រិដ្ឋ បទមជ្ឈិមណាមួយជាថ្មីទៀតដែលមិនទាន់ហួសរយៈពេលកំណត់ផង គាត់ក៏ទៅប្រព្រឹត្តបទល្មើសថ្មីមួយផ្សេងទៀត នោះព្រះរាជអាជ្ញាអាចប្ដឹងទៅចៅក្រម ដើម្បីឲ្យតុលាការធ្វើការសម្រេចដកហូតអំពីការព្យួរទោសសាកល្បងវិញបាន។

# ជំពូក៣៖
# យន្តការសំខាន់ៗនៃរបបនៃ
# ការប្រកាសទោស

# ជំពូកទី៣

# យន្តការសំខាន់ៗនៃរបបនៃការប្រកាសទោស

នៅក្នុងយន្តការសំខាន់ៗនៃរបបនៃការប្រកាសទោសនេះ វាមានលក្ខណៈជាចិត្តសាស្ត្រមួយ ដែលមានលក្ខណៈពិសេសដើម្បីកែប្រែ កាលបើទណ្ឌិតមិនមានលក្ខណៈកែប្រែទេនោះ ទណ្ឌិតត្រូវបានគេបង្ខំដល់រូបកាយដើម្បីអនុវត្តនៅក្នុងពន្ធនាគារជាដើម ដែលយន្តការទាំងនេះរួមមាន របបនៃការផ្អាកការប្រកាសទោស (១) របបពាក់កណ្ដាលសេរីភាព (២) និងការបែងចែកទោសជាប្រភាគ (៣)។

## ផ្នែកទី១. របបនៃការផ្អាកការប្រកាសទោស

របបនៃការផ្អាកការប្រកាសទោស ជាការផ្អាកការប្រកាសដោយតុលាការនូវទោសណាមួយដើម្បីអាចយកទោសនោះមកអនុវត្ត និងជាការសម្រេចពង្រឹងលទ្ធភាពធ្វើឯកត្តកម្មនូវទោសដែលត្រូវបានប្រគល់ជូនតុលាការ[40]។ បន្ទាប់ពីបានយល់នូវខ្លឹមសារនៃការផ្អាកការប្រកាសទោសរួចមក យើងនឹងត្រូវស្វែងយល់នូវលក្ខខណ្ឌនៃការផ្អាកការប្រកាសទោស (១.១) និងសវនាការពិនិត្យរឿងដែលបង្អង់ និងភាពខុសគ្នារវាងការផ្អាកការប្រកាស និងការផ្អាកសវនាការនាពេលសព្វថ្ងៃ (១.២) ដូចខាងក្រោម ៖

### កថាខណ្ឌទី១. លក្ខខណ្ឌនៃការផ្អាកការប្រកាសទោស

លក្ខខណ្ឌដែលនាំឱ្យមានការផ្អាកនូវ របបនៃការផ្អាកការប្រកាសទោស វាទាក់ទងនិងលក្ខខណ្ឌធំៗចំនួន ២ គឺ បទល្មើសដែលត្រូវចោទប្រកាន់ (១.១) និងវត្តមានជនជាប់ចោទនៅក្នុងសវនាការ (១.២) ដើម្បីយល់ឱ្យកាន់តែច្បាស់យើងនឹងធ្វើការបកស្រាយដូចខាងក្រោម ៖

#### ១.១ បទល្មើសដែលត្រូវចោទប្រកាន់

នៅក្នុងការផ្អាកការប្រកាសទោស អាចធ្វើការអនុវត្តបានចំពោះតែបទល្មើសមជ្ឈិមប៉ុណ្ណោះនេះមានន័យថា ជាស្ថានភាពមួយនៅពេលតុលាការធ្វើការចោទប្រកាន់អំពីបទមជ្ឈិម ហើយឈានទៅដល់ការសម្រេចប្រកាសទទួលស្គាល់ថា ជនជាប់ចោទមានពិរុទ្ធភាព ក៏ប៉ុន្តែចៅក្រមមិនប្រកាសទោសនៅពេលនោះតែម្តងទេ គឺចៅក្រមអាចផ្អាកការប្រកាសទោសដោយឈរលើស្ថានភាព ៣ (បី) យ៉ាង[41] គឺភាពច្របូកច្របល់នៃសណ្ដាប់ធ្នាប់សាធារណៈដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ឈប់ (ក) ជនជាប់ចោទបានបង្ហាញនូវការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ (ខ) និងជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត (គ)។

---

[40] យោងតាម " មេរៀននីតិព្រហ្មទណ្ឌ " នៃសហប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ ដោយផ្អែកលើអត្ថបទនៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ខែធ្នូ ឆ្នាំ២០០៧

[41] យោងតាមប្រសាសន៍របស់ ឯកឧត្តម ផូវ សំភី អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារ សេចក្តីព្រាងក្រមព្រហ្មទណ្ឌ នៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយ ក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា

**ក. ភាពច្របូកច្របល់នៃសណ្តាប់ធ្នាប់សាធារណៈដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ឈប់**

ភាពច្របូកច្របល់នៃសណ្តាប់ធ្នាប់សាធារណៈដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ឈប់ មានន័យថា បើយើងគិតអំពីសារជាតិនៃបទល្មើសដែលប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ដែលផលប៉ះពាល់ ឬភាពរឹករវដែលបង្កឡើងដោយបទល្មើសវាទាក់ទងជាមួយនឹងការធ្វើឱ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃនេះវាមិនមានអនុភាពជាចិត្តសាស្ត្រ ឬក៏ធ្វើឱ្យរន្ធត់ដល់សង្គម ទៅដល់ភូមិ ឃុំ ដែលបទល្មើសនោះបានកើតឡើងទេ ហេតុដូច្នេះវាអាចត្រូវបានបញ្ឈប់ភ្លាមៗ។

**ខ. ជនជាប់ចោទបានបង្ហាញនូវការធានា ក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ**

ជនជាប់ចោទបានបង្ហាញនូវការធានា ក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ គឺពាក់ព័ន្ធទៅនឹងឥរិយាបទរបស់ជនល្មើស អំពីការសន្យារបស់គាត់ថានឹងកែប្រែខ្លួនដើម្បីក្លាយជាពលរដ្ឋល្អនៅក្នុងសង្គមរបស់គាត់វិញ ឬគេអាចនិយាយម្យ៉ាងទៀតបានថា បុគ្គលដែលបានប្រព្រឹត្តនូវបទល្មើស មានការកែប្រែនូវ ចរិតមាយាទ និងធានាថាខ្លួននឹងមិនប្រព្រឹត្តនូវអំពើណាមួយដែលនាំឱ្យមានភាពល្អក់កករ ឬប៉ះពាល់ដល់សង្គម ហើយគាត់ក៏សន្យានិងអប់រំខ្លួនឱ្យបានក្លាយជាមនុស្សដ៏ល្អម្នាក់ផងដែរ។

**គ. ជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត**

ជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត បានន័យថា នៅពេលដែលប្រកាសផ្តន្ទាទោសជននោះ គឺគាត់មិនទាន់មានលុយសងទេ ដូច្នេះគាត់សុំឱ្យទុករយៈពេល ដើម្បីឱ្យគាត់មានពេលអាចទៅរកស៊ីប្រកបរបរ ឬក៏ធ្វើការក្នុងគោលបំណងយកប្រាក់ទៅជួសជុលការខូចខាត។ ហេតុដូច្នេះហើយយើងឃើញថា នៅក្នុងសារជាតិនៃបទល្មើស នេះគឺជាបទមជ្ឈិមហើយជាបទល្មើសដែលពាក់ព័ន្ធនឹងការធ្វើឱ្យខូចខាតនូវទ្រព្យរបស់អ្នកដទៃ ប៉ុន្តែក៏អាចមានបទល្មើសផ្សេងៗទៀត ដូចជាបទល្មើសដែលច្បាប់ឱ្យឈ្មោះថា **"អំពើហិង្សាស្រាល"** ដែលនេះគឺអាចជាកម្មវត្ថុក្នុងការផ្អាកការប្រកាសទោសដែរ។

ដូចនេះចំណុចទាំងបីខាងលើ អាចបំពេញបានគ្រប់នៅក្នុងលក្ខខណ្ឌនៃបទល្មើសដែលត្រូវចោទប្រកាន់អំពីបទមជ្ឈិមនោះ។ ប៉ុន្តែបើយើងពិនិត្យមើលឱ្យបានច្បាស់ថា លក្ខខណ្ឌខាងលើអាចធ្វើទៅបានលុះត្រាតែ បទល្មើសនោះមិនមានលក្ខណៈជាធ្ងន់ធ្ងរនោះទេ ជាក់ស្តែងដូចជាបទមជ្ឈិមស្រាល តែវាមិនទាំងស្រុងនោះទេកាលបើតុលាការយល់ឃើញថា វាមានភាពល្អប្រសើរសម្រាប់បុគ្គលនោះខ្លួនឯងក៏ដូចជាសង្គមផងដែរ។

**១.២ ជនជាប់ចោទត្រូវតែមានវត្តមាននៅពេលសវនាការ**

យោងទៅតាមមាត្រា ១២៥ នៃក្រមព្រហ្មទណ្ឌ បានកំណត់ថាការផ្អាកការប្រកាសទោស អាចត្រូវបង្គាប់បានលុះត្រាតែជនជាប់ចោទមានវត្តមានក្នុងសវនាការ។ តុលាការកំណត់នៅក្នុងសាលក្រមឬសាលដីការ

នូវកាលបរិច្ឆេទដែលត្រូវសម្រេចអំពីទោស។[42] សេចក្ដីសម្រេចអំពីទោស ត្រូវតែធ្វើឡើងយ៉ាងយូរបំផុត ១ (មួយ) ឆ្នាំ ក្រោយសេចក្ដីសម្រេចផ្អាក ហេតុនេះទាល់តែបានបំពេញនូវលក្ខខណ្ឌនេះផងដែរ ទើបតុលាការអាចបង្គាប់ឱ្យមានផ្អាកការប្រកាសទោសទៅបាន ហើយពិសេសទៅទៀតនៅក្នុងសាលក្រម ឬសាលដីកា ដែលសម្រេចអំពីការផ្អាកការប្រកាសទោសនោះ គឺតុលាការកំណត់ពីរយៈពេលថាតើថ្ងៃណា ពេលណា ម៉ោងប៉ុន្មាន ទើបត្រូវបើកសវនាការសាជាថ្មីដើម្បីសម្រេចអំពីទោសចំពោះករណីនេះ។ បើយោងតាមក្រមព្រហ្មទណ្ឌ ក៏បានកំណត់ថាសវនាការដែលលើកឡើងដើម្បីសម្រេចអំពីទោសទាក់ទងនឹងករណីនេះ គឺមានរយៈពេលយ៉ាងយូរបំផុតត្រឹម ១(មួយ) ឆ្នាំ។

**កថាខណ្ឌទី២៖ សវនាការពិនិត្យរឿងដែលបង្អង់ និងភាពខុសគ្នារវាងការផ្អាកការប្រកាស និងការផ្អាកការសវនាការនាពេលសព្វថ្ងៃ**

សវនាការដែលពិនិត្យរឿងក្ដីដែលបង្អង់នេះ តុលាការសម្រេចអំពីទោស ដែលត្រូវបានបញ្ញត្តិយ៉ាងជាក់លាក់នៅក្នុងមាត្រា១២៦ នៃក្រមព្រហ្មទណ្ឌ (ក)។ ចំណែកឯភាពខុសគ្នារវាងការផ្អាកការប្រកាសទោស និងការផ្អាកសវនាការនាពេលសព្វថ្ងៃ គឺយោងទៅតាមបទពិសោធន៍ជាក់ស្ដែងក្នុងតុលាការក្រមព្រហ្មទណ្ឌ(ខ)។

**១.១. សវនាការពិនិត្យរឿងដែលបង្អង់**

នៅពេលសវនាការពិនិត្យរឿងដែលបង្អង់ តុលាការសម្រេចអំពីទោស[43] បានន័យថាដោយសារតែមានមូលដ្ឋានដែលជាលក្ខខណ្ឌនៃមាត្រា ១២៤ និងមាត្រា ១២៥ ទើបតុលាការបង្អង់រឿងក្ដីនោះទុកសិន លុះដល់ពេលមួយកំណត់ ទើបតុលាការយករឿងដែលបង្អង់នោះមកសម្រេចអំពីទោសឡើងវិញ។

**១.២. ភាពខុសគ្នារវាងការផ្អាកការប្រកាស និងការផ្អាកសវនាការនាពេលសព្វថ្ងៃ**

សូមបញ្ជាក់អំពីករណីនៃការផ្អាកការប្រកាសជាមួយនឹងករណីដែលយើងឃើញថាសព្វថ្ងៃ នៅក្នុងតុលាការនៃព្រះរាជាណាចក្រកម្ពុជាយើងគឺ តុលាការបានបើកសវនាការហើយតែគាត់មិនបានប្រកាសសាលក្រមភ្លាមៗនៅក្នុងថ្ងៃនោះទេ ប៉ុន្តែគាត់ក៏លើកពេលសវនាការទៅថ្ងៃក្រោយវិញ។ ទាំងនេះគឺជាករណីផ្សេងខុសដាច់ដោយឡែកពីគ្នា ឬមួយក៏វាជាករណីផ្ទុយគ្នាទៅនឹងការផ្អាកការប្រកាសទោស ដែលមានចែងនៅក្នុងស្មារតីនៃក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ១២៤ ដល់មាត្រា ១២៦។ ក្នុងករណីនេះដែរ នៅពេលតុលាការបើកសវនាការតុលាការយល់ឃើញថា ត្រូវសម្រេចឱ្យជនជាប់ចោទមានពិរុទ្ធ គាត់ក៏ផ្អាកការប្រកាសទោសតាមលក្ខខណ្ឌដោយមានកំណត់ចែងក្នុងមាត្រា ១២៤ ដែលមាន៣ចំណុច។ លុះ ៨ (ប្រាំបី) ខែក្រោយមក ទើបតុលាការបើកសវនាការដើម្បីសម្រេចអំពីទោស ដូច្នេះនៅពេលបើកសវនាការនោះតុលាការត្រូវសម្រេចអំពីទោសផងដែរនៅ

[42] មាត្រា ១២៥ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[43] មាត្រា ១២៦ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

ពេលនោះហើយតុលាការនឹងពិនិត្យអំពីឥរិយាបថរបស់ជនជាប់ចោទថា តើគាត់បានធ្វើអ្វីខ្លះ ដើម្បីបង្ហាញគាត់បានចូលរួមរស់នៅក្នុងសង្គមវិញនោះ? តើគាត់បានធ្វើអ្វីខ្លះទាក់ទងជាមួយនិងការជួសជុលការខូចខាត? ហេតុនេះប្រសិនបើជាឃើញថាមានស្ថានភាពដូចដែលបានលើកឡើងខាងលើនោះ តុលាការអាចជ្រើសរើសទោសដែលផ្តល់នូវស្ថានសម្រាល ឬមួយក៏គាត់ប្រកាសទោសជំនួស ត្រង់នេះមានន័យថា គាត់អត់ប្រកាសទោសជាប់ពន្ធាគារ ឬក៏ទោសពិន័យជាប្រាក់ទេ តែគាត់ប្រកាសទោសជំនួសដែលជាទោសស្តីបន្ទោស ឬទោសការងារសហគមន៍។ ដូច្នេះការផ្អាកការប្រកាសទោស សូមបញ្ចប់ការបកស្រាយតែត្រឹមប៉ុណ្ណឹង ក៏ប៉ុន្តែនៅមានការប្រកាសទោស មួយទៀតដែលជាយន្តការថ្មីដែរគឺទាក់ទងនឹង **របបពាក់កណ្តាលសេរីភាព ៖**

## ផ្នែកទី ២៖ របបពាក់កណ្តាលសេរីភាព

របបពាក់កណ្តាលសេរីភាព គឺជារបបនៃការអនុវត្តទោសដែលអនុញ្ញាត ឲ្យទណ្ឌិតអាចចេញពីពន្ធនាគារទៅបំពេញសកម្មភាពវិជ្ជាជីវៈក្នុងរយៈពេលមានកំណត់[44]។ យន្តការនៃរបបពាក់កណ្តាលសេរីភាពនេះ គឺជានាវានុវត្តន៍មួយនៅក្នុងនីតិព្រហ្មទណ្ឌ។ តាមការពិត ប្រពៃណីគតិយុត្តខ្មែរ ធ្លាប់ស្គាល់រួចមកហើយនូវរបបនៃការដោះលែងដោយមានលក្ខខណ្ឌ ប៉ុន្តែពុំមែនជារបបពាក់កណ្តាលសេរីភាពទេ។ វិធានការឯកត្តកម្មនេះ អនុញ្ញាតឲ្យទណ្ឌិតរក្សាបាននូវកិច្ចការវិជ្ជាជីវៈរបស់ខ្លួន ទំនាក់ទំនងគ្រួសារ ឬទទួលនូវការបង្ហាត់បង្រៀន ឬការពិនិត្យព្យាបាលជំងឺ នៅក្រៅគ្រឹះស្ថានពន្ធនាគារ។ ប៉ុន្តែ របបពាក់កណ្តាលសេរីភាពនេះអាចប្រកាសបាន ចំពោះតែទោសពន្ធនាគាររយៈពេលខ្លី មានន័យថាតិចជាង ឬស្មើនឹង ៦ (ប្រាំមួយ) ខែប៉ុណ្ណោះ។[45] ដើម្បីធ្វើការពិភាក្សាវែកញែកឲ្យបានស៊ីជម្រៅទៅលើយន្តការនេះ យើងនឹងបែងចែកលក្ខខណ្ឌ និងបែបបទនៃរបបពាក់កណ្តាលសេរីភាព(១) និងចំណុចផ្សេងទៀតនៃរបបពាក់កណ្តាលសេរីភាព(២) ដែលនឹងធ្វើការបកស្រាយទាំងស្រុងដូចបានសរសេរបង្ហាញជូនខាងក្រោម៖

### កថាខណ្ឌទី១៖ លក្ខខណ្ឌ និងបែបបទនៃរបបពាក់កណ្តាលសេរីភាព

នៅក្នុងរបបពាក់កណ្តាលសេរីភាព អាចអនុវត្តទៅបានលុះត្រាតែមានបំពេញនូវលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ១២៧ (១.១) និងមាត្រា ១២៨ នៃក្រមព្រហ្មទណ្ឌ បានចែងអំពីបែបបទនៃរបបពាក់កណ្តាលសេរីភាព (១.២) ជាមុនសិន មុននឹងឈានទៅដល់តុលាការសម្រេចអំពីរបបពាក់កណ្តាលសេរីភាពចំពោះទណ្ឌិតនិងយកមកអនុវត្តបាន។

[44] សទ្ទានុក្រមពាក្យច្បាប់ច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀង ១៩៨
[45] យោងតាម " មេរៀននីតិព្រហ្មទណ្ឌ " នៃសហប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ ដោយផ្អែកលើអត្ថបទនៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ខែធ្នូ ឆ្នាំ២០០៧

### ១.១ លក្ខខណ្ឌនៃរបបពាក់កណ្ដាលសេរីភាព

ផ្អែកតាមមាត្រា ១២៧ បានកំណត់យ៉ាងច្បាស់ហើយថា បើកាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ៦ (ប្រាំមួយ) ខែ នោះតុលាការអាចសម្រេចថា ទោសដែលត្រូវអនុវត្តក្រោមរបបពាក់កណ្ដាលសេរីភាព ដើម្បីអនុញ្ញាតឲ្យទណ្ឌិតអាចបំពេញសកម្មភាពវិជ្ជាជីវៈ ទទួលការសិក្សា ការបណ្ដុះបណ្ដាល ពិនិត្យព្យាបាលជំងឺ ឬជួយឧបត្ថម្ភដល់សេចក្ដីត្រូវការរបស់គ្រួសារ។ ដូច្នេះមានបទល្មើសមួយចំនួនអាស្រ័យទៅលើសាលក្រមរបស់តុលាការ បើកាលណាតុលាការសម្រេចដាក់ពន្ធនាគារមិនលើសពី ៦ (ប្រាំមួយ) ខែទេនោះទោសអាចអនុវត្តនៅក្រោមរបបពាក់កណ្ដាលសេរីភាពបាន។

### ១.២ បែបបទនៃរបបពាក់កណ្ដាលសេរីភាព

ទណ្ឌិតដែលស្ថិតនៅក្រោម "របបពាក់កណ្ដាលសេរីភាព" ត្រូវបានអនុញ្ញាតឲ្យចាកចេញពីពន្ធនាគារក្នុងរយៈពេលជាកំណត់។ តុលាការកំណត់នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនអំពីថ្ងៃ និងម៉ោងដែលទណ្ឌិតត្រូវបានអនុញ្ញាតឲ្យអវត្តមាននៅក្នុងពន្ធនាគារ ឬឲ្យចាកចេញពីពន្ធនាគារ និងទៅបំពេញកិច្ចការណាមួយដែលជាការយល់ឃើញរបស់តុលាការ។

## កថាខណ្ឌទី២៖ ចំណុចផ្សេងៗទៀតនៃរបបពាក់កណ្ដាលសេរីភាព

ក្រៅអំពីលក្ខខណ្ឌ និងបែបបទនៃរបបពាក់លណ្ដាលសេរីភាពដូចមាន ពន្យល់ខាងលើរួចហើយ ក៏ប៉ុន្តែនូវមានចំណុចពាក់ពន្ធដទៃផ្សេងទៀត ដែលសំខាន់នៅក្នុងយន្តការនេះដូចជា ការគិតបញ្ចូលនូវរយៈពេលនៃការអនុវត្តផងដែរ (២.១) ហើយនៅពេលដែលគេអាចជ្រើសរើសយកនូវរបបពាក់កណ្ដាលសេរីភាពបាន គេក៏អាចដកហូតមកវិញបានដែរ (២.២) ខណៈដែលបុគ្គលដែលមាននូវកាតព្វកិច្ចនៅក្នុងការអនុវត្ត ហើយមិនគោរពតាមទេនោះ គេនឹងមាននូវវិធានការដែលត្រូវដកហូតមកវិញ ហើយបុគ្គលត្រូវបានចូលទៅអនុវត្តទោសក្នុងពន្ធនាគារវិញ (២.៣)។

### ២.១ ការគិតបញ្ចូលរយៈពេលនៃរបបពាក់កណ្ដាលសេរីភាពនៅក្នុងទោស

ការគិតបញ្ចូលរយៈពេលនៃរបបពាក់កណ្ដាលសេរីភាពទៅក្នុងទោស[46] នៅក្នុងរបបនេះរយៈពេលនៃរបបពាក់កណ្ដាលសេរីភាព ត្រូវគិតបញ្ចូលទៅក្នុងចិរវេលានៃទោសដែលកំពុងតែអនុវត្តនោះ ពីព្រោះនៅក្នុងរយៈពេលនៃរបបពាក់កណ្ដាលសេរីភាពករណីដូចជាការអនុញ្ញាតឲ្យទណ្ឌិតអាចបំពេញសកម្មភាពវិជ្ជាជីវៈទទួលការសិក្សា ការបណ្ដុះបណ្ដាល ពិនិត្យព្យាបាលជំងឺ ឬជួយឧបត្ថម្ភដល់សេចក្ដីត្រូវការរបស់គ្រួសារទាំងនេះគឺជារយៈពេលនៃការអនុវត្តទោសរួចទៅហើយ។

---

[46] មាត្រា១២៩ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

### ២.២ ការរៀបចំ និងការលុបចោលនៃរបបពាក់កណ្ដាលសេរីភាព

នៅគ្រប់ពេលវេលាទាំងអស់ តុលាការអាចរៀបចំរយៈពេលនៃរបបពាក់កណ្ដាលសេរីភាព ឬក៏លុបចោលនូវរបបពាក់កណ្ដាលសេរីភាព តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា បានសេចក្ដីថាតុលាការអាចបន្ថែម ឬបន្ថយរយៈពេលនៃរបបពាក់កណ្ដាលសេរីភាព ឬមួយក៏ឈប់ប្រើប្រាស់នូវរបបពាក់កណ្ដាលសេរីភាពនេះតទៅទៀត ចំពោះរឿងក្ដីមួយបានគ្រប់ពេលវេលា ប្រសិនបើមានការប្ដឹងសុំពីព្រះរាជអាជ្ញា ឬចៅក្រមអយ្យការ[47] ឬភាគីពាក់ព័ន្ធ។ តុលាការ ត្រូវបានទទួលដំណឹងនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ចំណុចនេះអាចដូចទៅនឹងករណីដែលមានចែងនៅក្នុងមាត្រា ៥៩៦ ពាក់ពន្ធទៅនឹងបទប្បញ្ញត្តិស្ដីពីការអនុវត្តទោសមួយចំនួន។ មាត្រានេះបានចែងថា ចំពោះវិវាទទាក់ទងនឹងការអនុវត្តទោសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ តុលាការទទួលដំណឹងពីព្រះរាជអាជ្ញាតាមរយៈពាក្យសុំធម្មតា។ ហើយអយ្យការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការទៅដល់ភាគីពាក់ព័ន្ធ។

### ២.៣ ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត

ព្រះរាជអាជ្ញាអាចបង្គាប់ឲ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនព្រមវិលត្រលប់មកក្នុងពន្ធនាគារវិញ នៅពេលដែលផុតកំណត់រយៈពេលនៃរបបពាក់កណ្ដាលសេរីភាព[48] ពីព្រោះការអនុវត្តនូវរបបនេះ ត្រូវស្ថិតនៅក្រោមការតាមដានរបស់ព្រះរាជអាជ្ញា បានន័យថាបើតុលាការកំណត់ថាដល់ពេលត្រូវចូលទៅក្នុងពន្ធនាគារវិញហើយស្រាប់តែដល់ម៉ោងអត់ឃើញទៅដល់ទេ ហើយថែមទាំងគ្មានមូលហេតុសមស្របនោះព្រះរាជអាជ្ញាអាចចេញបញ្ជាឲ្យចាប់ខ្លួនទណ្ឌិតដែលគេចខ្លួនដើម្បីយកមកអនុវត្តទោសនៅក្នុងពន្ធនាគារវិញ។

ជាបន្តទៅទៀតនេះ យើងសូមលើកយកនូវយន្តការមួយទៀតសម្រាប់សង្គមកម្ពុជាដែលបានប្បញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌ គឺ"**ការបែងចែកទោសជាប្រភាគ**" ដើម្បីយល់ឲ្យកាន់តែច្បាស់ថា តើរបបនេះមានលក្ខណៈបែបណានោះ យើងនឹងធ្វើការបកស្រាយដូចខាងក្រោម៖

## ផ្នែកទី៣៖ ការបែងចែកទោសជាប្រភាគ

ការបែងចែកទោសជាប្រភាគ ជាប្រភេទស្ថានសម្រាលទោសមួយដែលតុលាការយល់ថាទោសនោះត្រូវអនុវត្តជាប្រភាគដោយមូលហេតុធ្ងន់ធ្ងរដែលមានលក្ខណៈជាគ្រួសារ ជាវេជ្ជសាស្ត្រ ជាវិជ្ជាជីវៈ ឬជាសង្គម[49]។ នេះជាវិធានការឯកត្តកម្មតុលាការមួយផ្សេងទៀត ដែលតម្រូវឲ្យអនុវត្តទោសជាប់ពន្ធនាគារតិចជាង ឬស្មើនឹង ១ (មួយ) ឆ្នាំដោយប្រភាគ។ ដើម្បីអាចទទួលនូវរបបនេះបានលុះត្រាតែមានការឆ្លើយតបទៅនឹងលក្ខខណ្ឌ និង

---

[47] មាត្រា ៥០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[48] មាត្រា ១៣១ នៃក្រមព្រហ្មទណ្ឌ, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[49] សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែកក្រមព្រហ្មទណ្ឌ ទីស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ១០

បែបបទនៃការបែងចែកនូវទោសជាប្រភាគនេះជាមុនសិន (១) បន្ទាប់មកយើងនឹងធ្វើការប្រៀបធៀបគ្នារវាងយន្តការទាំងពីរ គឺភាពដូច និងខុសគ្នារវាងការបែងចែកទោសជាប្រភាគ ជាមួយនឹងរបបពាក់កណ្ដាលសេរីភាព(២) ដោយស្វែងយល់ពីលក្ខណៈពិសេសរបស់វា។

**កថាខណ្ឌទី១៖ លក្ខខណ្ឌ និងបែបបទនៃការបែងចែកទោសជាប្រភាគ**

នៅគ្រប់យន្តការទាំងអស់នៅក្នុងរបបនៃការប្រកាសទោស ដើម្បីទទួលបាននូវរបបនីមួយៗដាច់ខាតត្រូវតែបំពេញនូវលក្ខខណ្ឌក៏ដូចជាបែបបទដើម្បីទទួលបាននូវយន្តការណាមួយដែលតម្រូវជាក់ស្តែងដូចជា របបនៃការបែងចែកទោសជាប្រភាគ ក៏មិនខុសពីយន្តការមុនៗដែរ ដោយត្រូវបំពេញនូវលក្ខខណ្ឌដូចមានបញ្ញត្តិក្នុងច្បាប់ (១.១) ហើយបើចំពោះតែលក្ខខណ្ឌគឺមិនមានលក្ខណៈគ្រប់គ្រាន់អាចយកទៅអនុវត្តបានទេ ពោលគឺត្រូវតែមានបែបបទដើម្បីបញ្ជាក់អំពីនីតិវិធីនៃរយៈពេលទៀតទើបគេអាចយកមកអនុវត្តបាន (១.២)។

**១.១ លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ**

យោងតាមមាត្រា ១៣២ បានកំណត់ថា កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ១ (មួយ) ឆ្នាំ តុលាការអាចសម្រេចថា ទោសនោះត្រូវអនុវត្តជាប្រភាគ ដោយមូលហេតុធ្ងន់ធ្ងរដែលមានលក្ខណៈជាគ្រួសារ ជាវេជ្ជសាស្ត្រ ជាវិជ្ជាជីវៈ ឬជាសង្គម។ មានបទល្មើសមួយចំនួន គឺអាស្រ័យទៅលើសាលក្រមរបស់តុលាការ បើថាតុលាការសម្រេចដាក់ពន្ធនាគារមិនលើសពី ១ (មួយ) ឆ្នាំទេ ទោសនោះអាចអនុវត្តនៅក្រោមការបែងចែកទោសជាប្រភាគបាន។

**១.២ បែបបទនៃការបែងចែកទោសជាប្រភាគ**

ប្រភាគនៃទោសនីមួយៗ មិនត្រូវតិចជាង ១ (មួយ) ខែទេ។ ចិរវេលាសរុបនៃការអនុវត្តទោសមិនអាចលើសពី២(ពីរ)ឆ្នាំទេ ដោយរាប់បញ្ចូលទាំងការផ្អាកការអនុវត្តទោស។ តុលាការកំណត់ក្នុងសេចក្តីសម្រេចរបស់ខ្លួនអំពីបែបបទនៃការបែងចែកទោសជាប្រភាគ។ ដូច្នេះក្នុងឃ្លានេះមានន័យថា ចំណុចនៃរូបមន្តក្នុងការបែងចែកទោសជាប្រភាគ គឺជាទោសដាក់ពន្ធនាគារនីមួយៗ ត្រូវបែងចែកមិនឲ្យតិចជាង ១ (មួយ) ខែឡើយ ហើយចិរវេលាដែលត្រូវអនុវត្តគឺមិនត្រូវឲ្យលើសពី ២ (ពីរ) ឆ្នាំទេ ដោយត្រូវបូកបញ្ចូលទាំងរយៈពេលនៃការផ្អាកការអនុវត្តទោសផងដែរ។

**កថាខណ្ឌទី២៖ ភាពដូចគ្នា និងភាពខុសគ្នារវាងការបែងចែកទោសជាប្រភាគ និងរបបពាក់កណ្ដាលសេរីភាព**

យើងនឹងធ្វើការបែងចែកនូវភាពដូចគ្នា និងភាពខុសគ្នារវាងការបែងចែកទោសជាប្រភាគ និងរបបពាក់កណ្ដាលសេរីភាព ដោយសូមចាប់ផ្ដើមធ្វើការបកស្រាយពីភាពដូចគ្នាជាមុនសិន (២.១) មុននឹងឈានចូលទៅ

សិក្សាអំពីភាពខុសគ្នា **(២.២)** ដើម្បីដឹងថាដូចគ្នា ឬខុសគ្នាបែបណានោះ យើងនឹងធ្វើការបកស្រាយដូចខាងក្រោម៖

### ២.១ ភាពដូចគ្នារវាងការបែងចែកទោសជាប្រភាគ និងរបបពាក់កណ្ដាលសេរីភាព

ជាការពិតណាស់ ការបែងចែកទោសជាប្រភាគក្ដី ជារបបពាក់កណ្ដាលសេរីភាពក្ដី សុទ្ធតែមានគោលដៅធ្វើយ៉ាងណាមិនឲ្យទណ្ឌិត ដែលស្ថិតនៅក្នុងរយៈពេលនៃការអនុវត្តទោសនោះត្រូវកាត់ផ្ដាច់ចេញពីទំនាក់ទំនងគ្រួសារ ទំនាក់ទំនងវេជ្ជសាស្ត្រ ទំនាក់ទំនងវិជ្ជាជីវៈ ឬទំនាក់ទំនងសង្គម។ បើយោងតាមការបកស្រាយខាងលើយើងឃើញថារបបទាំងពីរមានលក្ខណៈដូចគ្នានូវចំណុចមួយចំនួនដូចជា លក្ខខណ្ឌដែលទទួលបាន **(ក)** ការបែងចែកកែប្រែ ឬលុបចោល**(ខ)** និងការចាប់ខ្លួនទណ្ឌិត**(គ)** ដែលយើងនឹងបកស្រាយនូវភាពដូចគ្នាទាំងពីរនេះដូចខាងក្រោម៖

#### ក. លក្ខខណ្ឌដែលទទួលបាន

នៅក្នុងលក្ខខណ្ឌដែលបុគ្គលស្ថិតនៅក្នុងស្ថានភាព ដែលអាចឈានទៅដល់ការទទួលបាននូវរបបពាក់កណ្ដាលសេរីភាពក៏ដូចជាការបែងចែកទោសជាប្រភាគបាន គឺសុទ្ធតែស្ថិតនៅក្នុងស្ថានភាពដែលត្រូវបានផ្ដន្ទាទោសមិនអាចលើសពី ៦ (ប្រាំមួយ) ខែ ចំពោះរបបពាក់កណ្ដាលសេរីភាព និង១ (មួយ) ឆ្នាំ ចំពោះការបែងចែកទោសជាប្រភាគ។ ជាក់ស្ដែង កាលដែលមានការទទួលបាននូវការផ្ដន្ទាទោសព្រហ្មទណ្ឌដោយមិនលើសពី ១ (មួយ) ឆ្នាំនេះ វាស្ថិតនៅក្នុងស្ថានភាពមួយមិនជាមាននូវបញ្ហាធ្ងន់ធ្ងរដល់សង្គមនោះទេ ពោលគឺជាទោសមជ្ឈិមថ្នាក់ទី២[50] តែប៉ុណ្ណោះ។ ទោសមជ្ឈិមថ្នាក់ទី២ នេះ គឺជាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ ឬពិន័យជាប្រាក់ចាប់ពី ១២០,១០០ រៀលទៅ ៤០០,០០០ រៀល។

#### ខ. ការកែប្រែរបបនៃការបែងចែកទោសជាប្រភាគ

ស្របទៅតាមមាត្រា ១៣៤ និងមាត្រា ១៣០ នៃក្រមព្រហ្មទណ្ឌ គឺមានអត្ថន័យដូចគ្នា។ គ្រាន់តែនៅក្នុងរបបពាក់កណ្ដាលសេរីភាព បានប្រើពាក្យថា "**ការរៀបចំ និងការលុបចោល**" ចំណែកឯការបែងចែកទោសជាប្រភាគគេប្រើនូវពាក្យ "**ការកែប្រែ**"។ តែបើតាមអត្ថន័យពិតប្រាកដ ឬស៊ីជម្រៅគឺការរៀបចំ និងលុបចោល ដូចតែគ្នាទៅនឹងការកែប្រែទេ ព្រោះនៅក្នុងមាត្រា ១៣៤ បានចែងថានៅគ្រប់ពេលវេលា តុលាការអាចរៀបចំបែបបទនៃការបែងចែកទោសជាប្រភាគ ឬលុបចោលនូវរបបនៃការបែងចែកទោសជាប្រភាគ ផ្អែកតាមបណ្ដឹងរបស់ព្រះរាជអាជ្ញា។ ហេតុដូច្នេះហើយទើបតុលាការអាចបន្ថែម ឬបន្ថយរយៈពេលនៃការបែងចែកទោសជាប្រភាគទៅតាមចន្លោះនៃការកំណត់របស់ច្បាប់ ឬមួយក៏ឈប់ប្រើនូវយន្តការនៃការបែងចែកទោសជាប្រភាគ តទៅទៀតចំពោះរឿងក្ដីមួយបានគ្រប់ពេល នេះប្រសិនបើជាមានការប្ដឹងសុំអំពីព្រះរាជអាជ្ញា បានន័យថានៅក្នុងគ្រប់ករណី គ្រប់

---

[50] ដកស្រង់ចេញពីសៀវភៅ " នីតិព្រហ្មទណ្ឌ " រៀបរៀងដោយ ឯកឧត្តម ហ៊ី សោភា ឆ្នាំ២០០៦

ពេលវេលា ការអនុវត្តរបបពាក់កណ្ដាលសេរីភាពក្ដី ក៏ដូចជាការបែងចែកទោសជាប្រភាគក្ដី អាចត្រូវបានតុលាការកែប្រែទៅតាមបណ្ដឹងរបស់ព្រះរាជអាជ្ញា ជាពិសេសគឺទាក់ទងជាមួយនឹងឥរិយាបថរបស់គាត់ កាលបើព្រះរាជអាជ្ញាពិនិត្យទៅឃើញថា ដូចជាមិនសូវល្អនោះទេ បើទុកគាត់ឲ្យនៅក្រៅបន្តទៅទៀតវានឹងអាចមានស្ថានភាពគ្រោះថ្នាក់ ឬក៏ស្ថានភាពនៃគោលការណ៍ឯកត្តកម្មនៃទោសនេះ ការអនុវត្តត្រូវក្រោមការតាមដានរបស់ព្រះរាជអាជ្ញា ដូច្នេះគឺអាចប្ដឹងសុំលុបចោលរបបពាក់កណ្ដាលសេរីភាព ឬប្ដឹងសុំលុបរបបនៃការបែងចែកទោសជាប្រភាគនោះចោលតែម្ដង។

**គ. ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត**

ព្រះរាជអាជ្ញា អាចបង្គាប់ឲ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនវិលត្រឡប់មកពន្ធនាគារវិញនៅពេលផុតកំណត់រយៈពេលនៃការផ្អាកការអនុវត្តទោស ព្រោះថាការអនុវត្តនូវរបបនេះគឺត្រូវស្ថិតនៅក្រោមការតាមដានរបស់ព្រះរាជអាជ្ញា បានន័យថាដូចគ្នានឹងករណីនៃរបបពាក់កណ្ដាលសេរីភាពដែរ ប្រសិនបើដល់ពេលគេអនុញ្ញាតឲ្យគាត់នៅក្រៅឃុំ ក៏ប៉ុន្តែនៅពេលផុតរយៈពេលនៅក្រៅឃុំ ជននោះត្រូវចូលមន្ទីរឃុំឃាំងវិញទៅហើយតែគាត់បែរជាមិនចូលទៅវិញ។ បើដូច្នេះមែននោះ ព្រះរាជអាជ្ញាគាត់នឹងចេញបញ្ជាឲ្យចាប់ខ្លួន និងឃុំខ្លួន ទណ្ឌិតដែលមិនបាន វិលត្រឡប់មកវិញតាមការកំណត់កាលបើគ្មានមូលហេតុត្រឹមត្រូវ ដែលអាចទទួលយកបាន។

**២.២ ភាពខុសគ្នា រវាងការបែងចែកទោសជាប្រភាគ និងរបបពាក់កណ្ដាលសេរីភាព**

បើប្រៀបធៀបរបបនៃការបែងចែកទោសជាប្រភាគទៅនឹងរបបពាក់កណ្ដាលសេរីភាព ឃើញថាចំណុចមួយចំនួនដែលធ្វើឲ្យមានភាពខុសគ្នារវាងរបបពាក់កណ្ដាលសេរីភាព និងការបែងចែកទោសជាប្រភាគនោះគឺៈ

- ទីមួយ : នៅក្នុងមាត្រា១៣២ បានកំណត់ច្បាស់ថាបើកាលណា តុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង១ (មួយ) ឆ្នាំ បានន័យថា បើប្រកាសទោសជាប់ពន្ធនាគារមិនលើសពី ១ (មួយ) ឆ្នាំទេ ដូច្នេះអាចអនុវត្តដោយធ្វើទៅតាមប្រព័ន្ធនៃការបែងចែកទោសជាប្រភាគបាន ហើយការបែងចែកទោសជាប្រភាគនេះមានលក្ខណៈទូលំទូលាយជាងពីព្រោះថាការបែងចែកជាប្រភាគនេះអាចអនុវត្តបានចំពោះទោសជាប់ពន្ធនាគាររហូតដល់ ១ (មួយ) ឆ្នាំ[51]។ ចំណែកឯ របបពាក់កណ្ដាលសេរីភាព គឺទោសដែលតុលាការបានប្រកាសនោះគឺមិនលើសពី ៦ (ប្រាំមួយ) ខែទេ។
- ទីពីរ : នៅក្នុងបែបបទនៃការបែងចែកក្នុងការនៅក្រៅពន្ធនាគារ ចំពោះប្រភាគនៃទោសគឺមានលក្ខណៈមិនតិចជាង ១ (មួយ) ខែ បានន័យថា ជនដែលទទួលបានទោសជាប្រភាគអាច

---

[51] យោងតាម " មេរៀននីតិព្រហ្មទណ្ឌ " នៃសហប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ ដោយផ្អែកលើអត្ថបទនៃសេចក្ដីព្រាងក្រមព្រហ្មទណ្ឌ ខែធ្នូ ឆ្នាំ២០០៧

មាននៅក្រៅពន្ធនាគារមិនតិចជាង ១ (មួយ) ខែនោះទេ។ បើរបបពាក់កណ្ដាលសេរីភាពវិញនោះ តុលាការកំណត់ជាថ្ងៃដែលនៅក្រៅឃុំ ហើយពេលវេលាដែលត្រូវទៅដល់ទីកន្លែងឃុំឃាំងវិញ ជាក់ស្ដែងដូចជា ម៉ោង ៦ (ប្រាំមួយ) ចេញពីពន្ធនាគារ ហើយនៅម៉ោង ១៨ (ដប់ប្រាំបី) ត្រូវចូលពន្ធនាគារវិញ តែត្រូវបានចេញជារៀងរាល់ថ្ងៃ។ មូលហេតុដែលមាននៅក្នុងមាត្រា ១៣២ បានបញ្ជាក់អំពីមូលហេតុធ្ងន់ធ្ងរដែលមានដូចជាលក្ខណៈគ្រួសារ ជាលក្ខណៈវេជ្ជសាស្ត្រ ជាលក្ខណៈវិជ្ជាជីវៈ ឬជាលក្ខណៈសង្គម ទាំងនេះគឺទាក់ទងនឹងមូលហេតុ។

- ទីបី : បើយើងពិនិត្យទៅលើរយៈពេលនៃការនៅក្រៅឃុំនៃរបបទាំងពីរនេះវិញឃើញថា របបនៃការបែងចែកទោសជាប្រភាគ មិនត្រូវបានគិតអំពីរយៈពេលនៃការនៅក្នុងពន្ធនាគារ និងនៅក្រៅពន្ធនាគារបញ្ចូលគ្នាទេ ដែលមានលក្ខណៈខុសគ្នាពីរបបពាក់កណ្ដាលសេរីភាព ដែលរយៈពេលនៃការនៅក្រៅពន្ធនាគារចាត់ទុកថាបានអនុវត្តទោសដូចនៅក្នុងពន្ធនាគារផងដែរ ត្បិតតែរយៈពេលនៃការនៅក្រៅមន្ទីរឃុំឃាំងមានរយៈពេលតិចជាងទោសជាប្រភាគក៏ដោយ។

សរុបសេចក្ដីមក គោលបំណងទាំងអស់នៃប្រព័ន្ធនេះ គឺជាប្រព័ន្ធថ្មីមួយបើយើងប្រៀបធៀបជាមួយនឹងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌយើងកន្លងមក។ ហេតុនេះក្រមព្រហ្មទណ្ឌថ្មីនេះ មានប្រព័ន្ធបង្ក្រាបតាមបែបសម័យទំនើបមួយ ដែលមានគោលដៅបង្ក្រាបប្រកបដោយប្រសិទ្ធភាព និងមានគោលដៅ គឺជានាធ្វើសមាហរណកម្មទណ្ឌិតឲ្យចូលទៅរួមរស់នៅក្នុងសង្គមវិញស្ថិតក្រោមវិធានការណ៍អប់រំ កែប្រែ និងសម្រួលទណ្ឌិតឲ្យក្លាយទៅជាពលរដ្ឋល្អ ដើម្បីក្លាយទៅជាជនដែលមានប្រយោជន៍ទៅដល់សង្គមខ្លួនផងដែរ។ ហេតុនេះហើយ ក្រៅពីគោលការណ៍ឯកត្តកម្មនៃទណ្ឌកម្ម យើងក៏មានបង្កើតយន្តការទាំងនេះដើម្បីបម្រើដល់គោលដៅនៃទោសសព្រហ្មទណ្ឌ ឬមួយក៏បម្រើដល់គោលបំណងនៃទោសព្រហ្មទណ្ឌ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវនូវប្រធានបទស្តី **"របបនៃការប្រកាសទោស"** រួចមកសបញ្ជាក់ឱ្យឃើញថា របបនៃការប្រកាសទោសនេះ គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ផ្តល់ជាមូលដ្ឋានដល់ចៅក្រមក្នុងការប្រកាសទោសចំពោះបុគ្គលដែលបានប្រព្រឹត្តបទល្មើស និងការពិន័យដាក់ទោសទណ្ឌចំពោះបុគ្គលដែលបានធ្វើខុសនោះ។ ក្នុងការប្រកាសទោសចំពោះរូបវន្តបុគ្គល ឬ នីតិបុគ្គលក្តី គឺជាឆន្ទានុសិទ្ធិរបស់ចៅក្រមក្នុងការសម្រេច ដែលជាយុត្តាធិការរបស់ចៅក្រមក្នុងការប្រកាសទោស ដូចដែលយើងដឹងហើយថាគ្មានបុគ្គលណាម្នាក់ត្រូវបានយកមកអនុវត្តទោសបានឡើយ ប្រសិនជាបុគ្គលនោះមិនត្រូវបានប្រកាសទោសដោយតុលាការ។ ដូចនេះ ក្នុងរបបនៃការប្រកាសទោស ដើម្បីកំណត់អំពីអត្ថិភាពនៃបទល្មើសដែលបុគ្គលនោះបានប្រព្រឹត្តិ និងផ្តន្ទាទោសបានដោយយោងតាមការប្រកាសអំពីទោសរបស់បុគ្គលនោះដែលត្រូវទទួល។ ក្នុងគោលគារណ៍នៃការប្រកាសទោសដែលជាឆន្ទានុសិទ្ធិរបស់ចៅក្រមទៅលើការដាក់ទោសលើជនល្មើសណាមួយ ពោលគឺផ្អែកតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងគោលការឯកត្តកម្មនៃទោស។ គោលការណ៍ទាំងពីរនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រកាសទោសចំពោះបុគ្គលដែលបានប្រព្រឹត្តិបទល្មើស ព្រោះថាគោលការឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលជាការទទួលខុសត្រូវចំពោះតែអំពើ ដែលខ្លួនបានធ្វើ ឬប្រព្រឹត្តប៉ុណ្ណោះ គឺមិនអនុញ្ញាត្តិឱ្យនណាម្នាក់ទទួលទោសជំនួសនោះទេ។ ម្យ៉ាងទៀត ក្នុងគោលការណ៍ឯកត្តកម្មនៃទោស ជាគោលការណ៍មូលដ្ឋានក្នុងការបញ្ញតិសម្រាប់ចៅក្រមលើកយកមកពិចារណា មុននឹងធ្វើការផ្តន្ទាទោស។ មូលហេតុចាំបាច់ក្នុងការប្រកាសទោស គឺសំខាន់ក្នុងការយកបុគ្គលដែលទទួលខុសមកផ្តន្ទាទោសតាមច្បាប់ ដែលជាការធានាឱ្យបាននូវការការពារសិទ្ធិស្របច្បាប់របស់បុគ្គលគ្រប់រូប។ នៅក្នុងគោលការណ៍របបនៃការប្រកាសមានទាំងគោលការណ៍បន្ធូរបន្ថយ ក៏ដូចជាការអនុគ្រោះចំពោះទណ្ឌិតដែលបានប្រព្រឹត្តនូវបទល្មើសមជ្ឈិម ព្រមទាំងលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់។ ការបន្ធូរបន្ថយ ឬ អនុគ្រោះដល់ ទណ្ឌិតមានគោលការណ៍មួយចំនួនរួមមាន ការព្យួរទោសធម្មតា និងការព្យួរទោសសាកល្បង។ ទន្ទឹមនឹងនេះផងដែរ គោលការណ៍របបនៃការប្រកាសក៏មាននូវរបបពាក់កណ្តាលសេរីភាព ដែលមើលទៅដូចជាការ សម្រាលទោសមួយសម្រាប់ទណ្ឌិតក្នុងការអនុវត្តទោសរបស់ខ្លួន។ ការបង្កើតគោលការណ៍ ឬបទបញ្ញត្តិទាក់ទងនឹងការប្រកាសទោស គឺផ្តល់នូវបទបញ្ញត្តិមូលដ្ឋានក្នុងការសម្រេចទោសចំពោះទណ្ឌិត ដែលជាឆន្ទានុសិទ្ធិរបស់ចៅក្រម និងស្របតាមច្បាប់កំណត់យ៉ាងជាក់លាក់។ អាស្រ័យដូចនេះ របបនៃការប្រកាសទោស ពិតជាមានសារៈប្រយោជន៍ចំពោះការអនុវត្តទោសចំពោះជនដែលបានប្រព្រឹត្តិបទល្មើស ព្រោះថាបុគ្គលដែលអាចអនុវត្តទោស ឬផ្តន្ទាទោសបានត្រូវធ្វើឡើងដោយតុលាការ។

ជាចុងបញ្ចប់ យើងខ្ញុំសូមសន្និដ្ឋានថា របបនៃការប្រកាសទោស ដែលអនុលោមតាមក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ គឺមាននូវរបបពិសេសជាច្រើនដែលមានសារៈសំខាន់សម្រាប់ទណ្ឌិត។ មិនត្រឹមតែប៉ុណ្ណោះ នៅក្នុងការប្រកាសផ្តន្ទាទោសព្រហ្មទណ្ឌក៏មាននូវរបបដោយឡែកផ្សេងទៀតដែលអាចជំនួសឱ្យការជាប់ពន្ធនាគារបានផងដែរ កាលដែលតុលាការយកនូវទោសណាមួយមកជំនួសឱ្យទោសពន្ធនាគារ ពិតណាស់ច្បាស់ជាបានផ្តល់សេរីភាព និងលទ្ធភាពជាច្រើនដល់ទណ្ឌិត ក្នុងការអបរំ ទូន្មាន និងកែប្រែ ដើម្បីឱ្យទណ្ឌិតបានដឹងនូវអំពើដែលខ្លួនប្រព្រឹត្ត និងលែងហ៊ានប្រព្រឹត្តអំពើបែបនេះទៀត។ កាលដែលក្រមព្រហ្មទណ្ឌបានចែងនូវរបបពិសេសផ្សេងៗទៀតគឺដោយសារមានគោលបំណងធ្វើយ៉ាងណា ដើម្បីកែប្រែជនដែលបានប្រព្រឹត្តបទល្មើសនោះឱ្យក្លាយជាពលរដ្ឋល្អម្នាក់នៅក្នុងសង្គម និងធ្វើសមាហរណកម្មឱ្យចូលមករួមរស់ជាមួយសង្គមជាតិវិញ ដោយគេជឿថាការប្រើនូវរបបនេះក៏ជាគំរូមួយសម្រាប់ប្រជាពលរដ្ឋដទៃមិនឱ្យប្រព្រឹត្តបទល្មើសដូចជននេះ ព្រោះអាចធ្វើឱ្យខ្លួនប្រឈមនឹង ទោសព្រហ្មទណ្ឌបាន។ ការប្រើនូវរបបដោយឡែកដូចជា របបនៃការព្យួរទោស របបពាក់កណ្តាលសេរីភាព ក៏ ដូចជា ការបែងចែកទោសជាប្រភាគ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះទណ្ឌិត និងសង្គម ព្រោះថាការ ប្រកាសរបបទាំងនេះចំពោះទណ្ឌិតដែលបានផ្តន្ទាទោសហើយ គឺទណ្ឌិតមានលទ្ធភាពក្នុងការកែប្រែ និងធ្វើសមាហរណកម្មមករួមរស់ជាមួយសង្គមវិញ ហើយថែមទាំងមិនបានកាត់ទំនាក់ទំនងរវាងទណ្ឌិតនិងសង្គមទៀតផង។ ម្យ៉ាងវិញទៀត រដ្ឋមិនសូវចំណាយច្រើនទៅលើទណ្ឌិតទាំងនេះ ព្រោះការប្រកាសនូវរបបទាំងនេះគឺមិនត្រូវ អនុវត្តទោសក្នុងពន្ធនាគារនោះទេ ដូច្នេះការចំណាយរបស់រដ្ឋទៅលើទណ្ឌិតនៅមន្ទីរឃុំឃាំងក៏បានកាត់បន្ថយច្រើនដែរ។

# អនុសាសន៍

# អនុសាសន៍

ឆ្លងតាមការបកស្រាយខាងលើរួចមកយើងសង្កេតឃើញថា នៅក្នុងក្រមព្រហ្មទណ្ឌនេះ មានយន្តការជាច្រើនដែលត្រូវបានប្រើក្នុងវិស័យព្រហ្មទណ្ឌ ជាក់ស្តែងដូចជាការប្រកាសទោសព្រហ្មទណ្ឌតែម្តងដែលជាវិធានការចុងក្រោយដែលឈានដល់ការដាក់នូវទោសទណ្ឌ ចំពោះជនដែលបានប្រព្រឹត្តដូចអ្វីដែលមានចែងយ៉ាងជាក់លាក់នៅក្នុងច្បាប់ព្រហ្មទណ្ឌ។ ហើយនៅក្នុងយន្តការទាំងអស់មានដូចជា ការប្រកាសទោស ការព្យួរទោស របបពាក់កណ្តាលសេរីភាព និងការបែងចែកទោសជាប្រភាគ ដែលនីតិករបានខិតខំបង្កើតឡើង នូវរបបទាំងនេះក្នុងគោលដៅដើម្បីជាប្រយោជន៍ចំពោះសង្គមរបស់ខ្លួន ដែលវាមានលក្ខណៈលើកលែងច្រើនជាងប្បញ្ញត្តិច្បាប់ដែលមានចែងពីមុន។ ទោះបីជាមានរបបពិសេសបែបនេះពិតមែន តែនៅក្នុងការអនុវត្តសព្វថ្ងៃពុំមានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយទេ ជាពិសេសគឺរបបពាក់ណ្តាលសេរីភាព និងការបែងចែកទោសជាប្រភាគ ដែលមកដល់សព្វថ្ងៃនេះមិនទាន់ឃើញមានការអនុវត្តនៅឡើយ នៅតាមបណ្តាតុលាការជាន់ទាប និងជាន់ខ្ពស់ ដែលមាននៅកម្ពុជា។ ចំណែកឯ ការព្យួរទោសសាកល្បងវិញ ក៏ពុំសូវមានការអនុវត្តប៉ុន្មានដែរ តែក៏មិនមែនមានន័យថា គ្មានទាល់តែសោះនោះទេ តែមានតិចតួចបំផុតនៅក្នុងការអនុវត្ត។ កាលដែលមានច្បាប់ចែងហើយ តែមិនយកមកអនុវត្តវាអាចធ្វើឲ្យវិធានដែលត្រូវបានបង្កើតឡើងហើយបែរជាគ្មានប្រសិទ្ធភាពនៅក្នុងការអនុវត្ត ប្រៀបបីដូចជារដ្ឋមួយគ្មានការគោរពនូវគោលការណ៍នីតិរដ្ឋផងដែរ។ ម្យ៉ាងទៀតនៅក្នុងវិធាននៃការបង្កើតនូវយន្តការទាំងឡាយពិតជាមាននូវគោលដៅ និងគោលបំណងពិតប្រាកដ នៅក្នុងអ្វីដែលនីតិករបង្កើត ហើយបែរជាគ្មាននូវការអនុវត្តវិញនោះហាក់បីដូចជា ការខិតខំបង្កើតរបស់អ្នកច្បាប់គ្មានន័យនោះទេ យើងក៏មានការសោកស្តាយនូវអ្វីដែលល្អៗ ដែលយើងមានតែគ្មាននូវការអនុវត្ត។ បញ្ហាប្រឈម ដែលធ្វើឲ្យមិនអាចយកមកអនុវត្តបាន នូវរបបនៃការបែងចែកទោសជាប្រភាគ និងរបបពាក់កណ្តាលសេរីភាព គឺបណ្តាលមកពីបញ្ហាជាច្រើនដូចជា ពាក់ព័ន្ធជាមួយនិងបច្ចេកវិជ្ជា ស្ថានភាព ទីកន្លែង ពេលវេលា និងការឃ្លាំមើលជាដើម ណាមួយវាជាយន្តការថ្មីមួយនៅក្នុងសង្គមរបស់កម្ពុជាយើង ដែលជាហេតុនាំឲ្យចៅក្រមមិនហ៊ានប្រើនូវយុត្តិសាស្ត្រទាំងអស់នេះផងដែរ។

ជាចុងបញ្ចប់ យើងខ្ញុំសង្ឃឹមថាយ៉ាងមុតមាំថាប្រទេសកម្ពុជាយើងនឹងរៀបចំពង្រឹងរឹតបន្តឹងនូវប្រព័ន្ធតុលាការឱ្យកាន់តែល្អប្រសើរ ដូចជាការអនុវត្តនូវនីតិវិធីក្នុងការចេញសម្រេចសេចក្តី ការអនុវត្តនូវរបបនៃប្រកាសទោស ការព្យួរទោស និងការបែងចែកទោសផ្សេងៗ ឱ្យកាន់តែមានប្រសិទ្ធភាព និងប្រកបដោយយុត្តិធម៌នៅក្នុងសង្គមជាតិយើង។ ដើម្បីអាចជួយដល់ទណ្ឌិតមានឱកាសបានទទួលនូវការអប់រំ ការដឹងនូវកំហុស ហើយមានទំនួលខុសត្រូវចេះកែប្រែនូវកំហុសរបស់ខ្លួន ដោយអាចធ្វើការវិលត្រឡប់ចូលមករួមរស់នៅក្នុងសង្គមវិញ។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩។
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧។
- ច្បាប់ស្តីពី យុត្តិធម៌អនីតិជន នៃព្រះរាជាណាចក្រកម្ពុជា។

## ២. សៀវភៅមេរៀនច្បាប់ និងអត្ថបទឯកសារផ្សេងៗ

- សៀវភៅនីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ ២០២២ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត
- សៀវភៅស្តីពី រូបវន្តបុគ្គល ឆ្នាំ ២០១២ និងសៀវភៅទោសព្រហ្មទណ្ឌ ឆ្នាំ រៀបរៀងដោយលោកសាស្ត្រាចារ្យ កៅ សីហា
- សៀវភៅនីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ ២០០៦ រៀបរៀងដោយ ឯកឧត្តម ហ៊ី សោភា
- សៀវភៅនីតិព្រហ្មទណ្ឌខ្មែរ ឆ្នាំ ២០០៧ រៀបរៀងដោយសហប្រតិបត្តិការបារាំងខ្មែរគម្រោងទ្រទ្រង់នីតិរដ្ឋ
- វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត
- សទ្ទានុក្រមពាក្យច្បាប់ខ្មែរ-អង់គ្លេស-បារាំង ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១
- យោងតាមអនុសាសន៍របស់ ឯកឧត្តម កើត រិទ្ធ អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ (បច្ចុប្បន្នជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌) នៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា។
- យោងតាមប្រសាសន៍របស់ ឯកឧត្តម ផូវ សំភី អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារ សេចក្តីព្រាងក្រមព្រហ្មទណ្ឌ នៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ឧបសម្ព័ន្ធទី២ ៖ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

ឧបសម្ព័ន្ធទី៣ ៖ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ឧបសម្ព័ន្ធទី៤ ៖ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន

ឧបសម្ព័ន្ធទី៥ ៖ ទម្រង់នៃដីការបស់ព្រះរាជអាជ្ញា

# ឧបសម្ព័ន្ធទី១ ៖

# រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ឧបសម្ព័ន្ធទី ១

# រដ្ឋធម្មនុញ្ញ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

រដ្ឋសភា

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រង សង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និង ចូលជាសមាជិកសហជីពនេះ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីព នឹងមានកំណត់ ក្នុង ច្បាប់ ។

**មាត្រា ៣៧.-**

សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្ត នៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។

**មាត្រា ៣៨.-**

ច្បាប់ធានាមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គល ណាមួយឡើយ ។ ច្បាប់ការពារជីវិត កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ប្រជា ពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណា មួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណា មួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ ។ អ្នកដែលដល់ អ្នករួមប្រព្រឹត្ត និង អ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយ

ក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

**មាត្រា ៣៩.-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋរបស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។

**មាត្រា ៤០.-**

សេរីភាពក្នុងការធ្វើដំណើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់របស់ប្រជាពលរដ្ឋ ត្រូវបានគោរព ។

ប្រជាពលរដ្ឋខ្មែរអាចចេញទៅតាំងទីលំនៅ នៅប្រទេសក្រៅ ឬវិលត្រឡប់មកវិញបាន ។

ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទ ត្រូវបានធានា ។

ការឆែកឆេរលំនៅឋាន សម្ភារៈវត្ថុ និងលើរូបបុគ្គល ត្រូវធ្វើឱ្យស្របនឹងបញ្ញត្តិច្បាប់ ។

# ជំពូកទី ១១ ថ្មី
# អំពីអំណាចតុលាការ

**មាត្រា ១២៨._ ថ្មី (មាត្រា ១០៩ ចាស់)**

អំណាចតុលាការជាអំណាចឯករាជ្យ ។

អំណាចតុលាការ ជានាយរក្សាអនាគត និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាចតុលាការគ្របដណ្ដប់ទៅលើរឿងក្ដីទាំងអស់ រួមទាំងរឿងក្ដីរដ្ឋបាលផង ។

អំណាចនេះ ត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជំរះក្ដីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ។

**មាត្រា ១២៩._ ថ្មី (មាត្រា ១១០ ចាស់)**

ការជំរះក្ដីផ្ដល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន ។

មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្ដី ។ ចៅក្រមត្រូវបំពេញការកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន ។

**មាត្រា ១៣០._ ថ្មី (មាត្រា ១១១ ចាស់)**

គ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ ។

# ឧបសម្ព័ន្ធទី២ ៖

# ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

**ឧបសម្ព័ន្ធទី ២**


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ក្រមព្រហ្មទណ្ឌ
និង
វិសោធនកម្មក្រមព្រហ្មទណ្ឌ
នៃព្រះរាជាណាចក្រកម្ពុជា
រៀបចំចងក្រងដោយ
លោក ឡោ ក្រឹម
ឆ្នាំ២០១៨

ប៉ុន្តែ ក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ ។

**មាត្រា ៥.-** ការបកស្រាយច្បាប់ព្រហ្មទណ្ឌ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ ។

**មាត្រា ៦.-** ការប្រកាសទោស

គ្មានទោសណាមួយដែលអាចត្រូវយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះមិនត្រូវបានប្រកាសដោយតុលាការទេ ។

**មាត្រា ៧.-** លក្ខខណ្ឌនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ដែនអនុវត្តច្បាប់កម្ពុជាក្នុងលំហ ត្រូវបានកំណត់ដោយបទប្បញ្ញត្តិនៃក្រមនេះ លើកលែងតែមានសន្ធិសញ្ញាអន្តរជាតិ ។

**មាត្រា ៨.-** អវត្តមាននៃនិទណ្ឌភាពក្នុងបទល្មើសធ្ងន់ធ្ងរខាងនីតិមនុស្សធម៌អន្តរជាតិ

បទប្បញ្ញត្តិនៃក្រមនេះ ពុំអាចនាំឱ្យមានការបង្កើតនូវស្ថានភាពយុត្តិនិសេធចំពោះជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរ ដែលកំណត់ដោយច្បាប់ដោយឡែកទាក់ទងដល់ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជាឡើយ ។

## ជំពូកទី ២

## ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

**មាត្រា ៩.-** ការអនុវត្តច្បាប់ដែលលុបចោលបទល្មើស

បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម ។ អំពើដែលប្រព្រឹត្តនៅមុនបទប្បញ្ញត្តិនេះចូលជាធរមាន មិនអាចត្រូវចោទប្រកាន់ទៀតឡើយ ។ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះ ត្រូវបញ្ឈប់ ។

ចោទប្រកាន់ត្រូវតែមានបណ្ដឹងពីជនរងគ្រោះ ឬពីសិទ្ធិវន្ត ឬបណ្ដឹងបរិហារជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលអំពើនោះបានប្រព្រឹត្ត ។

**មាត្រា ២២.-** សមត្ថកិច្ចដោយឡែកចំពោះបទឧក្រិដ្ឋដោយឡែក

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើស ដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយបើបទល្មើសនោះជា :

១-បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា ។

២-បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា ។

៣-បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិ ដែលមានតម្លៃស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ។

៤-បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ។

៥-បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៣.-** ការមិនចោទប្រកាន់ត្រួតគ្នា និងទោស

ពុំមានការចោទប្រកាន់ណាមួយអាចប្រព្រឹត្តប្រឆាំងនឹងបុគ្គលណាម្នាក់ ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅឯបរទេសចំពោះអំពើល្មើសដដែល ហើយក្នុងករណីដែលមានការផ្ដន្ទាទោស បុគ្គលនោះបានបង្ហាញថាខ្លួនបានអនុវត្តទោសរបស់ខ្លួនរួចហើយ ឬក៏ទោសត្រូវបានរលត់ដោយការផុតអាជ្ញាយុកាល ។

## មាតិកាទី ២

## ការទទួលខុសត្រូវព្រហ្មទណ្ឌ

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ២៤.-** គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ ។

**មាត្រា ៣៥.-** ស្ថានភាពចាំបាច់

បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និង

-គ្មានវិសមាមាត្ររវាងមធ្យោបាយការពារនិងទម្ងន់នៃគ្រោះថ្នាក់ ។

**មាត្រា ៣៦.-** អានុភាពនៃកម្លាំង ឬការបង្ខិ

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខិ ដែលបុគ្គលនេះ មិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កម្លាំង និងការបង្ខិ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ។ កម្លាំង និងការបង្ខិនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន ។

**មាត្រា ៣៧.-** ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ មិនត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌណាមួយទេ ។

## ជំពូកទី ៣
## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

**មាត្រា ៣៨.-** នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។

**មាត្រា ៣៩.-** វិធានការអនុវត្តចំពោះអនីតិជន

អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ។

ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ។

**មាត្រា ៤០.-** ប្រភេទនៃវិធានការ

វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមានដូចតទៅ :

១-ការប្រគល់អនីតិជនឱ្យទៅឪពុកម្ដាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្ដិសមនឹងទំនុកចិត្ត ។

២-ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន ។

៣-ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន ។

៤-ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ។

៥-ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ ។

**មាត្រា ៤១.-** ការដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ

ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន ។ បុគ្គលនេះធ្វើរបាយការណ៍ស្ដីពីកិរិយាមារយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្ដល់ព័ត៌មាន ដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ ។

## ជំពូកទី ៤
## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

**មាត្រា ៤២.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គល លើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ក្នុងអំពើដដែលនោះទេ ។

## មាតិកាទី ៣
## ទោស
## ជំពូកទី ១
## ប្រភេទនៃទោស
## ផ្នែកទី ១
## មូលទោស

**មាត្រា ៤៣.-** មូលទោស

មូលទោសរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យ ។

ការពិន័យត្រូវគិតជាប្រាក់រៀល ។

**មាត្រា ៤៤.-** អប្បបរមា និងអតិបរមានៃមូលទោស

កាលបើបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ច្បាប់កំណត់អំពី អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ ។

កាលបើបទល្មើសត្រូវផ្តន្ទាទោសពិន័យ ច្បាប់កំណត់អំពីអប្បបរមា និង អតិបរមា នៃចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល ។

ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមចំនួនថ្ងៃជាក់ស្តែង ដែលមាននៅក្នុងខែនោះ ។

ទោសដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំ ត្រូវគិត ១២ (ដប់ពីរ) ខែ ។

**មាត្រា ៥០.-** លក្ខខណ្ឌដោយឡែកនៃការបញ្ចប់ទោស

ជាគោលការណ៍ ទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬបទដ្ឋានគតិយុត្តបានកំណត់ ត្រូវតែដោះលែងឱ្យមានសេរីភាពវិញនៅមុនថ្ងៃឈប់សម្រាកនោះ ។

**មាត្រា ៥១.-** ការគិតបញ្ចូលរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន

រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវគិតបញ្ចូលទាំងស្រុងទៅក្នុងរយៈពេលនៃទោសដាក់ពន្ធនាគារដែលត្រូវទទួល ។

**មាត្រា ៥២.-** ផលនៃទោសពិន័យ

ប្រាក់ពិន័យដែលទទួលបាន ត្រូវបង់ចូលថវិការដ្ឋ ។

## ផ្នែកទី ២
## ទោសបន្ថែម

**មាត្រា ៥៣.-** ប្រភេទនៃទោសបន្ថែម

ទោសបន្ថែមរួមមាន :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្ត នៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ ។

៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ។

៤-ការល្អរលិខិតបើកបរ ។

៥-ការហាមឃាត់ចំពោះការស្នាក់នៅ ។

៦-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

៧-ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស ។

៨-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ។

៩-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

១០-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

១១-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

១២-ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត ។

១៣-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

១៤-ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ ។

១៥-ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស ។

១៦-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន ។

១៧-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស ។

១៨-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៩-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បទប្បញ្ញត្តិដោយឡែក អាចបង្កើតទោសបន្ថែមផ្សេងៗទៀត ។

**មាត្រា ៥៤.-** លក្ខខណ្ឌនៃការប្រកាសទោសបន្ថែម

ទោសបន្ថែម នឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលត្រូវចោទប្រកាន់ ។

ទោសបន្ថែម អាចប្រកាសក៏បាន មិនប្រកាសក៏បាន ។ ទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់ ។

ផុតទោសពន្ធនាគារ លើកលែងតែមានសេចក្ដីសម្រេចផ្ទុយរបស់តុលាការ។

## ផ្នែកទី ៣

## ទោសជំនួស

## កថាភាគទី ១

## ការងារសហគមន៍

**មាត្រា ៧២.-** និយមន័យនៃការងារសហគមន៍

កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសទោសការងារសហគមន៍ ។

ការងារសហគមន៍ គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ (សាមសិប) ម៉ោង ទៅ ២០០ (ពីររយ) ម៉ោង នូវការងារគ្មានកម្រៃ ជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀត ដល់សមាគម ឬដល់អង្គការមិនមែនរដ្ឋាភិបាល ។

**មាត្រា ៧៣.-** អ្នកមិនទទួលប្រយោជន៍នៃការងារសហគមន៍

នៅក្នុងគ្រប់ករណីទាំងអស់ ការងារសហគមន៍មិនអាចបំពេញជាប្រយោជន៍នៃរូបវន្តបុគ្គលទេ ។

**មាត្រា ៧៤.-** របបគតិយុត្តនៃការងារសហគមន៍

ការងារសហគមន៍ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ជាអាទិ៍ ការងារនៅពេលយប់ អនាម័យ សន្តិសុខ ហើយនិងការងាររបស់ស្ត្រី ។

ការងារសហគមន៍អាចត្រួតគ្នាបានជាមួយនឹងការអនុវត្តសកម្មភាពវិជ្ជាជីវៈ ។

**មាត្រា ៧៥.-** គោលការណ៍ផ្ដល់សំណងការខូចខាតដល់អ្នកដទៃ

រដ្ឋត្រូវតែចេញសោហ៊ុយផ្ដល់សំណងការខូចខាតដែលបង្កដល់អ្នកដទៃដោយទណ្ឌិតនៅក្នុងពេលដែលកំពុងអនុវត្តការងារសហគមន៍ ។ រដ្ឋត្រូវធ្វើឧបាទេសកម្មដោយពេញច្បាប់ ទៅក្នុងសិទ្ធិជនរងគ្រោះ ។

## កថាភាគទី ២
## ការស្ដីបន្ទោស

**មាត្រា ៧៦.-** របបគតិយុត្តនៃការស្ដីបន្ទោស

កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសស្ដីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌទាំងបីដូចតទៅនេះ :

-ភាពចលាចលដល់សណ្ដាប់ធ្នាប់សាធារណៈដែលបណ្ដាលមកពីបទល្មើសបានបញ្ចប់

-ការខូចខាតត្រូវបានជួសជុលរួចហើយ និង

-ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ ។

## ជំពូកទី ២
## ស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស
## ផ្នែកទី ១
## ស្ថានទម្ងន់ទោស
## កថាភាគទី ១
## និយមន័យនៃស្ថានទម្ងន់ទោសដោយឡែកខ្លះៗ

**មាត្រា ៧៧.-** ក្រុមមានការចាត់តាំង

ក្រុមមានការចាត់តាំង គឺជាការប្រមូលផ្តុំដែលបានបង្កើតឡើង ឬជាសន្និដ្ឋិភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬប្រព្រឹត្តបទល្មើសមួយ ឬច្រើន ។

**មាត្រា ៧៨.-** ការគិតទុកជាមុន

ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនសកម្មភាពប្រព្រឹត្តបទល្មើស ។

**មាត្រា ៩៥.-** ទោសដាក់ពន្ធនាគារអស់មួយជីវិត និងស្ថានសម្រាលទោស

កាលណាបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចៅក្រមដែលផ្តល់ស្ថានសម្រាលទោស អាចប្រកាសទោសដាក់ពន្ធនាគារ ក្នុងចន្លោះរវាង ១៥ (ដប់ប្រាំ) និង ៣០ (សាមសិប) ឆ្នាំ ។

## ជំពូកទី ៣
## របបនៃការប្រកាសទោស
### ផ្នែកទី ១
### របបទូទៅ

**មាត្រា ៩៦.-** គោលការណ៍ឯកត្តកម្មនៃទោស

តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ ។

**មាត្រា ៩៧.-** ការប្រកាសមូលទោស

នៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យផង តុលាការអាចប្រកាស :

-ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬ

-ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ

-ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ ។

**មាត្រា ៩៨.-** ការប្រកាសទោសជំនួស

ទោសការងារសហគមន៍ជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសទោសការងារសហគមន៍នោះ មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ ។

ការស្ដីបន្ទោសជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសការស្ដីបន្ទោស មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ ។

**មាត្រា ៩៩.-** ការប្រកាសទោសបន្ថែមលើមូលទោស

កាលណាបទល្មើសមួយត្រូវផ្ដន្ទាទោសដោយទោសបន្ថែមមួយឬច្រើន ទោសបន្ថែមនេះត្រូវបន្ថែមទៅលើមូលទោស លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ១០០ (ការជំនួសមូលទោសដោយទោសបន្ថែម) នៃក្រមនេះ ចេញ ។

**មាត្រា ១០០.-** ការជំនួសមូលទោសដោយទោសបន្ថែម

តុលាការអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយឬច្រើន នៅក្នុងករណីណាមួយដូចខាងក្រោម :

១-កាលណាជនជាប់ចោទទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់ ។

២-កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាស្មើ ឬតិចជាង ៣ (បី) ឆ្នាំ ។

កាលណាតុលាការសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬច្រើន តុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់បានទេ ។

**មាត្រា ១០១.-** វិធានដោយឡែកសម្រាប់ការប្រកាសទោសការងារសហគមន៍

ទោសការងារសហគមន៍នឹងអាចប្រកាសបាន លុះត្រាតែជនជាប់ចោទមានវត្តមាននៅពេលសវនាការ ហើយយល់ព្រមធ្វើការងារនេះ ។ តុលាការនៅមុនពេលប្រកាសសាលក្រម ឬសាលដីកា ត្រូវប្រាប់ជនជាប់ចោទថាសាមីខ្លួនមានសិទ្ធិប្រកែកមិនព្រមធ្វើការងារនេះ ។ ចម្លើយរបស់ជនជាប់ចោទ ត្រូវតែមានចុះនៅក្នុងសាលក្រម ឬសាលដីកា ។

**មាត្រា ១០២.-** ថិរវេលា និងអំឡុងពេលនៃការងារសហគមន៍

តុលាការដែលប្រកាសទោសការងារសហគមន៍ ត្រូវកំណត់អំពីថិរវេលានៃ

ការងារ និងរយៈពេលដែលត្រូវបំពេញ ។ រយៈពេលនេះមិនអាចលើសពី ១ (មួយ) ឆ្នាំ ទេ ។

**មាត្រា ១០៣.-** បែបបទនៃការអនុវត្តទោសការងារសហគមន៍

បែបបទនៃការអនុវត្តទោសការងារសហគមន៍ ត្រូវកំណត់ដោយព្រះរាជអាជ្ញា ។

ព្រះរាជអាជ្ញាចង្អុលប្រាប់ឈ្មោះនីតិបុគ្គល ដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ ។

ទោសនេះត្រូវអនុវត្តនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ។

## ផ្នែកទី ២

## ការព្យួរទោសធម្មតា

### កថាភាគទី ១

### បទប្បញ្ញត្តិរួម

**មាត្រា ១០៤.-** ការប្រកាសការព្យួរទោស

នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងផ្នែកនេះ តុលាការអាចបង្គាប់ថា ត្រូវព្យួរការអនុវត្តទាំងមូលទោស ។

**មាត្រា ១០៥.-** របបនៃការព្យួរទោស

ដើម្បីអនុវត្តបទប្បញ្ញត្តិស្តីពីការព្យួរទោស ត្រូវគិតតែអំពីការផ្តន្ទាទោសជាស្ថាពរខាងបណ្តឹងអាជ្ញាប៉ុណ្ណោះ ។

### កថាភាគទី ២

### ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

**មាត្រា ១០៦.-** លក្ខខណ្ឌទាក់ទងនឹងការផ្តន្ទាទោសពីមុន

ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ការព្យួរទោសធម្មតាអាចត្រូវផ្តល់ឱ្យបាន ប្រសិនបើជនជាប់ចោទមិនទាន់មានការផ្តន្ទាទោស

ជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ មុនអំពើល្មើស ។

**មាត្រា ១០៧.-** ទោសអាចនាំឱ្យមានការព្យួរទោស

ការព្យួរទោសធម្មតា ត្រូវអនុវត្តទៅលើទោសដូចតទៅ :

១-ទោសដាក់ពន្ធនាគារ កាលបើទោសដែលប្រកាសនោះតិចជាង ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ ។

២-ទោសពិន័យជាប្រាក់ ។

**មាត្រា ១០៨.-** ការព្យួរទោសមួយផ្នែក

តុលាការអាចសម្រេចថា ការព្យួរទោសធម្មតានេះអាចនឹងអនុវត្តទៅលើមួយផ្នែកនៃទោសពន្ធនាគារ ដែលតុលាការជាអ្នកកំណត់ថិរវេលា ឬលើមួយផ្នែកនៃប្រាក់ពិន័យដែលតុលាការជាអ្នកកំណត់ចំនួនទឹកប្រាក់ ។

**មាត្រា ១០៩.-** ការដកហូតការព្យួរទោស

ប្រសិនបើក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយមានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀតពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ការព្យួរទោសធម្មតានេះ ត្រូវដកហូតចេញដោយពេញច្បាប់ ។

ទោសទី ១ ត្រូវអនុវត្តដោយមិនអាចស្រូបចូលជាមួយទោសទី ២ បានឡើយ ។

**មាត្រា ១១០.-** ការមិនដកហូតការព្យួរទោស

ជាបដិប្បញ្ញត្តិទៅនឹងមាត្រា ១០៩ (ការដកហូតការព្យួរទោស) នៃក្រមនេះ តុលាការអាចសម្រេចថា ការផ្តន្ទាទោសថ្មីមិននាំឱ្យមានការដកហូតនូវការព្យួរទោសធម្មតាដែលបានសម្រេចពីមុននោះទេ។ សេចក្តីសម្រេចរបស់តុលាការត្រូវតែមានសំអាងហេតុជាពិសេស ។

**មាត្រា ១១១.-** ការទុកជាអសារបង់នូវការផ្តន្ទាទោស

ប្រសិនបើរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ

ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយគ្មានការផ្តន្ទាទោសថ្មីជាស្ថាពរ មួយទៀត ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះទេ ការផ្តន្ទាទោសដោយមានព្យួរនេះត្រូវ ចាត់ទុកថាជាអសារបង់ ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

កាលណាបើការព្យួរទោសត្រូវបានប្រកាសទៅលើតែផ្នែកមួយនៃទោសនោះ ការផ្តន្ទាទោសត្រូវចាត់ទុកជាអសារបង់ទាំងស្រុង ។ ទោសក៏មិនអាចយកមកអនុវត្ត បានទៀតឡើយ ។

## កថាភាគទី ៣
## ការចោទប្រកាន់ចំពោះបទលហុ

**មាត្រា ១១២.-** លក្ខខណ្ឌទាក់ទងទៅនឹងការផ្តន្ទាទោសពីមុន

ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាអាចត្រូវបានប្រកាស ប្រសិនបើជនជាប់ចោទ មិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារជាស្ថាពរនៅឡើយ នៅក្នុងរយៈពេល ១ (មួយ) ឆ្នាំ មុនបទល្មើសនេះ ។

**មាត្រា ១១៣.-** ទោសអាចនាំឱ្យមានការព្យួរទោស

ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាត្រូវអនុវត្តទៅលើទោស ដូចតទៅនេះ :

១-ទោសដាក់ពន្ធនាគារ ។

២-ទោសពិន័យជាប្រាក់ ។

**មាត្រា ១១៤.-** ការដកហូតការព្យួរទោស

ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ ក្រោយការផ្តន្ទាទោសជាស្ថាពរពី បទលហុដោយមានការព្យួរទោសធម្មតាផង រួចកើតមានការផ្តន្ទាទោសថ្មីជាស្ថាពរ ពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការព្យួរទោសធម្មតានេះ ត្រូវដកហូតចេញដោយ ពេញច្បាប់។ ទោសទី ១ ត្រូវអនុវត្តដោយគ្មានស្រួបជាមួយទោសទី ២ ឡើយ ។

**មាត្រា ១១៥.-** ការមិនដកហូតការព្យួរទោស

ជាបដិយ្យាប្បត្តិនៃមាត្រា ១១៤ (ការដកហូតការព្យួរទោស) នៃក្រមនេះ តុលាការអាចសម្រេចថា ការផ្តន្ទាទោសថ្មីមិនអាចនាំឱ្យមានការដកហូតនូវការព្យួរទោសធម្មតានេះដែលសម្រេចពីមុននោះទេ។ សេចក្តីសម្រេចនេះត្រូវតែមានសំអាងហេតុជាពិសេស។

**មាត្រា ១១៦.-** ការចាត់ទុកជាអសារបង់នូវការផ្តន្ទាទោស

ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទលហុដែលមានការព្យួរទោសធម្មតា គ្មានការផ្តន្ទាទោសថ្មីណាមួយបានកើតឡើងពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការផ្តន្ទាទោសដែលព្យួរនោះ ត្រូវទុកជាអសារបង់ ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

## ផ្នែកទី ៣

## ការព្យួរទោសសាកល្បង

**មាត្រា ១១៧.-** និយមន័យ និងលក្ខខណ្ឌនៃការព្យួរទោសសាកល្បង

តុលាការអាចសម្រេចព្យួរសាកល្បងនូវទោសដែលបានសម្រេចដាក់ពន្ធនាគារដែលមានរយៈពេលពី ៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ ។

ការព្យួរទោសសាកល្បង មានអានុភាពដាក់ឱ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនក្នុងរយៈពេលសាកល្បង ។

**មាត្រា ១១៨.-** រយៈពេលនៃការសាកល្បង

តុលាការកំណត់រយៈពេលនៃការសាកល្បង។ រយៈពេលនេះមិនអាចតិចជាង ១ (មួយ) ឆ្នាំ និងមិនលើសពី ៣ (បី) ឆ្នាំ ទេ ។

**មាត្រា ១១៩.-** វិធានការត្រួតពិនិត្យ

វិធានការត្រួតពិនិត្យដែលតម្រូវទៅលើទណ្ឌិត មានដូចតទៅ :

១-ទណ្ឌិតត្រូវតែគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែល

ព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ ។

២-ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ ។

៣-ទណ្ឌិតត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ នូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឱ្យទៅរស់នៅក្នុងសង្គមវិញ ។

៤-ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន ។

៥-ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន ។

៦-ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស ។

**មាត្រា ១២០.-** កាតព្វកិច្ចដោយឡែកដែលអាចដាក់ទៅលើទណ្ឌិត

កាតព្វកិច្ចដោយឡែកដែលអាចតម្រូវទៅលើទណ្ឌិតមានដូចតទៅ :

១-បំពេញសកម្មភាពខាងវិជ្ជាជីវៈ ។

២-ទទួលការបង្ហាត់បង្រៀន ឬទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

៣-រស់នៅក្នុងទីកន្លែងណាមួយជាកំណត់ ។

៤-ទទួលឱ្យពេទ្យធ្វើការពិនិត្យ ឬការព្យាបាល ។

៥-បញ្ជាក់ថាខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ ។

៦-ធ្វើការជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើស តាមលទ្ធភាពនៃធនធានរបស់ខ្លួន ។

៧-បញ្ជាក់ថាខ្លួនបានបង់ប្រាក់ជូនរដ្ឋបន្ទាប់ពីការផ្តន្ទាទោស តាមលទ្ធភាពធនធានរបស់ខ្លួន ។

៨-មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈឬសង្គមដែលអនុញ្ញាត ឬសម្រួលដល់ការប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់ ។

៩-មិនត្រូវមានមុខនៅទីកន្លែងខ្លះ។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីទីកន្លែងដែលហាមឃាត់ ។

១០-មិនត្រូវសេពគប់បនល្បែង ។

១១-មិនត្រូវសេពគប់គ្រឿងភេសជ្ជៈស្រវឹង ។

១២-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេស ចារី សហចារី អ្នកផ្ដើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីបុគ្គលដែលមិនត្រូវសេពគប់ជាមួយ ។

១៣-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន តុលាការត្រូវចែងអំពីកាតព្វកិច្ចដោយឡែកដែលតម្រូវទៅលើទណ្ឌិត ។

**មាត្រា ១២១.-** ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ

នៅគ្រប់ពេលវេលា តុលាការអាចកែប្រែកាតព្វកិច្ចដោយឡែកដែលតម្រូវលើទណ្ឌិតបាន ។

តុលាការត្រូវបានទទួលបណ្ដឹងនៅក្នុងលក្ខខណ្ឌដែលបានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១២២.-** ការដកហូតការព្យួរទោសសាកល្បង

ការព្យួរទោសសាកល្បងអាចត្រូវដកហូតដោយតុលាការ នៅក្នុងករណីដូចខាងក្រោមនេះ :

១-ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតមិនគោរពតាមវិធានការត្រួតពិនិត្យ ឬកាតព្វកិច្ចដោយឡែកទេ ។

២-ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាថ្មីទៀត ។

តុលាការអាចបង្គាប់ឱ្យដកហូតការព្យួរទោសសាកល្បងនេះទាំងមូល ឬមួយផ្នែក ។ នៅក្នុងករណីនេះ ទោសត្រូវយកមកអនុវត្តទាំងមូល ឬមួយផ្នែក ។

តុលាការត្រូវបានទទួលបណ្ដឹងនៅក្នុងលក្ខខណ្ឌដែលមានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១២៣.-** ការផ្អន្ទាទោសដែលត្រូវចាត់ទុកជាអសារបង់

ការផ្អន្ទាទោសត្រូវចាត់ទុកជាអសារបង់ ប្រសិនបើមុនការផុតរយៈពេលសាកល្បង ការផ្អន្ទាទោសមិនមែនជាកម្មវត្ថុនៃពាក្យសុំដកហូតដែលមានសេចក្ដីសម្រេចដកហូតទេ ។

## ផ្នែកទី ៤
## ការផ្អាកការប្រកាសទោស

**មាត្រា ១២៤.-** លក្ខខណ្ឌនៃការផ្អាកការប្រកាសទោស

ក្នុងករណីចោទប្រកាន់ពីបទមជ្ឈិម តុលាការក្រោយពីបានប្រកាសថា ជនជាប់ចោទមានពិរុទ្ធ អាចផ្អាកការប្រកាសទោស ប្រសិនបើលក្ខខណ្ឌដូចតទៅនេះ ត្រូវបានបំពេញ :

-ភាពច្របូកច្របល់នៃសណ្ដាប់ធ្នាប់សាធារណៈ ដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ឈប់

-ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរៀមរស់នៅក្នុងសង្គមវិញ និង

-ជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត ។

**មាត្រា ១២៥.-** សេចក្ដីសម្រេចនៃការផ្អាកការប្រកាសទោស

ការផ្អាកការប្រកាសទោសអាចត្រូវបង្គាប់បាន លុះត្រាតែជនជាប់ចោទមានវត្តមានក្នុងសវនាការ ។

តុលាការកំណត់នៅក្នុងសាលក្រម ឬសាលដីកាខួវកាលបរិច្ឆេទដែលត្រូវសម្រេចអំពីទោស ។

សេចក្ដីសម្រេចអំពីទោសត្រូវតែធ្វើឡើងយ៉ាងយូរបំផុត ១ (មួយ) ឆ្នាំ ក្រោយសេចក្ដីសម្រេចផ្អាក ។

**មាត្រា ១២៦.-** សវនាការពិនិត្យរឿងដែលបង្អង់

នៅពេលសវនាការពិនិត្យរឿងដែលបង្អង់នេះ តុលាការសម្រេចអំពីទោស ។

## ផ្នែកទី ៥
## របបពាក់កណ្ដាលសេរីភាព

**មាត្រា ១២៧.-** លក្ខខណ្ឌនៃរបបពាក់កណ្ដាលសេរីភាព

កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ៦ (ប្រាំមួយ) ខែ តុលាការអាចសម្រេចថា ទោសត្រូវអនុវត្តក្រោមរបបពាក់កណ្ដាលសេរីភាព ដើម្បីអនុញ្ញាតឱ្យទណ្ឌិតអាចបំពេញសកម្មភាពវិជ្ជាជីវៈ ទទួលការសិក្សា ឬការបណ្ដុះបណ្ដាល ឬការពិនិត្យព្យាបាលជំងឺ ឬជួយឧបត្ថម្ភដល់សេចក្ដីត្រូវការរបស់គ្រួសារ ។

**មាត្រា ១២៨.-** បែបបទនៃរបបពាក់កណ្ដាលសេរីភាព

ទណ្ឌិតដែលស្ថិតនៅក្រោមរបបពាក់កណ្ដាលសេរីភាព ត្រូវបានអនុញ្ញាតឱ្យចាកចេញពីពន្ធនាគារ ក្នុងរយៈពេលជាកំណត់ ។

តុលាការកំណត់នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនអំពីថ្ងៃ និងម៉ោងដែលទណ្ឌិតត្រូវបានអនុញ្ញាតឱ្យមានអវត្តមាននៅក្នុងពន្ធនាគារ ។

**មាត្រា ១២៩.-** ការគិតបញ្ចូលរយៈពេលនៃពាក់កណ្ដាលសេរីភាពទៅក្នុងទោស

រយៈពេលនៃពាក់កណ្ដាលសេរីភាព ត្រូវគិតបញ្ចូលទៅក្នុងថិរវេលានៃទោសដែលកំពុងអនុវត្ត ។

**មាត្រា ១៣០.-** ការរៀបចំ និងការលុបចោលនៃរបបពាក់កណ្ដាលសេរីភាព

នៅគ្រប់ពេល តុលាការអាចរៀបចំរយៈពេលនៃពាក់កណ្ដាលសេរីភាព ឬក៏លុបចោលនូវរបបពាក់កណ្ដាលសេរីភាព តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា ។

តុលាការត្រូវបានទទួលដំណឹងនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១៣១.-** ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនវិលត្រឡប់មកពន្ធនាគារវិញ នៅពេលផុតកំណត់រយៈពេលនៃពាក់កណ្ដាលសេរីភាព ។

## ផ្នែកទី ៦
## ការបែងចែកទោសជាប្រភាគ

**មាត្រា ១៣២.-** លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ

កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ១ (មួយ) ឆ្នាំ តុលាការអាចសម្រេចថា ទោសនោះត្រូវអនុវត្តជាប្រភាគ ដោយមូលហេតុធ្ងន់ធ្ងរដែលមានលក្ខណៈជាគ្រួសារ ជាវេជ្ជសាស្ត្រ ជាវិជ្ជាជីវៈ ឬជាសង្គម។

**មាត្រា ១៣៣.-** បែបបទនៃការបែងចែកទោសជាប្រភាគ

ប្រភាគនៃទោសនីមួយៗ មិនត្រូវតិចជាង ១ (មួយ) ខែ ទេ ។ ថិរវេលាសរុបនៃការអនុវត្តទោសមិនអាចលើសពី ២ (ពីរ) ឆ្នាំ ទេ ដោយរាប់បញ្ចូលទាំងការផ្អាកការអនុវត្តទោស ។

តុលាការកំណត់ក្នុងសេចក្ដីសម្រេចរបស់ខ្លួនអំពីបែបបទនៃការបែងចែកទោសជាប្រភាគ ។

**មាត្រា ១៣៤.-** ការកែប្រែរបបនៃការបែងចែកទោសជាប្រភាគ

នៅគ្រប់ពេលវេលា តុលាការអាចរៀបចំបែបបទនៃការបែងចែកទោសជាប្រភាគ ឬលុបចោលរបបនៃការបែងចែកទោសជាប្រភាគ តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា ។

តុលាការត្រូវបានទទួលបណ្ដឹងនៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១៣៥.-** ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនវិលត្រឡប់មក

៤-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

**មាត្រា ១៦២.-** ទោសការងារសហគមន៍

ទោសដែលជាការងារសហគមន៍ អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦ (ដប់ប្រាំមួយ) ឆ្នាំ ប៉ុន្តែ ថិរវេលានៃការងារមិនអាចលើសពី ១០០ (មួយរយ) ម៉ោង ។

ការងារសហគមន៍ត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈជាការបណ្ដុះបណ្ដាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ ។

**មាត្រា ១៦៣.-** ការមិនអនុវត្តបទប្បញ្ញត្តិស្ដីពីការមិនរាងចាល

បទប្បញ្ញត្តិស្ដីពីការមិនរាងចាល មិនអនុវត្តទៅលើអនីតិជនទេ ។

**មាត្រា ១៦៤.-** ការទទួលប្រយោជន៍នៃស្ថានសម្រាលទោស

ស្ថានសម្រាលទោសត្រូវអនុវត្តទៅលើអនីតិជន ។

កាលបើតុលាការបានសម្រេចឱ្យមានស្ថានសម្រាលទោស អប្បបរមានៃមូលទោស លើអនីតិជនពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបន្ថយតាមខ្នាតដោយឡែកដូចតទៅ :

១-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ១ (មួយ) ឆ្នាំ ។

២-ប្រសិនបើអប្បបរមានៃទោសជាប់ពន្ធនាគារស្មើ ឬលើសពី ៥ (ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ ។

៣-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ (ពីរ) ឆ្នាំ និងតិចជាង ៥ (ប្រាំ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៣ (បី) ខែ ។

៤-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងតិចជាង ២ (ពីរ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយត្រឹម ១ (មួយ) ថ្ងៃ ។

៥-អប្បបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

**មាត្រា ១៦៥.-** កាតព្វកិច្ចដោយឡែកក្នុងករណីនៃការលួរទោសសាកល្បង

នៅក្នុងករណីនៃការលួរទោសសាកល្បង មានតែកាតព្វកិច្ចដោយឡែកដូចតទៅនេះប៉ុណ្ណោះដែលអាចអនុវត្តទៅលើអនីតិជន :

១-ទទួលការបង្ហាត់បង្រៀន ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

២-ស្ថិតនៅទីកន្លែងមួយជាកំណត់ ។

៣-ដាក់ខ្លួនឱ្យពេទ្យពិនិត្យ ឬព្យាបាល ។

៤-ជួសជុលល្មសនកម្មដែលបណ្តាលមកអំពីបទល្មើស ទៅតាមធនធានរបស់ខ្លួន ។

៥-បង្ហាញភស្តុតាង បញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយ តាមលទ្ធភាពនៃធនធានរបស់ខ្លួន បន្ទាប់ពីការផ្តន្ទាទោស ។

៦-មិនត្រូវបង្ហាញមុខនៅទីកន្លែងខ្លះ ។

៧-មិនត្រូវសេពគប់ ទីកន្លែងលក់ភេសជ្ជៈស្រវឹង ។

៨-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ដោយឡែកជាមួយសហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស ។

៩-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។ជ

## ផ្នែកទី ២
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៦៦.-** លក្ខខណ្ឌនៃការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារ

អនីតិជនដែលជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅទីកន្លែងពិសេស ខណ្ឌដាច់ពីនីតិជន ។ អនីតិជនស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គល ដែលជាទីកន្លែង

សម្រាប់អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

របបឃុំឃាំងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ។

## ជំពូកទី ៧
## ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល
### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦៧.-** ទោសដែលត្រូវរងដោយនីតិបុគ្គល

ទោសជាយថាប្រភេទដែលត្រូវរងដោយនីតិបុគ្គលមានដូចតទៅ :

១-ទោសពិន័យក្នុងឋានៈជាមូលទោស ។

២-ទោសបន្ថែមដែលរៀបរាប់នៅក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមនេះ ។

### ផ្នែកទី ២
### ទោសបន្ថែម

**មាត្រា ១៦៨.-** ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល

ទោសបន្ថែមត្រូវអនុវត្តទៅលើនីតិបុគ្គលមានដូចតទៅ :

១-ការរំលាយចោល ។

២-ការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។

៣-ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬច្រើន ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសៃ ។

៦-ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបាន ដែលកំណត់ដោយធនាគារ ។

៧-ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់ ។

៨-ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស ។

៩-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលបានប្រើប្រាស់ដោយសាធារណជន ។

១០-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស ។

១១-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

១២-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

១៣-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

១៤-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បទប្បញ្ញត្តិដោយឡែកអាចបង្កើតទោសបន្ថែមដទៃទៀតបាន ។

**មាត្រា ១៦៩.-** លក្ខខណ្ឌនៃការសម្រេចអំពីទោសបន្ថែម

ទោសបន្ថែមអាចនឹងប្រកាសបានដោយតុលាការ ប្រសិនបើទោសនោះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសដែលចោទប្រកាន់ ។

**មាត្រា ១៧០.-** ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល

សេចក្ដីសម្រេចដែលបង្គាប់ឱ្យរំលាយនីតិបុគ្គល នាំឱ្យមានការបញ្ជូននីតិបុគ្គលនេះទៅតុលាការមានសមត្ថកិច្ច ដើម្បីធ្វើការជម្រះបញ្ជី ។

**មាត្រា ១៧១.-** ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ

ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការមិនអាចលើសពី ៥ (ប្រាំ) ឆ្នាំ ទេ ។ សេចក្ដីសម្រេចដាក់ការត្រួតពិនិត្យតាមដានរបស់តុលាការនាំឱ្យមានការចាត់តាំងអាណត្តិគាហកតុលាការដែលតុលាការបញ្ជាក់បេសកកម្ម ។

ជារៀងរាល់ ៦ (ប្រាំមួយ) ខែ យ៉ាងតិច អាណត្តិគាហកតុលាការធ្វើរបាយការណ៍ជូនព្រះរាជអាជ្ញាអំពីដំណើរការនៃបេសកកម្មរបស់ខ្លួន ។

ក្រោយពីបានឃើញរបាយការណ៍របស់អាណត្តិគាហកតុលាការ ព្រះរាជអាជ្ញាអាចប្ដឹងទៅតុលាការដែលបានប្រកាសឱ្យធ្វើការដាក់ក្រោមការតាមដានរបស់តុលាការ ។ តុលាការអាចប្រកាសនូវទោសថ្មីមួយ ។

តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្ដាប់យោបល់របស់តំណាងអយ្យការ អាណត្តិគាហកតុលាការ និងជាយថាហេតុ មេធាវីរបស់នីតិបុគ្គលនោះ ។

**មាត្រា ១៧២.-** ការហាមឃាត់ចំពោះការធ្វើសកម្មភាព

ការហាមឃាត់ចំពោះការធ្វើសកម្មភាព អាចជាស្ថាពរ ឬជាបណ្ដោះអាសន្នសម្រាប់ចិរវេលា ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

តុលាការបញ្ជាក់អំពីសកម្មភាពដែលត្រូវហាមឃាត់ ។

**មាត្រា ១៧៣.-** ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ

ទោសបណ្ដេញចេញពីលទ្ធកម្មសាធារណៈ នាំឱ្យមានការហាមឃាត់ចំពោះការចូលរួម ដោយផ្ទាល់ ឬដោយប្រយោលនៅក្នុងគ្រប់លទ្ធកម្មសាធារណៈដែលរៀបចំ ដោយ :

១-រដ្ឋ ។

២-រដ្ឋបាលថ្នាក់ក្រោមជាតិ ។

៣-គ្រឹះស្ថានសាធារណៈ ។

៤-សហគ្រាសដែលទទួលសម្បទានពីរដ្ឋឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬដែលត្រួតពិនិត្យដោយរដ្ឋឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទោសនេះ អាចជាស្ថាពរ ឬជាបណ្ដោះអាសន្ន សម្រាប់ចិរវេលាមួយមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

**មាត្រា ១៧៤.-** ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ

ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ឱ្យធ្វើការដាក់ប្រាក់សន្សំ

## ឧបសម្ព័ន្ធទី៣ ៖

## ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ឧបសម្ព័ន្ធទី ៣



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមនីតិវិធីព្រហ្មទណ្ឌ
# នៃ
# ព្រះរាជាណាចក្រកម្ពុជា

ឆ្នាំ ២០១១

www.elibraryofcambodia.org

**មាត្រា ៨.-** មូលហេតុផ្សេងទៀតនៃការរលត់បណ្ដឹងអាជ្ញា

កាលណាច្បាប់ដោយឡែកបានចែងដោយជាក់លាក់ នោះបណ្ដឹងអាជ្ញាក៏អាចផុតរលត់បានដែរ :

១-ដោយការសម្របសម្រួលជាមួយរដ្ឋ ។

២-ដោយការដកពាក្យប្ដឹង នៅក្នុងករណីដែលពាក្យប្ដឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ ។

៣-ដោយការបង់ប្រាក់ពិន័យសុទ្ធ ឬប្រាក់ពិន័យសម្របសម្រួល ។

**មាត្រា ៩.-** ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់

បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម មិនអាចផុតអាជ្ញាយុកាលបានទេ ។

**មាត្រា ១០.-** អាជ្ញាយុកាលនៃបទល្មើស

លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ៩ (ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់) នៃក្រមនេះចេញ ថិរវេលានៃអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញាមានដូចតទៅគឺ :

-១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ

-៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម

-១ (មួយ) ឆ្នាំ ចំពោះបទលហុ

**មាត្រា ១១.-** ការផ្ដាច់រយៈពេលនៃអាជ្ញាយុកាល

ថិរវេលានៃអាជ្ញាយុកាល ត្រូវចាប់ផ្ដើមគិតពីពេលប្រព្រឹត្តបទល្មើស ។ អាជ្ញាយុកាលត្រូវផ្ដាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ ។ ការបញ្ចប់កិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរនីមួយៗ នាំឱ្យចាប់ផ្ដើមគិតថិរវេលាថ្មីនៃអាជ្ញាយុកាលតាមការវែកញែកនៃមាត្រា ១០ (អាជ្ញាយុកាលនៃបទល្មើស) នៃក្រមនេះ ។ ថិរវេលាថ្មីអាចយកទៅជំទាស់បាន ចំពោះជនគ្រប់រូបដែលទាក់ទិននៅក្នុងរឿងនេះ ។

**មាត្រា ១២.-** អាជ្ញាអស់ជំនុំ

ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ ។

## គន្ថីទី ៨
## នីតិវិធីប្រតិបត្តិ
### មាតិកាទី ១
### បទប្បញ្ញត្តិទូទៅ
### ជំពូកតែមួយ
### បទប្បញ្ញត្តិទូទៅ

**មាត្រា ៤៩៦.** – ការអនុវត្តទោស និងទណ្ឌកម្មរដ្ឋប្បវេណី

ការអនុវត្តទោស និងការបង្ខំដល់រូបកាយត្រូវធ្វើតាមគំនិតផ្តើមរបស់អយ្យការ ។

ការអនុវត្តទណ្ឌកម្មរដ្ឋប្បវេណីត្រូវតែធ្វើតាមគំនិតផ្តើមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

**មាត្រា ៤៩៧.** – សេចក្តីសម្រេចស្ថាពរ

អយ្យការធ្វើការអនុវត្តទោស នៅពេលដែលសេចក្តីសម្រេចរបស់តុលាការ បានក្លាយទៅជាស្ថាពរ ។

រយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា មិនមែនជាឧបសគ្គដល់ការអនុវត្តទោសទេ ។

**មាត្រា ៤៩៨.** – ការប្រមូលប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធី

ការប្រមូលប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធីត្រូវធ្វើដោយភ្នាក់ងាររតនាគារ នៅក្រោមនិវាទរបស់អយ្យការ ។ ប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធីដែលប្រមូលបាននេះ ត្រូវបង់ចូលថវិការដ្ឋ ។

គ្រប់សេចក្តីសម្រេចផ្តន្ទាទោសជាស្ថាពរ មានតំលៃជាបញ្ជាឱ្យបង់ប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធី ។

**មាត្រា ៤៩៩.** – ការសុំកងកម្លាំងសាធារណៈ

ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា អាចសុំកងកម្លាំងសាធារណៈ ដើម្បីធានាអំពីរាល់ការអនុវត្តទោស ។

**មាត្រា ៥០០.** – ការលំបាកទាក់ទងនឹងការអនុវត្តទោស

ការលំបាកទាំងឡាយដែលទាក់ទងនឹងការអនុវត្តទោស ត្រូវតែលើកជូនតុលាការជាន់ដំបូង ឬតុលាការជាន់ខ្ពស់ ដែលបានសម្រេចផ្តន្ទាទោសនោះ ដោះស្រាយ ។

តុលាការទទួលបណ្តឹង តាមពាក្យប្តឹងរបស់អយ្យការ ឬរបស់ភាគីពាក់ព័ន្ធ ។ តុលាការនេះសម្រេចនៅពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់អយ្យការ ភាគីពាក់ព័ន្ធ និងជាយថាហេតុមេធាវីរបស់ភាគីនេះ ។

ការអនុវត្តទោសអាចត្រូវបានព្យួរដោយតុលាការ ។

**មាត្រា ៥០១.** – ពាក្យសុំឱ្យស្រូបទោសបញ្ចូលគ្នា

ពាក្យសុំឱ្យស្រូបទោសបញ្ចូលគ្នា ត្រូវលើកនៅមុខតុលាការដែលបានសម្រេចចុងក្រោយគេ ។

តុលាការនេះទទួលបណ្ដឹង តាមពាក្យប្ដឹងរបស់អយ្យការ ឬរបស់ភាគីពាក់ព័ន្ធ ។ តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្ដាប់អយ្យការ ភាគីពាក់ព័ន្ធ និងជាយថាហេតុមេធាវីរបស់ភាគីនេះ ។

## មាតិកាទី ២

## ការប្រតិបត្តិការឃុំខ្លួនបណ្ដោះអាសន្ន និងទោសដកហូតសេរីភាព

### ជំពូកទី ១

### ចំនួនពាក់ព័ន្ធនឹងការឃុំខ្លួន

**មាត្រា ៥០២.** – ការគណនារយៈពេលនៃការដាក់ពន្ធនាគារ

ទោសដាក់ពន្ធនាគារក្នុង ១ (មួយ) ថ្ងៃ មានរយៈពេល ២៤ (ម្ភៃបួន) ម៉ោង ។

ទោសដាក់ពន្ធនាគារ ក្នុង ១ (មួយ) ខែ មានរយៈពេល ៣០ (សាមសិប) ថ្ងៃ ។

ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមលេខរៀងនៃថ្ងៃក្នុងខែទី ១ (មួយ) ទៅលេខរៀងនៃថ្ងៃក្នុងខែមួយទៀត ។

ទណ្ឌិតដែលបានអនុវត្តទោសរបស់ខ្លួនរួចហើយ ត្រូវដោះលែងនៅក្នុងចន្លោះពីម៉ោង ៦ (ប្រាំមួយ) ព្រឹក ដល់ម៉ោង ១៨ (ដប់ប្រាំបី) ល្ងាច ។

**មាត្រា ៥០៣.** – ការគិតបញ្ចូលរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន

រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវបានគិតបញ្ចូលទាំងស្រុងទៅក្នុងរយៈពេលនៃទោសដែលបានប្រកាស ឬជាយថាហេតុនៃរយៈពេលសរុបនៃទោសដែលត្រូវទទួលរង បន្ទាប់ពីការស្រូបទោសបញ្ចូលគ្នា ។

**មាត្រា ៥០៤.** – ការរៀបចំពន្ធនាគារ

ការរៀបចំ និងរបបផ្ទៃក្នុងនៃពន្ធនាគារ និងមណ្ឌលឃុំខ្លួន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងដែលគ្រប់គ្រងពន្ធនាគារ ។

ប្រកាសនេះកំណត់ផងដែរ អំពីលក្ខខណ្ឌនៃការបែងចែកទណ្ឌិតទៅតាមពន្ធនាគារ និងមណ្ឌលឃុំខ្លួននានា អំពីរបៀបបទអនុវត្តទោសដកហូតសេរីភាព និងអំពីរបបឃុំខ្លួន ។

# ឧបសម្ព័ន្ធទី៤ ៖ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន

# ច្បាប់

## ស្តីពី

# យុត្តិធម៌អនីតិជន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២/៣៩

# ព្រះរាជក្រម

នស/រកម/០៧១៦/០០៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.- គោលបំណង

ច្បាប់នេះមានគោលបំណង៖

- ធានាការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនដែលប្រព្រឹត្តបទល្មើស
- គាំទ្រដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និងសហគមន៍
- ធានាការពារផលប្រយោជន៍សង្គមនិងសហគមន៍ ។

### មាត្រា ២.- គោលដៅ

ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឲ្យបានច្បាស់នូវអត្តិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយដែលប្រព្រឹត្តដោយអនីតិជន ។

បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ និងច្បាប់ដោយឡែកផ្សេងទៀត ត្រូវយកមកអនុវត្ត លើកលែងតែក្នុងករណីដែលមានចែងនៅក្នុងច្បាប់នេះ ។

### មាត្រា ៣.- វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តលើករណីអនីតិជនប្រព្រឹត្តបទល្មើស ។

### មាត្រា ៤.- និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ៖

១- យុត្តិធម៌អនីតិជន សំដៅដល់ការការពារសិទ្ធិអនីតិជនតាមរយៈយន្តការ វិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងអនុវត្តដោយហ្មត់ចត់ ព្រមទាំងវិធាននៃការកំណត់ទោសក្នុងករណីអនីតិជនប្រព្រឹត្តបទល្មើស ។

២- អាជ្ញាធរមានសមត្ថកិច្ច សំដៅដល់បុគ្គល ឬស្ថាប័នដែលអនុវត្តដោយស្របច្បាប់នូវមុខងាររបស់ខ្លួនដែលពាក់ព័ន្ធនឹងរឿងក្តីអនីតិជន ។

៣- អនីតិជន សំដៅដល់ជនដែលមានអាយុតិចជាង ១៨ (ដប់ប្រាំបី) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស ។

៤- អនីតិជនត្រូវការកិច្ចការពារ និងថែទាំ សំដៅដល់អនីតិជនដែលត្រូវការកិច្ចការពារ និងថែទាំ ដោយមូលហេតុអនីតិជននោះគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ឬគ្មានការថែទាំ និងគ្រប់គ្រងត្រឹមត្រូវពីសំណាក់អ្នកតំណាងដែលច្បាប់បានកំណត់ ហើយកំពុងប្រឈមនឹងសភាពគ្រោះថ្នាក់ ឬរងការរំលោភបំពាន ឬបង្ហាញការគំរាមកំហែងដល់សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬគំរាមកំហែងដល់សុវត្ថិភាពផ្ទាល់ខ្លួន ។

៥- អ្នកតំណាងដែលច្បាប់បានកំណត់ សំដៅដល់អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអ្នកអាណាព្យាបាលទូទៅ ។

៦- អ្នកទំនុកបម្រុង សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលត្រូវបានជ្រើសរើសដោយអនីតិជន ឬដោយអាជ្ញាធរមានសមត្ថកិច្ច និងមានការយល់ព្រមពីអនីតិជនឲ្យទទួលខុសត្រូវក្នុងការទំនុកបម្រុងខ្លួនក្នុងអំឡុងពេលអនុវត្តនីតិវិធីដែលមានចែងក្នុងច្បាប់នេះ ។

៧- នីតិវិធីកុមារមេត្រី សំដៅដល់ដំណើរការ និងនីតិវិធីដែលពាក់ព័ន្ធនឹងការលើកទឹកចិត្តឲ្យអនីតិជនចូលរួមក្នុងរឿងក្តី តាមរយៈការប្រើប្រាស់ភាសានិងអាកប្បកិរិយាក្នុងកម្រិតដែលអនីតិជនអាចយល់បាន និងក្នុងបរិយាកាសដែលផ្តល់ឲ្យអនីតិជននូវសុវត្ថិភាព សន្តិសុខ សិទ្ធិ និងតម្រូវការជាមូលដ្ឋាន ។

៨- របាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន សំដៅដល់របាយការណ៍ស្តីពីស្ថានភាពទូទៅរបស់អនីតិជន និងការផ្តល់យោបល់វាយតម្លៃផ្សេងៗដែលធ្វើឡើងដោយភ្នាក់ងារសង្គមកិច្ច ។

៩- ភ្នាក់ងារសង្គមកិច្ច សំដៅដល់មន្ត្រីរបស់ក្រសួង មន្ទីរ ការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬបុគ្គលផ្សេងទៀតដែលទទួលបានការបណ្តុះបណ្តាលជំនាញផ្នែកកុមារ និងច្បាប់ពាក់ព័ន្ធនឹងអនីតិជន ហើយត្រូវទទួលបានការតែងតាំង ឬទទួលស្គាល់ពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

១០- មណ្ឌលយុវនីតិសម្បទា សំដៅដល់មណ្ឌលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច សម្រាប់ផ្តល់សេវាការពារ ថែទាំ អប់រំ ស្តារនីតិសម្បទា និងសមាហរណកម្មដល់អនីតិជន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·

# ជំពូកទី ២
## គោលការណ៍ និងសិទ្ធិជាមូលដ្ឋានរបស់អនីតិជន

### មាត្រា ៥.- គោលការណ៍ជាមូលដ្ឋាន

គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឲ្យមានការគោរពគោលការណ៍ដូចតទៅ ៖

- ត្រូវយកចិត្តទុកដាក់ និងពិចារណាពល់សកម្មភាពពាក់ព័ន្ធនឹងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេស ធានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមា
- ត្រូវប្រព្រឹត្តប្រកបដោយមនុស្សធម៌ និងសេចក្តីថ្លៃថ្នូរទៅលើអនីតិជន
- ត្រូវផ្តល់ឱកាសឲ្យអនីតិជនសម្តែងមតិដោយសេរី ហើយទស្សនៈនោះត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងស្របទៅតាមអាយុ ការរីកចម្រើនផ្នែករូបកាយ បញ្ញាស្មារតី និងកម្រិតនៃការយល់ដឹងរបស់អនីតិជនចំពោះសកម្មភាពរបស់ខ្លួន
- ត្រូវអនុវត្តទៅតាមនីតិវិធីកុមារមេត្រី
- ត្រូវអនុវត្តការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និងការសម្រេចផ្តន្ទាទោសអនីតិជនជាវិធានការចុងក្រោយ និងមានរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន
- មិនត្រូវរើសអើងចំពោះអនីតិជន មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា ឋានៈសង្គម ធនធាន ដើមកំណើតជាតិ និន្នាការនយោបាយ ឬស្ថានភាពឯទៀត
- មិនត្រូវប្រើខ្នោះ និងឧបករណ៍ផ្សេងៗទៀតដែលប៉ះពាល់ដល់បូរណភាពរូបរាងកាយរបស់អនីតិជន លើកលែងតែក្នុងករណីចាំបាច់បំផុតប៉ុណ្ណោះដែលវិធានការទាំងឡាយមិនអាចអនុវត្តបាន ឬគ្មានប្រសិទ្ធភាព
- មិនត្រូវប្រើទារុណកម្ម ទណ្ឌកម្ម ឬប្រព្រឹត្តកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក តាមគ្រប់រូបភាពទៅលើរូបកាយ និងផ្លូវចិត្តរបស់អនីតិជន
- មិនត្រូវបញ្ចេញ ឬផ្សព្វផ្សាយរូបភាព និងព័ត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងសកម្មភាពរបស់អនីតិជន និងដែលនាំឲ្យបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជន ហើយដែលអាចមានឥទ្ធិពលលើសម្បទាកុមារក្នុងការទទួលបាននូវការអប់រំ ការងារ ការស្នាក់នៅ ឬសុវត្ថិភាព ។ ការផ្សព្វផ្សាយរឿងក្តីអាចធ្វើទៅបាន លុះត្រាតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា ដើម្បីផលប្រយោជន៍សាធារណៈប៉ុណ្ណោះ ប៉ុន្តែមិនត្រូវបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជនឡើយ
- សន្មតថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ROYAUME du CAMBODGE * SECRETARIAT du PALAIS ROYAL

### មាត្រា ៦.- សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី

អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ ៖

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានការឲ្យដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃ ស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី
- សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ
- សិទ្ធិស្នើសុំឲ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស
- សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន ។

## ជំពូកទី ៣
## ការទទួលខុសត្រូវព្រហ្មទណ្ឌ និងវិជ្ជមានភាពរបស់អនីតិជន

### មាត្រា ៧.- ការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ លើកលែងតែករណីមានចែងពិសេសនៅក្នុងច្បាប់ផ្សេងទៀត ។

## មាត្រា ៨.- ការទទួលខុសត្រូវរដ្ឋប្បវេណី

បទប្បញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៧៤៥ (អសមត្ថភាពក្នុងការទទួលខុសត្រូវ) និងមាត្រា ៧៤៦ (ការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ) នៃជំពូកទី ១៦ (អំពើអនីត្យានុកូល) ក្នុងគន្ថីទី ៥ (កិច្ចសន្យាសំខាន់ៗ និងអំពើអនីត្យានុកូល)នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះការទទួលខុសត្រូវរដ្ឋប្បវេណីរបស់អនីតិជន ។

## មាត្រា ៩.- ការកំណត់អាយុ

អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ត្រូវកំណត់យកអាយុនៅពេលដែលអនីតិជននោះប្រព្រឹត្តបទល្មើស ។

ភស្តុតាងនៃអាយុរបស់អនីតិជន ត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងទៀតដែលអាចបញ្ជាក់បានអំពីកំណើត ។ ក្នុងករណីពុំមានឯកសារ ឬមានការសង្ស័យ ឬមិនមានភាពច្បាស់លាស់ទាក់ទងនឹងយថាភូតនៃឯកសារនោះ ភស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន ។

អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វះស្វែងរកភស្តុតាង ដើម្បីកំណត់អាយុរបស់អនីតិជនឲ្យបានឆាប់រហ័សបំផុតដែលអាចធ្វើទៅបាន ។

ក្នុងករណីមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជននោះ ។

# ជំពូកទី ៤
# ជំនួយផ្នែកសេវាសង្គមកិច្ច

## មាត្រា ១០.- ការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច

ការតែងតាំង ការទទួលស្គាល់ និងការគ្រប់គ្រងភ្នាក់ងារសង្គមកិច្ចជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

បែបបទនៃការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច។

## មាត្រា ១១.- ភ្នាក់ងារសង្គមកិច្ច

ភ្នាក់ងារសង្គមកិច្ចមានភារកិច្ចជាអាទិ៍ ៖

- ជួបអនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធី ជាពិសេស នៅដំណាក់កាលដំបូងនៃនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ និងនៅក្នុងពន្ធនាគារ ដើម្បីប្រមូលព័ត៌មានវាយតម្លៃ និងផ្តល់សេវាបន្ទាន់ដល់អនីតិជន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- ប្រមូលព័ត៌មានស្តីពីស្ថានភាពគ្រួសារ អាកប្បកិរិយា ប្រវត្តិអប់រំ ការសិក្សា លក្ខខណ្ឌដែលទាក់ទងនឹងការរស់នៅ ការរកែលុតលាស់ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតដែលទាក់ទងនឹងកម្រិតយល់ដឹង បញ្ហាអារម្មណ៍ ផ្លូវចិត្ត សង្គមរបស់អនីតិជន ដើម្បីរៀបចំ និងផ្តល់របាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនជូនចៅក្រម អយ្យការ និងតុលាការ
- ផ្តល់ការគាំទ្រផ្លូវចិត្ត និងសង្គមដល់អនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធី
- រៀបចំ និងផ្តល់ផែនការបង្វែរជូនអាជ្ញាធរទទួលបន្ទុកបង្វែរ ដើម្បីពិនិត្យ និងសម្រេច
- ផ្តល់សេវាស្តារនីតិសម្បទា និងធ្វើសមាហរណកម្មអនីតិជន
- ភារកិច្ចចាំបាច់ផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

## ជំពូកទី ៥
## នគរបាលយុត្តិធម៌ និងការស៊ើបអង្កេត

### មាត្រា ១២.- សមត្ថកិច្ចនគរបាលយុត្តិធម៌ក្នុងការពិនិត្យបទឧក្រិដ្ឋ និងបទមជ្ឈិម

នគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម កំណត់អត្តសញ្ញាណ និងចាប់អនីតិជន ព្រមទាំងប្រមូលភស្តុតាង ។

នគរបាលយុត្តិធម៌ដែលចាប់ខ្លួន ឬមន្ត្រីនគរបាលយុត្តិធម៌ដែលឃាត់ខ្លួនអនីតិជន ត្រូវប្រគល់របាយការណ៍ និងកំណត់ហេតុលម្អិតស្តីពីការចាប់ ឬឃាត់ខ្លួន និងប្រគល់អនីតិជននោះទៅឲ្យផ្នែក ឬអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន ។

### មាត្រា ១៣.- អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការពិនិត្យ និងដោះស្រាយបទលហុ

អនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ បានប្រព្រឹត្តបទលហុ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការអប់រំណែនាំ ព្រមានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ រួចហើយប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ជាបន្ទាន់ ។

ក្នុងករណីអនីតិជនបានសារភាពថាបានប្រព្រឹត្តបទល្មើស ហើយបទល្មើសនោះជាបទលហុ នគរបាលយុត្តិធម៌អាចធ្វើការសម្រុះសម្រួលរវាងភាគីពាក់ព័ន្ធដើម្បីបញ្ចប់វិវាទ ។

ករណីដែលមានចែងក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ នគរបាលយុត្តិធម៌ត្រូវធ្វើរបាយការណ៍ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីចាត់ការតាមច្បាប់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជន ។ មន្ទីរឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជនពីនគរបាលយុត្តិធម៌ ជូនទៅព្រះរាជអាជ្ញា ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ ក្នុងករណីដែលអនីតិជនគ្មានអ្នក តំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យត្រូវសុំទៅតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

**មាត្រា ១៤.- នីតិវិធីទាក់ទងនឹងអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ**

អនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។ មន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជនពីមន្ត្រីនគរបាលយុត្តិធម៌ ជូនទៅព្រះរាជអាជ្ញា ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

គ្រប់អំពើដែលជាបទល្មើសទាំងអស់ដែលប្រព្រឹត្តដោយអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ក្នុងករណីមានវិវាទទាក់ទងនឹងអាយុរបស់អនីតិជននៅពេលប្រព្រឹត្តបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿងនេះទៅព្រះរាជអាជ្ញាជាបន្ទាន់ ។

## មាត្រា ១៥.- ការចាប់ខ្លួន

នគរបាលយុត្តិធម៌អាចចាប់ខ្លួនអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ តែក្នុងករណីដែលអនីតិជនប្រព្រឹត្តបទមជ្ឈិម ឬបទឧក្រិដ្ឋជាក់ស្តែងតែប៉ុណ្ណោះ ។ ប៉ុន្តែអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ ការចាប់ខ្លួនអាចធ្វើទៅបានតែក្នុងករណីដែលអនីតិជននោះប្រព្រឹត្តបទមជ្ឈិមដោយចេតនា ។ រាល់ការចាប់ខ្លួនអនីតិជនត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម។

ការអនុវត្តការចាប់ខ្លួន នគរបាលយុត្តិធម៌ត្រូវចៀសវាងការធ្វើឲ្យអាម៉ាស់មុខនិងបាត់បង់សេចក្តីថ្លៃថ្នូររបស់អនីតិជន និងត្រូវបញ្ជូនអនីតិជនទៅឲ្យផ្នែក ឬអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជនដែលនៅជិតបំផុត ។

## មាត្រា ១៦.- ការឆែកឆេរលើខ្លួនបុគ្គល

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរលើខ្លួនបុគ្គលដែលជាអនីតិជនបាន ។ ការឆែកឆេរខ្លួនបុគ្គលត្រូវធ្វើឡើងដោយបុគ្គលដែលមានភេទដូចគ្នា និងមិនត្រូវជាប់ពាក់ព័ន្ធនឹងបទល្មើស ពុំមានទំនាស់ ឬមិនជាប់សាច់ញាតិ ឬមានទំនាក់ទំនងជិតស្និទ្ធជាមួយអនីតិជននោះឡើយ លើកលែងតែក្នុងករណីមិនអាចចៀសវាងបាន ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុនិងចុះនិទ្ទេសអំពីបញ្ហានេះ ។

## មាត្រា ១៧.- ការឃាត់ខ្លួនអនីតិជនប្រព្រឹត្តបទល្មើស

មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំបាន ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ជឿជាក់ថាអនីតិជនអាចគេចខ្លួន ឬបំផ្លាញភស្តុតាង ឬបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាក្សី ជនរងគ្រោះ ឬសន្តិសុខសាធារណៈ ឬក្នុងគោលបំណងការពារសុវត្ថិភាពអនីតិជននោះ ។ ប៉ុន្តែ អនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ ការឃាត់ខ្លួនអាចធ្វើទៅបានតែក្នុងករណីដែលអនីតិជន នោះប្រព្រឹត្តបទមជ្ឈិមដោយចេតនា ។ រាល់ការឃាត់ខ្លួនអនីតិជន ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម ។ ការឃាត់ខ្លួននេះ សម្រាប់តែជាវិធានការចុងក្រោយប៉ុណ្ណោះ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ចប់ដំណើរការស៊ើបអង្កេតឲ្យបានលឿនបំផុតដែលអាចធ្វើទៅ

## មាត្រា ១៨.- ការជូនដំណឹងបន្ទាប់ពីការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជន

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងជាបន្ទាន់ទៅអ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជនបន្ទាប់ពីការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជននោះ ។ ក្នុងករណីមិនអាចផ្តល់ដំណឹងនេះជាបន្ទាន់ ត្រូវជូនដំណឹងដល់អ្នកតំណាងដែលច្បាប់បានកំណត់ក្នុងរយៈពេលយ៉ាងខ្លីបំផុតដែលអាចធ្វើ ទៅបាន អំពី ៖

- មូលហេតុនៃការចាប់ខ្លួន ឬឃាត់ខ្លួន និងប្រភេទនៃបទល្មើស
- ទីកន្លែងដែលអនីតិជនកំពុងស្ថិតនៅ
- សិទ្ធិចូលរួមរបស់អ្នកតំណាងដែលច្បាប់បានកំណត់នៅអង្គភាពនគរបាល ។

ក្នុងករណីមិនអាចទាក់ទងអ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជនបាន មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រឹងប្រែងទាក់ទងអ្នកទំនុកបម្រុងដែលជ្រើសរើសដោយអនីតិជន ឬដោយមន្ត្រីនគរបាលយុត្តិធម៌ ដោយមានការយល់ព្រមពីអនីតិជននោះ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងភ្លាមផងដែរទៅភ្នាក់ងារសង្គមកិច្ច បន្ទាប់ពីអនីតិជននោះត្រូវបាននាំមកដល់អង្គភាពនគរបាលយុត្តិធម៌ ដើម្បីផ្តល់សេវាគាំទ្រផ្លូវចិត្ត និងសង្គមដល់អនីតិជននោះ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងភ្លាមទៅមេធាវីរបស់អនីតិជន ប្រសិនបើមាន ។ ក្នុងករណីដែលគ្មានការជ្រើសរើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកមេធាវីដោយមិនយកកម្រៃឲ្យអនីតិជននោះឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន បន្ទាប់ពីអនីតិជននោះត្រូវបាននាំមកដល់អង្គភាពនគរបាលយុត្តិធម៌ ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវមានបញ្ជីឈ្មោះមេធាវីសម្រាប់ឲ្យអនីតិជនធ្វើការជ្រើសរើស ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកអ្នកបកប្រែភាសាដោយមិនយកកម្រៃឲ្យអនីតិជន ក្នុងករណីដែលអនីតិជននោះពុំមានអ្នកបកប្រែភាសាផ្ទាល់ខ្លួន ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុដោយឡែកអំពីការជូនដំណឹង ឬការព្យាយាមជូនដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវីរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ច និងស្វែងរកមេធាវីនិងអ្នកទំនុកបម្រុង ទោះបីជាការជូនដំណឹង ឬការព្យាយាមជូនដំណឹងនោះមិនបានទទួលលទ្ធផលក្តី។

## មាត្រា ១៩.- ការពិនិត្យសុខភាពផ្លូវកាយ ឬសុខភាពផ្លូវចិត្ត

ក្នុងករណីអនីតិជនមានរបួស ឬមានបញ្ហាសុខភាពហើយត្រូវការការព្យាបាល នគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជនទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលនៅជិតបំផុត ដើម្បីធ្វើការពិនិត្យព្យាបាល ។ រាល់ការចំណាយលើការពិនិត្យនិងព្យាបាលជាបន្ទុករបស់រដ្ឋ ក្នុងករណីដែលឪពុកម្តាយ ឬអ្នកថែរក្សាព្យាបាលគ្មានលទ្ធភាព ។

LE ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

កំណត់ហេតុ ឬរបាយការណ៍ពាក់ព័ន្ធនឹងសុខភាព ត្រូវបញ្ចូលទៅក្នុងសំណុំរឿង ។

## មាត្រា ២០.- កំណត់ហេតុនៃការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជន

ច្បាប់ចម្លងនៃកំណត់ហេតុស្តីពីការចាប់ខ្លួននិងកំណត់ហេតុសរុបនៃការឃាត់ខ្លួនអនីតិជនត្រូវផ្តល់ឲ្យមេធាវីតាមការស្នើសុំ ។

នៅតាមអង្គភាពដែលមាននគរបាលយុត្តិធម៌នីមួយៗ ត្រូវមានបញ្ជីដោយឡែកស្តីពីការឃាត់ខ្លួនអនីតិជន ។

## មាត្រា ២១.- នីតិវិធីមុនការស្តាប់ចម្លើយ

អនីតិជនត្រូវទទួលបានឱកាសសន្ទនា ឬទំនាក់ទំនងជាមួយអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ច និងមេធាវីជាលក្ខណៈឯកជននិងជាសម្ងាត់ ប្រសិនបើមានការស្នើសុំ លើកលែងតែជនទាំងនេះមានការទាក់ទិនក្នុងរឿងជាមួយ ។ ការជួបសន្ទនាឬទាក់ទងគ្នាមានរយៈពេល ៣០ (សាមសិប) នាទី និងត្រូវធ្វើមុនពេលស្តាប់ចម្លើយ ប្រសិនបើអាចធ្វើទៅបាន ។

## មាត្រា ២២.- ការស្តាប់ចម្លើយ

មុនពេលផ្តើមស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ដល់អនីតិជនអំពីសិទ្ធិជាមូលដ្ឋានជាពិសេស គឺសិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី ។

ការស្តាប់ចម្លើយត្រូវប្រព្រឹត្តដោយមានវត្តមានរបស់មេធាវី ដោយប្រើប្រាស់នីតិវិធីកុមារមេត្រីមានលក្ខណៈជាឯកជននិងជាការសម្ងាត់ ។

អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ចដែលមានសិទ្ធិ ហើយអាចផ្តល់ជំនួយដល់អនីតិជន មានសិទ្ធិចូលរួមក្នុងការស្តាប់ចម្លើយអនីតិជនបាន ។

មន្ត្រីនគរបាលយុត្តិធម៌អាចមិនអនុញ្ញាតឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្តាប់ចម្លើយ ប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ។ ការមិនអនុញ្ញាតនេះ ត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន ។ ប្រសិនបើអ្នកតំណាងដែលច្បាប់បានកំណត់មិនអាចចូលរួមបាន ត្រូវអនុញ្ញាតឲ្យអ្នកទំនុកបម្រុងអនីតិជនចូលរួមជំនួស ប្រសិនបើមាន ។

ក្នុងករណីអវត្តមានអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬមេធាវីរបស់អនីតិជន ឬភ្នាក់ងារសង្គមកិច្ចក្នុងពេលស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុដោយបញ្ជាក់ពីមូលហេតុនៃអវត្តមាននោះ ហើយបញ្ចូលក្នុងសំណុំរឿងរបស់អនីតិជន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន ។ ក្នុងករណីអនីតិជនមិនអាចអានបាន មន្ត្រីនគរបាលយុត្តិធម៌ ឬអ្នកបកប្រែត្រូវអានកំណត់ហេតុស្តាប់ចម្លើយឲ្យអនីតិជនស្តាប់ ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុញ្ញាតឲ្យមេធាវី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចអានកំណត់ហេតុស្តាប់ចម្លើយ ។

អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុនោះ ដោយត្រូវចុះនិទ្ទេស ។

អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចដែលមានវត្តមានត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ ។ ក្នុងករណីអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស នៅក្នុងកំណត់ហេតុនោះ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេ នឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

## មាត្រា ២៣.- ការប្រព្រឹត្តមកលើអនីតិជនដែលត្រូវបានឃាត់ខ្លួន

មន្ត្រីនគរបាលយុត្តិធម៌មិនត្រូវយកអនីតិជនដាក់បង្ហាញមុខជាដូរឡើយ ក្នុងករណីគ្មានការយល់ព្រមជាមុនពីអនីតិជន ដោយមានការពិគ្រោះយោបល់ជាមួយមេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ។ ក្នុងករណីអនីតិជនយល់ព្រម ត្រូវមានកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងផ្តិតម្រាមដៃ ។

អនីតិជនដែលត្រូវឃាត់ខ្លួន ត្រូវដាក់ដាច់ដោយឡែកពីនីតិជន និងទៅតាមភេទ ។

អនីតិជនមិនត្រូវបានទទួលរងទារុណកម្ម ការបង្ខិតបង្ខំ ការគំរាមកំហែង ការសម្លុតបំភិតបំភ័យ ឬទង្វើណាមួយផ្សេងទៀតដែលនាំឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អនីតិជន ឬទទួលរងអំពើអមនុស្សធម៌ណាមួយឡើយ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

# ជំពូកទី ៦
# ការចោទប្រកាន់

## មាត្រា ២៤.- សមត្ថកិច្ចរបស់អង្គការអយ្យការ

បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមផលប្រយោជន៍ទូទៅដោយអយ្យការ ។ អយ្យការធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងអនីតិជន ។

ការចោទប្រកាន់ករណីទាំងឡាយដែលពាក់ព័ន្ធនឹងអនីតិជន ត្រូវឲ្យតំណាងអយ្យការដែលទទួលបានការចាត់តាំងពិសេសឲ្យកាន់រឿងក្តីអនីតិជន ទោះជាការចាត់តាំងនោះឲ្យធ្វើតែរឿងអនីតិជនដាច់ខាតឬមិនដាច់ខាតក្តី ។ តំណាងអយ្យការដែលនឹងត្រូវចាត់ឲ្យកាន់រឿងក្តីអនីតិជន ត្រូវទទួលបានការបណ្តុះបណ្តាលជំនាញឯកទេសផ្នែកសិទ្ធិកុមារ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទាក់ទងនឹងយុត្តិធម៌អនីតិជន ។

## មាត្រា ២៥.- ការផ្ទៀងផ្ទាត់អាយុរបស់អនីតិជន

ព្រះរាជអាជ្ញាត្រូវពិនិត្យសំណុំឯកសារ និងពាក្យប្តឹងដែលខ្លួនបានទទួល ដើម្បីផ្ទៀងផ្ទាត់អាយុរបស់អនីតិជន ។

ក្នុងករណីមានវិមតិសង្ស័យអំពីអាយុរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋមឲ្យបានឆាប់បំផុត ដើម្បីស្វែងរកឲ្យឃើញអាយុពិតប្រាកដរបស់អនីតិជននោះ ។

ក្នុងករណីការស៊ើបអង្កេតបឋមនោះមិនអាចឈានដល់ការសន្និដ្ឋានអំពីអាយុពិតប្រាកដរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងនេះទៅឲ្យចៅក្រមស៊ើបសួរ ។

## មាត្រា ២៦.- ការស្តាប់ចម្លើយ

ព្រះរាជអាជ្ញាត្រូវប្រាប់អនីតិជន និងអ្នកចូលរួមស្តាប់ចម្លើយអំពីសិទ្ធិដែលមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ ដោយប្រើភាសានិងអាកប្បកិរិយាសមស្របទៅនឹងកម្រិតនៃការយល់ដឹងរបស់អនីតិជនមុនពេលធ្វើការស្តាប់ចម្លើយ ។ ក្នុងករណីដែលគ្មានការជ្រើសរើសព្រះរាជ-អាជ្ញាត្រូវចាត់តាំងមេធាវីដោយមិនយកកម្រៃឲ្យអនីតិជននោះ ។

ការស្តាប់ចម្លើយអនីតិជនត្រូវធ្វើជាសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី ។ ការស្តាប់ចម្លើយនេះត្រូវមានវត្តមានមេធាវី ភ្នាក់ងារសង្គមកិច្ច អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ។ ព្រះរាជអាជ្ញាអាចមិនអនុញ្ញាតឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្តាប់ចម្លើយបាន ប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ។ ការមិនអនុញ្ញាតនេះត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន ។

ក្នុងករណីអវត្តមានជនណាមួយខាងលើ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្ដាប់ចម្លើយ ដោយបញ្ជាក់អំពីមូលហេតុ ។

បន្ទាប់ពីបញ្ចប់ការស្ដាប់ចម្លើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្ដាប់ចម្លើយបាន ។ ក្នុងករណីអនីតិជនមិនអាចអានកំណត់ហេតុស្ដាប់ចម្លើយបាន ក្រឡាបញ្ជី ឬអ្នកបកប្រែត្រូវអានកំណត់ហេតុស្ដាប់ចម្លើយឲ្យអនីតិជនស្ដាប់ ។ អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្ដាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្ដិតស្រាមមេដៃ ។

ព្រះរាជអាជ្ញាត្រូវអនុញ្ញាតឲ្យមេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ចអានកំណត់ហេតុស្ដាប់ចម្លើយបាន ។

មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ចដែលមានវត្តមាន ត្រូវចុះហត្ថលេខាឬផ្ដិតស្រាមមេដៃលើកំណត់ហេតុ ។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខាឬផ្ដិតស្រាមមេដៃលើកំណត់ហេតុ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្ដាប់ចម្លើយនោះ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

## មាត្រា ២៧.- ការតម្កល់រឿងទុកឥតចាត់ការចំពោះអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ

ក្នុងករណីអនីតិជនមានអាយុក្រោម ១៤(ដប់បួន)ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស នោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជនទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញភ្លាម ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ព្រះរាជអាជ្ញាត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជន ។

ក្រោយពីបានទទួលអនីតិជនពីព្រះរាជអាជ្ញាហើយ ប្រសិនបើមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត យល់ឃើញថាអនីតិជននោះចាំបាច់ត្រូវមានកិច្ចការពារនិងថែទាំ នោះមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បាន

ROYAUME DU CAMBODGE
CABINET DU PALAIS ROYAL

កំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ អាចដាក់ពាក្យប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីបាន ។

## មាត្រា ២៨.- អំណាចរបស់តំណាងអយ្យការក្នុងការបង្វែរ

ករណីអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ប្រព្រឹត្តបទលហុ ឬបទមជ្ឈិម ព្រះរាជអាជ្ញាត្រូវពិចារណាជាបឋមទៅលើការបង្វែរដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ។

ករណីព្រះរាជអាជ្ញាសម្រេចបង្វែរ បទប្បញ្ញត្តិនៃជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវសម្រេចផ្អាកនីតិវិធីចោទប្រកាន់ដោយដីកាសម្រេច ។

ប្រសិនបើការរៀបចំផែនការបង្វែរត្រូវការពេលវេលា ព្រះរាជអាជ្ញាត្រូវផ្អាកនីតិវិធីចោទប្រកាន់ និងបង្គាប់ឱ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រងនិងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ។

ព្រះរាជអាជ្ញាជូនដំណឹងដល់ជនរងគ្រោះឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុងករណីជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជនអំពីការសម្រេចផ្អាកនីតិវិធីចោទប្រកាន់ ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ។

ព្រះរាជអាជ្ញា ត្រូវសម្រេចចេញដីកាតម្កល់រឿងទុកឥតចាត់ការក្នុងករណីដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យ ដោយផ្អែកលើលទ្ធផលនៃរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ ។

ក្នុងករណីអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ព្រះរាជអាជ្ញាអាចចេញដីកាសម្រេចបង្វែរជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំឱ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី ។

## មាត្រា ២៩.- ការឱ្យដំណឹងអំពីការចោទប្រកាន់

ក្នុងករណីណាក៏ដោយ ការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងភ្លាមដោយផ្ទាល់និងជាលាយលក្ខណ៍អក្សរទៅអនីតិជន ហើយប្រសិនបើសមស្រប ត្រូវឱ្យដំណឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ឬអ្នកទំនុកបម្រុងនិងមេធាវីរបស់អនីតិជន ដើម្បីរៀបចំមធ្យោបាយការពារអនីតិជន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ៣០.- ការបំបែកសំណុំរឿង**

ប្រសិនបើព្រះរាជអាជ្ញាពិនិត្យសំណុំរឿងឃើញថា អំពើប្រព្រឹត្តនោះមានសហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតជាអនីតិជនផង និងជានីតិជនផង ព្រះរាជអាជ្ញាអាចសម្រេចចេញដីកាបំបែកសំណុំរឿងរវាងអនីតិជន និងនីតិជនឲ្យដាច់ដោយឡែកពីគ្នា ។

## ជំពូកទី ៧
## ការស៊ើបសួរ

**មាត្រា ៣១.- សមត្ថកិច្ចនៃការស៊ើបសួរ**

ការស៊ើបសួរករណីទាំងឡាយដែលពាក់ព័ន្ធនឹងអនីតិជន ជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរដែលមានជំនាញទាក់ទងនឹងអនីតិជន ។

**មាត្រា ៣២.- ការបើកការស៊ើបសួរ**

បន្ទាប់ពីបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ ចៅក្រមស៊ើបសួរត្រូវបើកការស៊ើបសួរភ្លាម ។

ជនត្រូវចោទជាអនីតិជន ត្រូវមានមេធាវីអមជានិច្ចក្នុងអំឡុងពេលស្តាប់ចម្លើយនៅចំពោះមុខចៅក្រមស៊ើបសួរ ។ ក្នុងករណីគ្មានការជ្រើសរើស ចៅក្រមស៊ើបសួរត្រូវចាត់តាំងមេធាវីនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

**មាត្រា ៣៣.- ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ**

នៅពេលអនីតិជនបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណអនីតិជន ហើយប្រាប់អនីតិជនឲ្យបានដឹងអំពីរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើស ដែលបានកំណត់ដោយច្បាប់ ព្រមទាំងប្រាប់អំពីសិទ្ធិទាក់ទងនឹងដំណាក់កាលស៊ើបសួរដូចមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ចអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## មាត្រា ៣៤.- ការផ្តល់អាទិភាពចំពោះរឿងក្តីអនីតិជន

ចៅក្រមស៊ើបសួរត្រូវលើកយករឿងក្តីរបស់អនីតិជនមកចាត់ការជាអាទិភាព ពិសេសរឿងក្តីដែលអនីតិជនកំពុងជាប់ឃុំបណ្តោះអាសន្ន ។

## មាត្រា ៣៥.- ការស្តាប់ចម្លើយអនីតិជន

ការស្តាប់ចម្លើយត្រូវធ្វើជាការសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី ។ ការស្តាប់ចម្លើយនេះត្រូវមានវត្តមានមេធាវីការពារ អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ច ។

ចៅក្រមស៊ើបសួរអាចមិនអនុញ្ញាតឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្តាប់ចម្លើយបាន ប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ។ ការមិនអនុញ្ញាតនេះត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន ។

ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ដោយបញ្ជាក់អំពីមូលហេតុក្នុងករណីអវត្តមានអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ច ។

បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន ។ ក្នុងករណីអនីតិជនមិនអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ក្រឡាបញ្ជីត្រូវអានកំណត់ហេតុស្តាប់ចម្លើយឲ្យអនីតិជនស្តាប់ ។ អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតស្នាមមេដៃ ។

ចៅក្រមស៊ើបសួរត្រូវអនុញ្ញាតឲ្យមេធាវី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ប្រសិនបើមានការស្នើសុំ ។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមិនព្រមចុះហត្ថលេខា ឬផ្តិតស្នាមមេដៃលើកំណត់ហេតុ ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយនោះ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

## មាត្រា ៣៦.- ការលើកពេលស្តាប់ចម្លើយ

ក្នុងករណីអវត្តមានមេធាវី ចៅក្រមស៊ើបសួរត្រូវលើកពេលស្តាប់ចម្លើយ និងត្រូវកោះហៅមេធាវីដើម្បីចូលរួមក្នុងការស្តាប់ចម្លើយ លើកលែងតែក្នុងករណីបន្ទាន់ដែលបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបាត់បង់តម្រុយនៃភស្តុតាង ។ ប្រភេទនៃការបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

វត្តមាន ឬអវត្តមានរបស់មេធាវី មិនរារាំងចៅក្រមស៊ើបសួរក្នុងការសម្រេចអំពីការមិនឃុំខ្លួន ឬឃុំខ្លួនបណ្តោះអាសន្នឡើយ ។

## មាត្រា ៣៧.- ការព្យួរការសិក្សា និងការងារសម្រាប់អនីតិជន

ចៅក្រមស៊ើបសួរអាចបង្គាប់ទៅគ្រឹះស្ថានសិក្សា ឬនិយោជក មិនឲ្យព្យួរការសិក្សា ឬព្យួរការងាររបស់អនីតិជន ប្រសិនបើអនីតិជនមិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នទេ ។

ក្នុងករណីអនីតិជនត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ឬត្រូវអនុវត្តផែនការបង្វែរ គ្រឹះស្ថាន ឬនិយោជកអាចព្យួរការសិក្សា ឬព្យួរការងាររហូតដល់មានសេចក្តីសម្រេចរបស់តុលាការជាស្ថាពរ ។ ក្នុងករណីតុលាការសម្រេចសេចក្តីថាគ្មានទោសទេ នោះគ្រឹះស្ថានសិក្សា ឬនិយោជកត្រូវអនុញ្ញាតឲ្យអនីតិជនចូលសិក្សា ឬធ្វើការជាធម្មតាឡើងវិញ ។

## មាត្រា ៣៨.- អំណាចរបស់ចៅក្រមស៊ើបសួរក្នុងការបង្វែរ

ចៅក្រមស៊ើបសួរត្រូវពិចារណាជាបឋមទៅលើការបង្វែរ ដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ចំពោះអនីតិជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទមជ្ឈិម ។ បទមជ្ឈិមដែលមានស្ថានទម្ងន់ទោស អាចត្រូវបានយកមកពិចារណាអំពីការបង្វែរផងដែរ ។ ករណីចៅក្រមស៊ើបសួរសម្រេចបង្វែរ បទប្បញ្ញត្តិក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវផ្អាកនីតិវិធីនៃការស៊ើបសួរដោយដីកាសម្រេច និងបង្គាប់ឲ្យដោះលែងអនីតិជនដែលត្រូវបានឃុំខ្លួន ប្រសិនបើអនីតិជននោះត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ។ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រងនិងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ទោះបីផែនការបង្វែរត្រូវការពេលវេលារៀបចំក៏ដោយ ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុងករណីជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជន អំពីការសម្រេចផ្អាកនីតិវិធីនៃការស៊ើបសួរ ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ។

ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ ក្នុងករណីដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យ ដោយផ្អែកលើលទ្ធផលរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ ។

ក្នុងករណីដែលអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចបង្វែរជាថ្មីដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរ ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី ។

## មាត្រា ៣៩.- ការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនអនីតិជនបណ្តោះអាសន្ន ជាវិធានការចុងក្រោយ ។

បន្ថែមលើបទប្បញ្ញត្តិស្ដីពីលក្ខខណ្ឌ មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរមុននឹងសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវពិចារណាលើរបាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនផងដែរ ប្រសិនបើមាន ។

អនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវបានឃុំខ្លួនបណ្ដោះអាសន្នឡើយ ។ ក្នុងករណីអនីតិជនដែលកំពុងជាប់ឃុំត្រូវបានរកឃើញថាមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ និងបង្គាប់ឲ្យដោះលែងអនីតិជននោះជាបន្ទាន់ ទោះបីមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ អាចដាក់ពាក្យប្ដឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីបាន ។

## មាត្រា ៤០.- ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចដាក់អនីតិជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលាជំនួសឲ្យការឃុំខ្លួនបណ្ដោះអាសន្ន ប្រសិនបើអនីតិជនត្រូវចោទនោះ ត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ ។ បន្ថែមលើបទប្បញ្ញត្តិស្ដីពីការត្រួតពិនិត្យតាមផ្លូវតុលាការនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចបង្គាប់អនីតិជនដែលនៅក្រៅឃុំឲ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ ៖

- ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុកម្ដាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬក្រុមគ្រួសារណាមួយសមស្រប

- ឲ្យស្ថិតនៅក្រោមការគ្រប់គ្រង និងការថែទាំនៅក្នុងមណ្ឌលណាមួយរបស់រដ្ឋ ឬមណ្ឌលណាមួយរបស់អង្គការមិនមែនរដ្ឋាភិបាលដែលមាននីតិសម្បទាទទួល និងថែទាំអនីតិជន
- បង្គាប់មិនឲ្យអនីតិជនចេញដើរហួសម៉ោងកំណត់ ឬសេពគ្រឿងស្រវឹង
- វិធានការផ្សេងទៀតដែលតុលាការយល់ឃើញថាសមស្រប ។

## មាត្រា ៤១.- ការដោះលែងឲ្យនៅក្រៅឃុំ

ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ដោយគំនិតផ្តួចផ្តើមរបស់ខ្លួន ។ ចៅក្រមស៊ើបសួរដែលមានបំណងដោះលែងអនីតិជនឲ្យនៅក្រៅឃុំ ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលខ្លីបំផុត ។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងអនីតិជនភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា ឬទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ។ ចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះ នៅក្នុងដីកាសម្រេចរបស់ខ្លួន ។

ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ព្រះរាជអាជ្ញា អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុងអនីតិជនអាចសុំឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ។ មេធាវីអាចសុំដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានដោយមានការយល់ព្រមពីអនីតិជន ។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ គិតពីថ្ងៃទទួលបានពាក្យសុំ ។

## មាត្រា ៤២.- ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ

មុននឹងចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរត្រូវពិនិត្យ និងពិចារណាលើរបាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។ ក្នុងករណីរបាយការណ៍

ស្ដីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចផ្ដល់របាយការណ៍បន្ថែមក្នុងរយៈពេលឆាប់បំផុតដែលអាចធ្វើទៅបាន ដោយមិនឲ្យលើសរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ។

ដីកាដំណោះស្រាយលើកលែងចោទប្រកាន់មានអានុភាពនាំឲ្យដោះលែងអនីតិជនដែលជាប់ឃុំ ទោះបីមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ។

ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

### មាត្រា ៤៣.- ការប្ដឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍

មុននឹងសម្រេចប្ដឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ចំពោះដីកាលើកលែងចោទប្រកាន់ ដីកាសម្រេចឃុំខ្លួន ដីកាសម្រេចមិនឃុំខ្លួន ដីកាដោះលែងឲ្យនៅក្រៅឃុំ និងដីកាបង្វែររបស់ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញាត្រូវពិចារណាជាចម្បងអំពីឧត្ដមប្រយោជន៍របស់អនីតិជន ។

## ជំពូកទី ៨
## សមត្ថកិច្ចរបស់សាលាដំបូង

### មាត្រា ៤៤.- សមត្ថកិច្ចនៃការជំនុំជម្រះ

សាលាដំបូងដែលមានសមត្ថកិច្ចជំនាញទាក់ទងនឹងអនីតិជន ជំនុំជម្រះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុដែលមានជនជាប់ចោទជាអនីតិជន ។

សាលាដំបូងសម្រេចជាក្រុមសមូហភាពដោយមានចៅក្រម ៣ (បី) រូប ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុដែលជាប់ទាក់ទងនឹងបទឧក្រិដ្ឋ និងបទមជ្ឈិម ។

សាលាដំបូងសម្រេចជាចៅក្រមទោលចំពោះបទលហុ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL



៤៦០

## មាត្រា ៤៥.- អាទិភាពលើរឿងក្តីអនីតិជន

តុលាការត្រូវលើកយករឿងក្តីរបស់អនីតិជនមកចាត់ការជាអាទិភាព ជាពិសេសរឿងក្តីអនីតិជនដែលជាប់ឃុំខ្លួនបណ្តោះអាសន្ន ។

ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលរង់ចាំការជំនុំជម្រះ តុលាការត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាព ។ ករណីដែលរឿងក្តីត្រូវបានលើកពេលជំនុំជម្រះ តុលាការត្រូវពិចារណាផងដែរអំពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាព ។

## មាត្រា ៤៦.- នីតិវិធីមុនពេលសវនាការ

មុនពេលសវនាការ តុលាការត្រូវពិនិត្យរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ដែលផ្តល់ដោយភ្នាក់ងារសង្គមកិច្ច ។

ក្នុងករណីដែលរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់បានរៀបចំ ហើយតុលាការត្រូវការព័ត៌មានបន្ថែម តុលាការត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំ និងបំពេញបន្ថែមនូវរបាយការណ៍ និងយោបល់នោះ តាមតម្រូវការ ។

## មាត្រា ៤៧.- សវនាការជាអសាធារណៈ

ការពិភាក្សាដេញដោល និងការប្រកាសសាលក្រមរឿងក្តីអនីតិជន ត្រូវធ្វើឡើងក្នុងសវនាការជាអសាធារណៈ ។

មានតែបុគ្គលដែលមានសិទ្ធិ ភាតព្វកិច្ច ឬផលប្រយោជន៍ដែលពាក់ព័ន្ធនឹងរឿងក្តីប៉ុណ្ណោះដែលមានសិទ្ធិចូលរួមក្នុងសវនាការ ។

អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជនត្រូវចូលរួមក្នុងសវនាការ លើកលែងតែមានសំណូមពរពីអនីតិជនផ្ទុយពីនេះ ឬតុលាការយល់ឃើញថាការចូលរួមរបស់បុគ្គលទាំងនោះមិនបម្រើឧត្តមប្រយោជន៍របស់អនីតិជន ។

## មាត្រា ៤៨.- សវនាការ

នៅពេលសវនាការ តុលាការត្រូវប្រើប្រាស់នីតិវិធីកុមារមេត្រី ។

ក្នុងកាលៈទេសៈពិសេស មេធាវីរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញា អាចស្នើសុំឲ្យតុលាការប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធីសមស្របណាមួយក្នុងការស្តាប់ចម្លើយ ។

ROYAUME DU CAMBODGE · LE SECRETARIAT DU PALAIS ROYAL

## មាត្រា ៤៩.– ការឲ្យរួចផុតពីបទចោទ

ក្នុងករណីតុលាការរកឃើញថា អនីតិជនជាប់ចោទមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចឲ្យអនីតិជនរួចផុតពីបទចោទប្រកាន់ ហើយបង្គាប់ឲ្យដោះលែងអនីតិជនដែលជាប់ឃុំជាបន្ទាន់ ទោះបីមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះឲ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីតុលាការរកឃើញថាអនីតិជនខាងលើពិតជាបានប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចអំពីសំណងរដ្ឋប្បវេណី ប្រសិនបើមានបណ្តឹងរដ្ឋប្បវេណី ។

ប្រសិនបើតុលាការរកឃើញថា អំពើដែលចោទប្រកាន់មកលើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ មិនមែនជាបទល្មើស ឬអនីតិជនជាប់ចោទគ្មានកំហុសទេ តុលាការត្រូវសម្រេចឲ្យរួចខ្លួនពីបទចោទ និងបង្គាប់ឲ្យដោះលែងអនីតិជននោះភ្លាម ទោះបីមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះឲ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់ ប្រសិនបើអនីតិជននោះមិនត្រូវបានជាប់ឃុំពីបទល្មើសផ្សេងទៀតទេ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ តុលាការត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំ នោះមន្ទីរឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

## មាត្រា ៥០.– ជំនួយរបស់មេធាវី

ជំនួយរបស់មេធាវីត្រូវតែមានជាចាំបាច់នៅក្នុងសវនាការ ។ បើគ្មានការជ្រើសរើសដោយអនីតិជន មេធាវីត្រូវបានចាត់តាំងដោយមិនយកកម្រៃតាមគំនិតផ្តួចផ្តើមរបស់ប្រធានតុលាការ នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។ សោហ៊ុយសម្រាប់ធ្វើការ ចម្លងសំណុំរឿងជាបន្ទុករបស់រដ្ឋ ។

តុលាការត្រូវផ្តល់ពេលវេលាសមស្រប និងលិខិតចម្លងសំណុំរឿង ទៅឲ្យមេធាវីសម្រាប់រៀបចំការពារក្តី ។ សោហ៊ុយសម្រាប់ធ្វើការចម្លងសំណុំរឿងជាបន្ទុករបស់មេធាវីដែលត្រូវបានជ្រើសរើសដោយអនីតិជន ។

## មាត្រា ៥១.- ការផ្តល់ព័ត៌មានអំពីសិទ្ធិដល់អនីតិជន

នៅពេលចាប់ផ្តើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនអាចយល់បាន អំពីសិទ្ធិដូចខាងក្រោម ៖

- សិទ្ធិដែលទាក់ទងនឹងដំណាក់កាលនៃការជំនុំជម្រះដូចមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ
- សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះក្តី
- សិទ្ធិទទួលបានការការពារពីតុលាការនូវទង្វើមិនគប្បី ឬការសួរដេញដោលមិនសមរម្យ
- សិទ្ធិប្តឹងជំទាស់ចិត្តចៅក្រមជំនុំជម្រះ
- សិទ្ធិធ្វើសំណូមពរចុងក្រោយ និង
- សិទ្ធិប្តឹងឧទ្ធរណ៍ ។

## មាត្រា ៥២.- អំណាចរបស់តុលាការក្នុងការបង្វែរ

នៅដំណាក់កាលនៃការជំនុំជម្រះលើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ជាប់ចោទពីបទលហុ បទមជ្ឈិម តុលាការត្រូវពិចារណាជាបឋម ទៅលើការបង្វែរដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ។ បទមជ្ឈិមដែលមានស្ថានទម្ងន់ទោស អាចត្រូវបានយកមកពិចារណាអំពីការបង្វែរផងដែរ ។

ក្នុងករណីលក្ខខណ្ឌអប្បបរមាត្រូវបានបំពេញ តុលាការត្រូវចេញសាលក្រមបង្អង់រឿងទុកសិនបន្ទាប់មកត្រូវ ៖

- ពិគ្រោះយោបល់ជាមួយអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុងមេធាវី ភ្នាក់ងារសង្គមកិច្ច ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកពាក់ព័ន្ធផ្សេងទៀត
- រៀបចំផែនការបង្វែរ
- ឲ្យអនីតិជនចុះហត្ថលេខា ឬផ្តិតម្រាមដៃអនុវត្តផែនការបង្វែរ ។

ក្នុងករណីតុលាការសម្រេចបង្វែរ បទប្បញ្ញត្តិក្នុងជំពូកទី ១០(ការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត ។ តុលាការអាចចេញសាលក្រមសម្រេចអំពីសំណងរដ្ឋប្បវេណី ក្នុងករណីមានការប្តឹងសុំ ។

ប្រសិនបើអនីតិជនកំពុងជាប់ឃុំ តុលាការត្រូវបង្គាប់ឲ្យដោះលែងអនីតិជននោះភ្លាម ទោះបីមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ តុលាការត្រូវបញ្ជូនអនីតិជននោះ ទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជនឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីអនីតិជនអនុវត្តបានជោគជ័យនូវផែនការបង្វែរ ដោយមានរបាយការណ៍បញ្ជាក់រួមគ្នារបស់ភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ តុលាការត្រូវចេញសាលក្រមសម្រេចឲ្យអនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌ ។

ក្នុងករណីការអនុវត្តផែនការបង្វែរទទួលបរាជ័យ តុលាការអាចចេញដីកាសម្រេចបង្វែរជាថ្មីដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរ ទស្សនៈរបស់អនីតិជនអ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី ។

## មាត្រា ៥៣.- ចម្លើយសារភាពនៅពេលសវនាការ

តុលាការត្រូវពិនិត្យ ថ្លឹងថ្លែង និងបញ្ជាក់ថាចម្លើយសារភាពទទួលយកពិរុទ្ធភាពរបស់អនីតិជននៅពេលសវនាការ ត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត គ្មានការគំរាមកំហែង ឬបង្ខិតបង្ខំ និងយល់បានអំពីផលវិបាកនៃការសារភាពនេះ ។ ចម្លើយសារភាពដែលបានមកពីការគំរាមកំហែងការបង្ខិតបង្ខំ ឬការមិនយល់ដឹងអំពីផលវិបាកនៃការសារភាពមិនត្រូវចាត់ទុកជាភស្តុតាង នៃពិរុទ្ធភាពឡើយ ។

ការសារភាពទទួលយកផែនការបង្វែរមិនត្រូវចាត់ទុកជាភស្តុតាងសម្រាប់ពិរុទ្ធភាពក្នុងបទល្មើសដដែល សម្រាប់នីតិវិធីព្រហ្មទណ្ឌបន្តបន្ទាប់នោះឡើយ ។

ក្នុងពេលសវនាការតុលាការត្រូវផ្ទៀងផ្ទាត់ពីភាពស៊ីចង្វាក់នៃចម្លើយសារភាព និងភស្តុតាងផ្សេងទៀតនៃបទល្មើស ។

## មាត្រា ៥៤.- ការប្រកាសសាលក្រម

សាលក្រមត្រូវប្រកាសនៅពេលសវនាការ ក្រោយពីធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ ។

ជាគោលការណ៍ សាលក្រមត្រូវប្រកាសជាអសាធារណៈនៅចំពោះមុខអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍នៅ

សាលក្រមអាចប្រកាសកំបាំងមុខអនីតិជនបាន ក្នុងករណីដែលការប្រកាសសាលក្រមចំពោះមុខធ្វើឲ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជននោះ។

## ជំពូកទី ៩
## សមត្ថកិច្ចរបស់តុលាការជាន់ខ្ពស់

### មាត្រា ៥៥.- សមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះ

ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ និងតុលាការកំពូលត្រូវមានសមាសភាពជាចៅក្រមជំនាញទាក់ទងនឹងអនីតិជនយ៉ាងតិច ១ (មួយ) រូប ។

### មាត្រា ៥៦.- ការបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍ និងតុលាការកំពូល

ក្នុងករណីមានបណ្ដឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃសាលាដំបូងត្រូវរៀបចំសំណុំរឿងដើម្បីបញ្ជូនទៅសាលាឧទ្ធរណ៍ ក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ គិតពីថ្ងៃប្ដឹងឧទ្ធរណ៍ លើកលែងតែមានកាលៈទេសៈមិនអាចជម្នះបានដែលត្រូវតែមានបញ្ជាក់នៅក្នុងលិខិតបញ្ជូន ។

ក្នុងករណីមានបណ្ដឹងសាទុក្ខ ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ត្រូវរៀបចំសំណុំរឿងដើម្បីបញ្ជូនទៅតុលាការកំពូល ក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ គិតពីថ្ងៃប្ដឹងសាទុក្ខ លើកលែងតែមានកាលៈទេសៈមិនអាចជម្នះបានដែលត្រូវតែមានបញ្ជាក់នៅក្នុងលិខិតបញ្ជូន ។

### មាត្រា ៥៧.- អាទិភាពនៃរឿងក្ដីអនីតិជន

សាលាឧទ្ធរណ៍ និងតុលាការកំពូល ត្រូវលើកយករឿងក្ដីរបស់អនីតិជនមកចាត់ការ ជំនុំជម្រះជាអាទិភាព ពិសេសរឿងក្ដីអនីតិជនដែលជាប់ឃុំ ។ ចំពោះរឿងក្ដីដែលអនីតិជនជាប់ឃុំ ត្រូវលើកយកមកជំនុំជម្រះក្នុងអំឡុងពេល ៣ (បី) ខែ យ៉ាងយូរគិតពីថ្ងៃទទួលសំណុំរឿង លើកលែងតែមានមូលហេតុសត្យានុម័តដែលមិនអាចជម្នះបាន ។

ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលរង់ចាំការជំនុំជម្រះ សាលាឧទ្ធរណ៍ឬតុលាការកំពូលត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្ដោះអាសន្នឲ្យមានសេរីភាព ។ ក្នុងករណីរឿងក្ដីត្រូវបានលើកពេលជំនុំជម្រះ សាលាឧទ្ធរណ៍ ឬតុលាការកំពូលត្រូវពិចារណាផងដែរអំពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្ដោះអាសន្នឲ្យមានសេរីភាព ។

### មាត្រា ៥៨.- អំណាចរបស់សាលាឧទ្ធរណ៍ក្នុងការបង្វែរ

បទប្បញ្ញត្តិនៃមាត្រា ៥២ (អំណាចរបស់តុលាការក្នុងការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្តចំពោះអំណាចក្នុងការបង្វែររបស់សាលាឧទ្ធរណ៍ ។

ROYAUME DU CAMBODGE
LE MINISTRE du PALAIS ROYAL

### មាត្រា ៥៩.- ការពន្លាតវិធានដល់តុលាការជាន់ខ្ពស់

វិធានដែលត្រូវអនុវត្តចំពោះសាលាដំបូង ត្រូវយកមកអនុវត្តចំពោះសាលាឧទ្ធរណ៍ និងតុលាការកំពូល លើកលែងតែវិធាននោះមានភាពផ្ទុយពីលក្ខណៈនៃវិធានដែលអនុវត្តនៅតុលាការជាន់ខ្ពស់ ។

## ជំពូកទី ១០
## ការបង្វែរ

### មាត្រា ៦០.- ការបង្វែរ

ការបង្វែរជាវិធានដែលអាចប្រើប្រាស់ក្នុងករណីអនីតិជនបានសារភាពថា បានប្រព្រឹត្តបទល្មើស ហើយដែលអាចជឿជាក់បានថាបានប្រព្រឹត្តបទល្មើសមែន ចេញពីដំណាក់កាលនីមួយៗ នៃនីតិវិធីតុលាការ ។

### មាត្រា ៦១.- អាជ្ញាធរទទួលបន្ទុកបង្វែរ

អាជ្ញាធរទទួលបន្ទុកបង្វែររួមមាន តំណាងអង្គការអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះនៃសាលាដំបូង និងក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ ។

### មាត្រា ៦២.- គោលបំណងនៃការបង្វែរ

ការបង្វែរអនីតិជនមានគោលបំណងដូចខាងក្រោម៖

- លើកទឹកចិត្តអនីតិជនឲ្យទទួលស្គាល់កំហុស និងការខូចខាតដែលខ្លួនបានបង្កឡើង
- ជំរុញឲ្យមានការសះជារវាងជនរងគ្រោះជាមួយនឹងអនីតិជន
- លើកទឹកចិត្តឲ្យមានការជួសជុលការខូចខាត ឬសំណងជំងឺចិត្តដល់ជនរងគ្រោះ
- អប់រំ និងកែប្រែអាកប្បកិរិយារបស់អនីតិជន
- ឆ្លើយតបនឹងសេចក្តីត្រូវការផ្ទាល់របស់អនីតិជន ដើម្បីធ្វើសមាហរណកម្មទៅក្នុងគ្រួសារ ឬសហគមន៍ ឬសង្គមវិញ
- ចៀសវាងការមានស្លាកស្នាមអាក្រក់ក្នុងអារម្មណ៍ និងបញ្ចៀសការទទួលបាននូវបទពិសោធអាក្រក់នៃការប្រព្រឹត្តបទល្មើសពីជនដទៃក្នុងពេលអនុវត្តទោស និងចៀសវាងការប្រព្រឹត្តបទល្មើសសាជាថ្មី
- បង្ការការរើសអើងលើអនីតិជន និងចៀសវាងមានប្រវត្តិថាជាប់ទោសក្នុងបញ្ជីថ្កោលទោស ។

## មាត្រា ៦៣.- លក្ខខណ្ឌអប្បបរមានៃការបង្វែរ

ការបង្វែរត្រូវមានលក្ខខណ្ឌអប្បបរមាដូចខាងក្រោម ៖

ក- មានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ ឬបង្ហាញអំពីពិរុទ្ធភាពរបស់អនីតិជន ។

ខ- អនីតិជនសារភាពទទួលកំហុសដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ និងមានការសុំទោសជនរងគ្រោះ ។

គ- បទល្មើសដែលបានប្រព្រឹត្តជាបទលហុ ឬបទមជ្ឈិម ។

ឃ- អនីតិជនយល់ព្រមឲ្យធ្វើការបង្វែរ បន្ទាប់ពីបានទទួលការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬមេធាវីអំពីសិទ្ធិរបស់អនីតិជន និងពិចារណាផងដែរអំពីអានុភាព និងផលប៉ះពាល់នៅពេលអនុវត្តវិធានបង្វែរ ។

## មាត្រា ៦៤.- លក្ខណៈវិនិច្ឆ័យសម្រាប់បង្វែរ

ក្នុងករណីរឿងក្ដីបំពេញទៅតាមលក្ខខណ្ឌអប្បបរមានៃការបង្វែរ ដូចមានចែងនៅក្នុងមាត្រា ៦៣ (លក្ខខណ្ឌអប្បបរមានៃការបង្វែរ) នៃច្បាប់នេះ អាជ្ញាធរទទួលបន្ទុកបង្វែរ មុននឹងសម្រេចបង្វែរ ឬមិនបង្វែរ ត្រូវពិចារណាលើកត្តាដូចខាងក្រោម ៖

ក- កាលៈទេសៈនៃបទល្មើស ។

ខ- ស្ថានភាពនៃបទល្មើស ។

គ- បុគ្គលិកលក្ខណៈរបស់អនីតិជនដូចជា អាយុ កម្រិតយល់ដឹង បញ្ញា អត្តចរិត ។

ឃ- ការទទួលរងឥទ្ធិពលពីគ្រួសារ និងបរិយាកាសជុំវិញការរស់នៅរបស់អនីតិជន ។

ង- ព្យសនកម្មរបស់ជនរងគ្រោះ ។

ច- សុវត្ថិភាពរបស់ជនរងគ្រោះ សហគមន៍ និងសង្គម ។

## មាត្រា ៦៥.- វិធានការបង្វែរ

ក្នុងករណីដែលត្រូវបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរអាចសម្រេចជ្រើសរើសយកវិធានមួយ ឬច្រើនដូចខាងក្រោម សម្រាប់ឲ្យអនីតិជនបំពេញជាកាតព្វកិច្ច ៖

- ចំណុចមួយ ឬច្រើនដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌស្ដីពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ
- ទៅសាលារៀនឲ្យបានទៀងទាត់តាមផែនការកំណត់មិនលើសពី ៦ (ប្រាំមួយ) ខែ
- ចំណាយពេលវេលាជាក់លាក់ជាមួយក្រុមគ្រួសារមិនលើសពី ៦ (ប្រាំមួយ) ខែ
- តម្រូវឲ្យចូលរួមក្នុងការអប់រំ បណ្ដុះបណ្ដាលវិជ្ជាជីវៈក្នុងថិរវេលាមិនលើសពី ៦ (ប្រាំមួយ) ខែ

- ធ្វើការងារសហគមន៍ដោយមិនលើសពី ១០០ (មួយរយ) ម៉ោង ។ ការងារសហគមន៍នេះ សម្រាប់តែអនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ឡើងទៅ ហើយមានលក្ខណៈជាការងារបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ
- ចូលរួមក្នុងកម្មវិធីសហគមន៍ ឬមណ្ឌលដែលមានអត្ថប្រយោជន៍ សម្រាប់ជួយអនីតិជនមិនឲ្យប្រព្រឹត្តបទល្មើសសាជាថ្មី
- ឲ្យស្នាក់នៅទីកន្លែងណាមួយដោយកំណត់ពេលវេលាជាក់លាក់
- ជួសជុលសំណងការខូចខាតទៅជនរងគ្រោះ
- វិធានការសមស្របផ្សេងទៀតដែលបំពេញនូវគោលបំណងនៃការបង្វែរ ។

រាល់វិធានការបង្វែរដែលទាក់ទងនឹងការងារ ត្រូវអនុលោមតាមច្បាប់ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិស្តីពីការងារដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ។

## មាត្រា ៦៦.- ការរៀបចំបង្កើតផែនការបង្វែរ

ក្រោយពីបានទទួលដីកាសម្រេចបង្វែរពីអាជ្ញាធរទទួលបន្ទុកបង្វែរ ភ្នាក់ងារសង្គមកិច្ចត្រូវរៀបចំបង្កើតផែនការបង្វែរ ។ ផែនការបង្វែរត្រូវសម្រេចក្នុងអំឡុងពេលមិនលើសពី ១ (មួយ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីដីកាសម្រេចបង្វែរ លើកលែងតែមានស្ថានភាពពិសេសដែលមិនអាចជម្នះបាន ។

ក្នុងការបង្កើតផែនការបង្វែរជាឯកត្តបុគ្គលសម្រាប់អនីតិជនណាមួយ ភ្នាក់ងារសង្គមកិច្ចត្រូវពិចារណាទៅលើកត្តាដូចខាងក្រោម ៖

- ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងជនដទៃទៀតដែលទទួលរងផលប៉ះពាល់នៃអំពើល្មើស អំពីភាពសមស្របនៃផែនការបង្វែរដែលត្រូវបានស្នើឡើង
- សាវតារ វប្បធម៌ សាសនា និងភាសារបស់អនីតិជន
- កម្រិតសិក្សា សមត្ថភាពខាងបញ្ញា កាលៈទេសៈ និងស្ថានភាពគ្រួសាររបស់អនីតិជន
- សមាមាត្ររវាងផែនការដែលបានស្នើ ឬជ្រើសរើសចំពោះស្ថានភាពរបស់អនីតិជន ចរិតនៃបទល្មើស និងផលប្រយោជន៍សង្គម និង
- អាយុ និងតម្រូវការអភិវឌ្ឍរបស់អនីតិជន ។

ផែនការបង្វែរសម្រាប់អនីតិជនត្រូវ ៖

- ផ្តល់នូវអត្ថប្រយោជន៍សម្រាប់អនីតិជន
- ធ្វើឲ្យអនីតិជនយល់ពីផលប៉ះពាល់នៃអាកប្បកិរិយារបស់ខ្លួនចំពោះជនរងគ្រោះនៃបទល្មើស និងជនដទៃទៀត
- កែតម្រូវនូវកំហុសឆ្គងដែលបង្កឡើងដោយអំពើល្មើស ហើយអាចរួមបញ្ចូលទាំងសំណងការខូចខាត

- អនុវត្តនៅទីកន្លែងដែលអនីតិជនអាចអនុវត្តបាន
- ចៀសវាងការធ្វើអាជីវកម្មកេងប្រវ័ញ្ច ឬបណ្តាលឲ្យអន្តរាយ ឬធ្វើឲ្យមានគ្រោះថ្នាក់ដល់សុខភាពផ្លូវចិត្ត ឬផ្លូវកាយរបស់អនីតិជន
- មិនប៉ះពាល់ជាអវិជ្ជមានដល់ការសិក្សារបស់អនីតិជន បើអនីតិជនកំពុងសិក្សា និង
- មិនមានការពាក់ព័ន្ធនឹងការដកហូតសេរីភាព នៅក្នុងទម្រង់នៃការដាក់ទោសណាមួយឡើយ ។

## មាត្រា ៦៧.- និទ្ទេសដែលត្រូវចុះនៅក្នុងផែនការបង្វែរ

ផែនការបង្វែរត្រូវមាននិទ្ទេសដូចខាងក្រោម ៖

- វិធានការបង្វែរណាមួយដូចមានចែងក្នុងមាត្រា ៦៥ (វិធានការបង្វែរ) នៃច្បាប់នេះ និងរយៈពេលនៃការអនុវត្តវិធានការបង្វែរ
- បញ្ជាក់លម្អិតអំពីសេវា និងជំនួយដែលត្រូវផ្តល់ឲ្យអនីតិជន
- បញ្ជាក់ឲ្យច្បាស់ពីបុគ្គល ឬអង្គការដែលផ្តល់សេវា និងជំនួយទាំងនោះ
- បញ្ជាក់ពីការទទួលខុសត្រូវរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់
- បញ្ជាក់ពីគោលបំណងផ្ទាល់ខ្លួនរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់
- បញ្ចូលកម្មវិធីផ្សេងទៀតទាក់ទងនឹងការអប់រំ ការបម្រើការងារ ការកម្សាន្ត និងសុខុមាលភាពរបស់អនីតិជនទៅតាមស្ថានភាពដែលពាក់ព័ន្ធ
- បញ្ជាក់ពីអាជ្ញាធរ ឬជនសមស្របដែលទទួលបន្ទុកអនុវត្តផែនការបង្វែរ ។ អាជ្ញាធរ ឬជនសមស្របទាំងនេះអាចជានគរបាល បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គ្រូបង្រៀន ឬសមាជិកសមស្របណាមួយនៃសហគមន៍
- បញ្ជាក់ពីភ្នាក់ងារសង្គមកិច្ចដែលទទួលបន្ទុកត្រួតពិនិត្យតាមដាន និងអនុវត្តផែនការបង្វែរ
- បញ្ជាក់អំពីការយល់ព្រមរបស់អនីតិជនចំពោះផែនការបង្វែរ ។

ផែនការបង្វែរត្រូវចុះ ៖

- អត្តសញ្ញាណ និងហត្ថលេខារបស់ភ្នាក់ងារសង្គមកិច្ច
- អត្តសញ្ញាណ និងស្នាមម្រាមដៃរបស់អនីតិជន
- អត្តសញ្ញាណ ហត្ថលេខា ឬស្នាមម្រាមដៃរបស់បុគ្គលដែលពាក់ព័ន្ធ ។

ច្បាប់ចម្លងនៃផែនការបង្វែរត្រូវរក្សាទុកជាការសម្ងាត់នៅការិយាល័យរបស់ភ្នាក់ងារសង្គមកិច្ច ។



## មាត្រា ៦៨.- ការសម្រេចអំពីផែនការបង្វែរដោយអាជ្ញាធរទទួលបន្ទុកបង្វែរ

ភ្នាក់ងារសង្គមកិច្ច ត្រូវបញ្ជូនផែនការបង្វែរទៅអាជ្ញាធរទទួលបន្ទុកបង្វែរ ដើម្បីពិនិត្យ និងសម្រេច ។

ករណីអាជ្ញាធរទទួលបន្ទុកបង្វែរយល់ស្របចំពោះផែនការបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវចេញដីកាសម្រេចឲ្យអនុវត្តផែនការបង្វែរ ។

ករណីអាជ្ញាធរទទួលបន្ទុកបង្វែរមិនយល់ស្រប ចំពោះផែនការបង្វែរដែលរៀបចំដោយភ្នាក់ងារសង្គមកិច្ច អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំឡើងវិញនូវផែនការបង្វែរថ្មី ។ ផែនការបង្វែរត្រូវសម្រេចក្នុងអំឡុងពេលមិនលើសពី ១ (មួយ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីដីកាបង្គាប់ លើកលែងតែមានស្ថានភាពពិសេសដែលមិនអាចជម្នះបាន ។

## មាត្រា ៦៩.- ការអនុវត្តផែនការបង្វែរ

ភ្នាក់ងារសង្គមកិច្ច និងបុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវជានាប់ប់រងអនុវត្តសេចក្តីសម្រេច និងផែនការបង្វែររបស់អាជ្ញាធរទទួលបន្ទុកបង្វែរ ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើអនីតិជនដែលត្រូវអនុវត្តផែនការបង្វែរ ។

បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលជោគជ័យ ឬបរាជ័យ ឬឧបសគ្គដែលកើតមាន នៅក្នុងការអនុវត្តផែនការខាងលើទៅភ្នាក់ងារសង្គមកិច្ច ។ ភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនរបាយការណ៍នោះរួមទាំងយោបល់របស់ខ្លួន ទៅអាជ្ញាធរទទួលបន្ទុកបង្វែរ ហើយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ។

## មាត្រា ៧០.- ការកែប្រែវិធានការបង្វែរ

ក្នុងអំឡុងពេលអនុវត្តផែនការបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរអាចកែប្រែវិធានការបង្វែរបានតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ចស្របទៅតាមស្ថានភាពជាក់ស្តែង ដើម្បីជាប្រយោជន៍របស់អនីតិជន ។

អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបានទទួលពាក្យស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ច ។ ក្នុងករណីអាជ្ញាធរទទួលបន្ទុកបង្វែរមិនបានសម្រេចក្នុងថិរវេលានេះ ត្រូវចាត់ទុកថាយល់ស្របតាមការស្នើសុំ ។

ការកែប្រែផែនការបង្វែរ មិនចាត់ទុកថាជាការបរាជ័យក្នុងការអនុវត្តផែនការបង្វែរឡើយ ។

## មាត្រា ៧១.- បរាជ័យក្នុងការអនុវត្តវិធានការបង្វែរ

បរាជ័យក្នុងការអនុវត្តវិធានការបង្វែរ សំដៅដល់ករណីដែលអនីតិជនមិនបានគោរពតាមកាតព្វកិច្ចនៅក្នុងវិធានការបង្វែរ ឬនៅក្នុងវិធានការបង្វែរដែលត្រូវបានកែប្រែ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ភ្នាក់ងារសង្គមកិច្ចត្រូវផ្តល់របាយការណ៍ស្តីពី លទ្ធផលនៃការមិនគោរពកាតព្វកិច្ចដែលបានកំណត់នៅក្នុងវិធានការបង្វែរ ឬនៅក្នុងវិធានការបង្វែរដែលត្រូវបានកែប្រែ រួមទាំងយោបល់ជូនទៅអាជ្ញាធរទទួលបន្ទុកបង្វែរដើម្បីសម្រេច ដោយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ។

ក្រោយពិនិត្យរបាយការណ៍ខាងលើ អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវកោះហៅអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ច បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ និងមេធាវីរបស់អនីតិជន ប្រសិនបើមាន ឲ្យចូលមកបង្ហាញខ្លួនក្នុងថិរវេលា មិនលើសពី ១៥ (ដប់ប្រាំ) ថ្ងៃ ។

អាជ្ញាធរទទួលបន្ទុកបង្វែរ ត្រូវសាកសួរពីមូលហេតុដែលអនីតិជននោះមិនគោរពតាមវិធានការបង្វែរ ។

ក្រោយពីបានពិចារណាអំពីទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច អាជ្ញាធរទទួលបន្ទុកបង្វែរអាចចេញដីកាបង្វែរថ្មី ឬបន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

បទប្បញ្ញត្តិនៃមាត្រា ៦៦ (ការរៀបចំបង្កើតផែនការបង្វែរ) ដល់ មាត្រា ៧០ (ការកែប្រែវិធានការបង្វែរ)ខាងលើនេះ ត្រូវយកមកអនុវត្តក្នុងករណីដែលអាជ្ញាធរទទួលបន្ទុកបង្វែរចេញដីកាបង្វែរថ្មី ។

ក្នុងករណីអនីតិជនមិនបង្ហាញខ្លួនតាមការកោះហៅដោយគ្មានមូលហេតុសមស្រប អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវបន្តចាត់ការបន្តតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ១១
## ការដោះលែងដោយមានលក្ខខណ្ឌ

### មាត្រា ៧២.- ការដោះលែងដោយមានលក្ខខណ្ឌ

ការដោះលែងដោយមានលក្ខខណ្ឌ អាចត្រូវផ្តល់ឲ្យដល់ទណ្ឌិតជាអនីតិជនដែលទទួលរងទោសក្នុងមណ្ឌលយុវនីតិសម្បទា ៖

- ចំនួនមួយភាគបីនៃទោស ប្រសិនបើទោសតិចជាង ឬស្មើ ១ (មួយ) ឆ្នាំ
- ចំនួនពាក់កណ្តាលនៃទោស ក្នុងករណីផ្សេងទៀត ។

### មាត្រា ៧៣.- បុគ្គលដែលមានសិទ្ធិស្នើសុំដោះលែងដោយមានលក្ខខណ្ឌ

បុគ្គលដែលមានសិទ្ធិស្នើសុំដោះលែងអនីតិជនដោយមានលក្ខខណ្ឌ រួមមាន ៖

- ទណ្ឌិតដែលជាអនីតិជន ឬមេធាវីរបស់ជននោះ
- អ្នកតំណាងដែលច្បាប់បានកំណត់
- ប្រធានមណ្ឌលយុវនីតិសម្បទា

- ភ្នាក់ងារសង្គមកិច្ចដែលពាក់ព័ន្ធនឹងរឿងក្ដីអនីតិជននោះ
- បេសកកម្មការទូត ឬកុងស៊ុលបរទេស ក្នុងករណីអនីតិជនជាជនបរទេស ។

## ជំពូកទី ១២
## ការផ្ដល់ និងការមាននីតិសម្បទាឡើងវិញ

### មាត្រា ៧៤.- លក្ខខណ្ឌលើរយៈពេលទាក់ទងនឹងពាក្យសុំឲ្យមានការផ្ដល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ

ពាក្យសុំឲ្យមាននីតិសម្បទាឡើងវិញអាចនឹងដាក់ជូនសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ពិនិត្យបាន លុះត្រាតែផុតរយៈពេលដូចតទៅ ៖

- ២ (ពីរ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៦ (ប្រាំមួយ) ខែ ចំពោះបទមជ្ឈិម
- ១ (មួយ) ខែ ចំពោះបទលហុ ។

រយៈពេលនេះចាប់ផ្ដើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល ។

ពាក្យសុំអាចត្រូវធ្វើឡើងដោយ ៖

- ទណ្ឌិតជានីតិជនដែលបានប្រព្រឹត្តបទល្មើសនៅពេលខ្លួនជាអនីតិជន
- អ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងករណីទណ្ឌិតជាអនីតិជន ។

### មាត្រា ៧៥.- ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់

នីតិសម្បទាត្រូវមានឡើងវិញដោយពេញលក្ខណៈច្បាប់នៅពេលផុតរយៈពេល ៖

- ៣ (បី)ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ១ (មួយ)ឆ្នាំ ចំពោះបទមជ្ឈិម
- ៣ (បី)ខែ ចំពោះបទលហុ។

រយៈពេលនេះចាប់ផ្ដើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល ។

ROYAUME DU CAMBODGE · MINISTRE DU PALAIS ROYAL

## ជំពូកទី ១៣

## ការបង្កើត និងសមត្ថកិច្ចគ្រប់គ្រងមណ្ឌលយុវនីតិសម្បទា

### មាត្រា ៧៦.- ការបង្កើតមណ្ឌលយុវនីតិសម្បទា

ត្រូវបង្កើតឲ្យមានមណ្ឌលយុវនីតិសម្បទានៅតាមរាជធានី ខេត្ត សម្រាប់គ្រប់គ្រងអនីតិជន ។ មណ្ឌលនេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា ត្រូវកំណត់ដោយអនុក្រឹត្យ ។

### មាត្រា ៧៧.- ការបែងចែកការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា

ការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា ត្រូវបែងចែកជា ៣ (បី) ផ្នែកដាច់ដោយឡែកពីគ្នា ៖

- ផ្នែកសម្រាប់ឃុំខ្លួនអនីតិជនបណ្ដោះអាសន្ន
- ផ្នែកសម្រាប់ឃុំខ្លួនទណ្ឌិតជាអនីតិជនដើម្បីទទួលកម្មវិធីស្ដារនីតិសម្បទា
- ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជន ដើម្បីទទួលកម្មវិធីសមាហរណកម្ម ។

បែបបទនៃការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទាដែលត្រូវជាប់ឃុំ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

### មាត្រា ៧៨.- បញ្ជីឈ្មោះអនីតិជន

គ្រប់មណ្ឌលយុវនីតិសម្បទា ត្រូវមានបញ្ជី និងនីតិវិធីដោយឡែកសម្រាប់ចុះឈ្មោះ និងគ្រប់គ្រងអនីតិជន ព្រមទាំងបំពេញព័ត៌មានពាក់ព័ន្ធទាំងអស់ និងរក្សាឲ្យមានសុវត្ថិភាព ។

បញ្ជី និងនីតិវិធីដោយឡែកនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## ជំពូកទី ១៤

## វិធានការទាក់ទងនឹងការឃុំខ្លួនអនីតិជន

### មាត្រា ៧៩.- គោលបំណងនៃការឃុំខ្លួន

ការឃុំខ្លួនអនីតិជនធ្វើឡើងក្នុងគោលបំណងស្ដារនីតិសម្បទា ជាអាទិ៍ ការបណ្ដុះបណ្ដាលការព្យាបាល ការថែទាំ ការការពារ ការអប់រំ និងផ្ដល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយអនីតិជនឲ្យក្លាយទៅជាពលរដ្ឋសុចរិត និងមានប្រយោជន៍ដល់សង្គមជាតិ ។

មន្ត្រីមណ្ឌលឃុំនីតិសម្បទាដែលទទួលបន្ទុកគ្រប់គ្រងអនីតិជន ត្រូវទទួលការបណ្តុះបណ្តាលអំពីចិត្តសាស្ត្រ សុខុមាលភាព បទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងកុមារ និងវិធានការសម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព ។

## មាត្រា ៨០.- សិទ្ធិជាមូលដ្ឋានរបស់អនីតិជនដែលជាប់ឃុំ

អនីតិជនដែលជាប់ឃុំទាំងអស់ត្រូវទទួលបានសិទ្ធិជាមូលដ្ឋានដូចតទៅ ៖

- សិទ្ធិទទួលបានការសិក្សាអប់រំ
- សិទ្ធិរួចផុតពីការធ្វើទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ បន្ទាបបន្ថោក ការដាក់ទណ្ឌកម្មលើរូបកាយ និងផ្លូវចិត្ត ឬប្រើប្រាស់ទម្រង់ផ្សេងៗសម្រាប់ធ្វើទណ្ឌកម្ម រួមមានការដាក់ឱ្យនៅឯកា ការដាក់កំហិត ឬបដិសេធមិនឱ្យមានការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ការកាត់បន្ថយចំណីអាហារ និងពលកម្មដោយបង្ខំ
- សិទ្ធិទទួលបានវិធានការដាក់វិន័យដែលស្របតាមសេចក្តីថ្លៃថ្នូររបស់អនីតិជន
- សិទ្ធិទទួលបានការណែនាំអំពីបទបញ្ជាផ្ទៃក្នុង អំពីសិទ្ធិ និងកាតព្វកិច្ច
- សិទ្ធិផ្តល់ដំណឹងអំពីការឃុំខ្លួន ការផ្ទេរ ការដោះលែងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការការពារ ការពិនិត្យសុខភាព និងការព្យាបាលជំងឺ ឬរបួស និងផ្តល់ដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការអនុញ្ញាតឱ្យមានការសួរសុខទុក្ខជាលក្ខណៈឯកជនពីសំណាក់សមាជិកគ្រួសារ ឬមិត្តភក្តិ
- សិទ្ធិទទួលបានយន្តការបណ្តឹងប្រកបដោយប្រសិទ្ធភាព និងរក្សាការសម្ងាត់ទាក់ទងនឹងលក្ខខណ្ឌ និងការប្រព្រឹត្តមកលើខ្លួនក្នុងពេលឃុំខ្លួន
- សិទ្ធិផ្សេងទៀតដែលទទួលស្គាល់ដោយបទដ្ឋានគតិយុត្តជាធរមាន ។

## មាត្រា ៨១.- សេវាសម្រាប់អនីតិជនក្នុងមណ្ឌលឃុំនីតិសម្បទា

អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកមណ្ឌលឃុំនីតិសម្បទាទាំងអស់ ត្រូវផ្តល់សេវាដល់អនីតិជនដែលកំពុងជាប់ឃុំដូចខាងក្រោមនេះ ៖

- ការពារ ថែទាំ និងផ្តល់រាល់តម្រូវការចាំបាច់ផ្ទាល់ខ្លួនដោយស្របតាមបុគ្គលិកលក្ខណៈ ជំនឿ សាសនា ភេទ និងអាយុរបស់អនីតិជន
- ស្នាក់នៅជាក្រុម ឬជាឯកត្តបុគ្គល
- សិក្សាអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សិល្បៈ កីឡា កម្សាន្ត និងសម្រាកពីការងារ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- សុខភាពផ្លូវកាយនិងផ្លូវចិត្តសមស្រប
- ពិនិត្យវាយតម្លៃសុខភាពដោយមន្ទីរពេទ្យ ។ ត្រូវកត់បញ្ចូលទៅក្នុងសំណុំរឿងអនីតិជនជាប់ឃុំនៃព័ត៌មានអំពីរបួសស្នាម ជំងឺផ្លូវចិត្ត ពិការភាពផ្នែកកាយសម្បទា ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត
- សេវាផ្សេងទៀតដែលលើកស្ទួយសុខភាពនិងមោទនភាពចំពោះខ្លួនឯង លើកទឹកចិត្តឲ្យមានគំនិតទទួលខុសត្រូវ លើកទឹកចិត្តឲ្យមានអាកប្បកិរិយា និងជំនាញដែលនឹងជួយអនីតិជនក្នុងការអភិវឌ្ឍសក្តានុពលរបស់ខ្លួនក្លាយជាពលរដ្ឋល្អម្នាក់នៅក្នុងសង្គម និងជួយឲ្យពួកគេវិលត្រឡប់មកក្នុងសង្គមវិញបន្ទាប់ពីបានដោះលែង ។

## មាត្រា ៨២.- ការរក្សាអនីតិជន

ត្រូវរក្សាអនីតិជននៅក្នុងមណ្ឌលយុវនីតិសម្បទាដូចខាងក្រោមនេះ ៖

- អនីតិជនត្រូវដាក់ដោយឡែកពីនីតិជន
- នៅក្នុងអគារដាច់ដោយឡែកទៅតាមភេទផ្សេងគ្នា តាមប្រភេទ និងស្ថានភាពនៃបទល្មើស អាយុ អត្តចរិត សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អនីតិជន ។ អនីតិជនភេទស្រីត្រូវស្ថិតនៅក្រោមការថែទាំរបស់បុគ្គលិកភេទស្រីដូចគ្នា
- នៅក្នុងអគារដាច់ដោយឡែក និងដឹកជញ្ជូនតាមមធ្យោបាយដាច់ដោយឡែកសម្រាប់អនីតិជនដែលមានជំងឺឆ្លង ។

ប្រសិនបើទណ្ឌិតជាអនីតិជនឈានចូលអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ក្នុងពេលបាន និងកំពុងអនុវត្តទោសនៅក្នុងមណ្ឌលយុវនីតិសម្បទា ទណ្ឌិតនោះត្រូវបានរក្សាទុកនៅក្នុងមណ្ឌលយុវនីតិសម្បទាបន្តរហូតដល់អាយុក្រោម ២៤ (ម្ភៃបួន) ឆ្នាំ។ នៅពេលទណ្ឌិតឈានចូលអាយុគ្រប់ ២៤ (ម្ភៃបួន) ឆ្នាំ ទណ្ឌិតនោះត្រូវផ្ទេរទៅអនុវត្តទោសបន្តនៅក្នុងមណ្ឌលឃុំខ្លួនសម្រាប់នីតិជន ។

បែបបទនិងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលទណ្ឌិត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## មាត្រា ៨៣.- ចំណាត់ថ្នាក់សន្តិសុខនៅក្នុងមណ្ឌលយុវនីតិសម្បទា

ចំណាត់ថ្នាក់សន្តិសុខសម្រាប់អនីតិជននៅក្នុងមណ្ឌលយុវនីតិសម្បទា ត្រូវស្ថិតក្នុងចំណាត់ថ្នាក់ទាបបំផុត និងត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## មាត្រា ៨៤.- ភ្នាក់ងារក្នុងមណ្ឌលយុវនីតិសម្បទា

ភ្នាក់ងារទាំងអស់ដែលធ្វើការជាមួយអនីតិជននៅក្នុងមណ្ឌលយុវនីតិសម្បទា ជាអាទិ៍ មន្ត្រីមណ្ឌលយុវនីតិសម្បទា ភ្នាក់ងារសង្គមកិច្ច អ្នកជំនាញផ្នែកអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អ្នកពិគ្រោះយោបល់ និងបំណិនជីវិត និងអ្នកចិត្តសាស្ត្រ ឬគ្រូពេទ្យព្យាបាលជំងឺផ្លូវចិត្ត ត្រូវតែទទួលបាននូវការបណ្តុះ បណ្តាលត្រឹមត្រូវអំពីចិត្តសាស្ត្រកុមារ សុខុមាលភាពកុមារ និងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិកុមារ និងការប្រព្រឹត្តមកលើអនីតិជនដែលត្រូវបានដកហូតសេរីភាព ។

មន្ត្រី ឬបុគ្គលិកមណ្ឌលយុវនីតិសម្បទា មិនត្រូវប្រើ ឬបញ្ជាជនដែលកំពុងជាប់ឃុំឲ្យដាក់វិន័យទៅលើអនីតិជន ឬធ្វើកិច្ចការជំនួសខ្លួនឡើយ ។

## មាត្រា ៨៥.- ការធ្វើអធិការកិច្ចមណ្ឌលយុវនីតិសម្បទា

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញាអមសាលាដំបូង ប្រធានសភាស៊ើបសួរ ចៅក្រមស៊ើបសួរ ត្រូវធ្វើអធិការកិច្ចជាប្រចាំលើមណ្ឌលយុវនីតិសម្បទា ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងធានាថាលក្ខខណ្ឌនៃការប្រព្រឹត្ត និងការឃុំខ្លួនត្រូវអនុវត្តដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ជាធរមាន ។

យន្តការបង្ការថ្នាក់ជាតិ និងមន្ត្រីមានសមត្ថកិច្ចផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់មានសិទ្ធិធ្វើទស្សនកិច្ចមណ្ឌលយុវនីតិសម្បទានានាបានគ្រប់ពេលវេលា ។

# ជំពូកទី ១៥
# អន្តរប្បញ្ញត្តិ

## មាត្រា ៨៦.- បទប្បញ្ញត្តិទាក់ទងនឹងចៅក្រម

ចៅក្រមអយ្យការ និងចៅក្រមដែលត្រូវបានចាត់ឲ្យទទួលបន្ទុកលើរឿងក្តីអនីតិជនតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវចាត់ការបន្តរហូតដល់ពេលមានចៅក្រមជំនាញទាក់ទងនឹងអនីតិជន ។

## មាត្រា ៨៧.- នគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន

នគរបាលយុត្តិធម៌ដែលកំពុងចាត់ការលើរឿងក្តីអនីតិជនតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវចាត់ការបន្តរហូតដល់ពេលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន ។

**មាត្រា ៨៨.- មណ្ឌលយុវនីតិសម្បទា**

ក្នុងករណីមិនទាន់មានមណ្ឌលយុវនីតិសម្បទា វិធានការទាំងឡាយដែលកំពុងអនុវត្តទៅលើអនីតិជន ត្រូវបន្តអនុវត្តរហូតដល់មានមណ្ឌលយុវនីតិសម្បទា ។

បែបបទ និងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលអនីតិជន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## ជំពូកទី ១៦

## អវសានប្បញ្ញត្តិ

**មាត្រា ៨៩.- ការអនុវត្តច្បាប់នេះ**

ក្រោយពីចូលជាធរមាននៅទូទាំងប្រទេស ច្បាប់នេះត្រូវផ្សព្វផ្សាយរយៈពេល ៦ (ប្រាំមួយ) ខែ ទើបអនុវត្ត ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ**

រកម.០៧១៦.០១០

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**ហត្ថលេខា**

**វង សូត**

លេខ: ៧១៩ ស.ណ

**សំណៅចម្លងចេញពីច្បាប់ដើម**

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ឧបសម្ព័ន្ធទី៥ ៖ ទម្រង់នៃដីការបស់ព្រះរាជអាជ្ញា

អយ្យការអម

តុលាការខេត្ត-ក្រុង

..........................

********

សំណុំរឿងព្រហ្មទណ្ឌលេខ ....................

ចុះថ្ងៃទី ......... ខែ ............ ឆ្នាំ .........

លេខ: ....................................................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**********

# ដីកាកោះ

******

យើង.........................................................តំណាងអយ្យការអមតុលាការខេត្ត-ក្រុង ...............................................

អញ្ជើញឈ្មោះ ................................................ ជា.......................................................................ទីលំនៅបច្ចុប្បន្ននៅ

ភូមិ ...................... ឃុំ-សង្កាត់ ................................... ស្រុក-ខណ្ឌ ..................................... ខេត្ត-ក្រុង ......................

ឱ្យចូលទៅកាន់អយ្យការអមតុលាការខេត្ត-ក្រុង.................................................. នៅវេលាម៉ោង ...............................

ថ្ងៃទិ............. ខែ.................. ឆ្នាំ...................... ។

ដើម្បី...........................................................................................................................................................

.....................................................................................................................................................................

.................................................................................................................................................................... ។

សាមីខ្លួនត្រូវអញ្ជើញទៅឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមក ជាមួយផង ប្រសិនបើមាន ។

ធ្វើនៅ............................ ថ្ងៃទិ.............ខែ............... ឆ្នាំ............

**ព្រះរាជអាជ្ញា**

យើង..........................................ជា..........................................................................................

បានប្រគល់ដីកាកោះនេះឱ្យឈ្មោះ ..........................................................................................

ទីលំនៅបច្ចុប្បន្ននៅភូមិ............................ ឃុំ-សង្កាត់......................................ស្រុក-ខណ្ឌ..............................

ខេត្ត-ក្រុង ............................ នៅថ្ងៃទី.............. ខែ.............. ឆ្នាំ.................. ហើយយើងបានប្រាប់ថា សាមីខ្លួន ត្រូវប្រគល់ចុងដីកាកោះនេះ ដល់ក្រឡាបញ្ជីនៅពេលដែលខ្លួនចូលទៅចំពោះមុខអយ្យការអមតុលាការ ខេត្ត-ក្រុង ...............................។

*អ្នកទទួល*

ហត្ថលេខា ឬផ្តិតមេដៃ

*អ្នកប្រគល់*

ហត្ថលេខា

អយ្យការអម.
តុលាការខេត្ត-ក្រុង
..............................
*********

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**********

# ដីកាបង្គាប់ឱ្យចូលខ្លួន[១]

សំណុំរឿងព្រហ្មទណ្ឌលេខ ....................
ចុះថ្ងៃទី .......... ខែ ............ ឆ្នាំ ........
លេខ: ..............................................
*********

យើង .................................................... តំណាងអយ្យការអម តុលាការខេត្ត-ក្រុង ...........................។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ................ ចុះថ្ងៃទី ............ ខែ ..................... ឆ្នាំ.....................។

បានឃើញដីកាកោះលេខ............... ចុះថ្ងៃទី .......... ខែ ...............ឆ្នាំ ............... ដែលតំណាងអយ្យការបានចាត់ការតាមនីតិវិធិត្រឹមត្រូវរួចហើយ ប៉ុន្តែឈ្មោះនេះ មិនព្រមចូលខ្លួនមកបំភ្លឺនៅចំពោះមុខអយ្យការតាមកាលកំណត់ទេ។

បង្គាប់មកឈ្មោះ .......................................... ភេទ............... អាយុ ........... ឆ្នាំ ជាតិ ............................
ទីលំនៅបច្ចុប្បន្ន នៅភូមិ.......................ឃុំ-សង្កាត់ .................................. ស្រុក-ខណ្ឌ ......................................
ខេត្ត-ក្រុង ..........................................ឱ្យចូលខ្លួនទៅកាន់អយ្យការអមតុលាការ ខេត្ត-ក្រុង ...........................
នៅថ្ងៃទី........................... ខែ .................................... ឆ្នាំ ............................ វេលាម៉ោង .................................
ដើម្បី ......................................................................................................................................................
.......................................................................................................................................................។

ក្នុងករណីមិនចូលខ្លួនតាមកាលកំណត់ខាងលើនេះទេ *យើងនឹងចេញដីកាបង្គាប់ឱ្យនាំខ្លួន* ។

ធ្វើនៅ....................... ថ្ងៃទី........ ខែ.......... ឆ្នាំ ............

ព្រះរាជអាជ្ញា

យើង.................................... ជា ....................................................................................................

បានប្រគល់ដីកាបង្គាប់ឱ្យចូលខ្លួននេះដល់ឈ្មោះ.......................................................ទីលំនៅបច្ចុប្បន្ននៅភូមិ...............

ឃុំ-សង្កាត់ ........................ស្រុក-ខណ្ឌ .................................... ខេត្ត-ក្រុង ..................................

នៅថ្ងៃទី ..................... ខែ .............................. ឆ្នាំ ....................... ហើយយើងបានប្រាប់ថា

ឱ្យយកចុងដីកានេះទៅប្រគល់ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅចំពោះមុខអយ្យការអមតុលាការខេត្ត-

ក្រុង .................................................. ។

ក្នុងករណីមិនចូលខ្លួនតាមកាលកំណត់ខាងលើនេះទេ យើងនឹងចេញដីកាបង្គាប់ឱ្យនាំខ្លួន ។

អ្នកទទួល

ហត្ថលេខា ឬ ស្នាមមេដៃ

អ្នកប្រគល់

ហត្ថលេខា

អយ្យការអម

តុលាការ ខេត្ត-ក្រុង

.......................

*******

លេខ.......................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*********

# ដីកាបង្គាប់ឱ្យនាំខ្លួន

*********

យើង........................................ តំណាងអយ្យការអមតុលាការខេត្ត-ក្រុង ...................................................... ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ............. ចុះថ្ងៃទី ................ ខែ................. ឆ្នាំ................................ ។

បានឃើញ.........................................................................................................................................................

........................................................................................................................................................................

យល់ឃើញថា........................................................................................................................................... ។

........................................................................................................................................................................

........................................................................................................................................................................

........................................................................................................................................................................

........................................................................................................................................................................ ។

យល់ឃើញថា ដើម្បីធានាដល់ការកំណត់បទល្មើសឱ្យបានច្បាស់លាស់ គប្បីសំរេចនាំខ្លួនឈ្មោះ .........................................
មកចំពោះមុខ តំណាងអយ្យការដើម្បីបំភ្លឺការពិត ក្នុងសំណុំរឿងក្តីនេះ ។

## ហេតុដូច្នេះ សម្រេច

បង្គាប់ឱ្យនាំខ្លួនឈ្មោះ.............................................................................. ភេទ............ អាយុ.............. ឆ្នាំ
ជាតិ.................... របររកស៊ី.......................................................................... ទីលំនៅបច្ចុប្បន្នភូមិ.........................................
ឃុំ-សង្កាត់.................................................. ស្រុក-ខណ្ឌ.................................... ខេត្ត-ក្រុង...........................................
ដើម្បីសាកសួរយកពត៌មានផ្សេងៗ ទាក់ទងនឹងសំណុំរឿងព្រហ្មទណ្ឌខាងលើ ។

បង្គាប់មកលោក................................................ជា.........................................................................................
................................................................................................ អនុវត្តដីកានេះ ឱ្យបានសម្រេច ។

ធ្វើនៅ..................... ថ្ងៃទី......... ខែ.............. ឆ្នាំ........

ព្រះរាជអាជ្ញា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

••••••••••

អយ្យការអម

តុលាការខេត្ត-ក្រុង

.......................

•••••••

# ដីកាបញ្ឈប់ឱ្យនាំខ្លួន

••••••••••

លេខ.......................

យើង.......................................................អយ្យការអមតុលាការខេត្ត-ក្រុង.......................................។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ...................ចុះថ្ងៃទី...............ខែ.......................ឆ្នាំ.......................

បានឃើញ.......... ...................................................................................................................................

...........................................................................................................................................................។

យល់ឃើញថា...............................................................................................................................................

...........................................................................................................................................................

...........................................................................................................................................................

...........................................................................................................................................................។

## ហេតុដូច្នេះ សម្រេច:

បង្គាប់ទៅភ្នាក់ងារមានសមត្ថកិច្ចឱ្យបញ្ឈប់នាំខ្លួនឈ្មោះ.......................................................................

ភេទ.............អាយុ..................ឆ្នាំ ជាតិ....................................របររកស៊ី.............................................

ទីលំនៅបច្ចុប្បន្នភូមិ.................. ឃុំ-សង្កាត់........................... ស្រុក-ខណ្ឌ...........................ខេត្ត-ក្រុង..............................

ដែលទាក់ទងនឹងសំណុំរឿងព្រហ្មទណ្ឌខាងលើ ចាប់ពីពេលនេះតទៅ ។

ធ្វើនៅ................................ ថ្ងៃទី......... ខែ......... ឆ្នាំ ២០០....

ព្រះរាជអាជ្ញា